ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍អំពី
# ស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច
# របស់
# ជនជាតិដើមភាគតិចនៅកម្ពុជា



សហការរៀបចំដោយ

ក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ

បោះពុម្ពឆ្នាំ២០២១

ឧបត្ថម្ភបច្ចេកទេសដោយ

IRAM

The NGO Forum on Cambodia

AIPP

UNFPA

UN DESA

ឧបត្ថម្ភហិរញ្ញវត្ថុដោយ

HEINRICH BÖLL STIFTUNG

Diakonia People Change the World

European Commission

VOICE

Norwegian People's Aid

OXFAM

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍អំពី

# ស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ច
# របស់
# ជនជាតិដើមភាគតិចនៅកម្ពុជា

សហការរៀបចំដោយ

ក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ

ឆ្នាំ២០២១

# មាតិកា

**មាតិកា** ........ i
**បញ្ជីតារាង** ........ iv
**បញ្ជីក្រាហ្វិក** ........ vi
**បញ្ជីអក្សរកាត់** ........ viii
បុព្វកថា ........ x
សេចក្តីសង្ខេប ........ xii
ផែនទីចំនួនប្រជាជនជនជាតិដើមភាគតិចនិងភាគរយនៃប្រជាជនដែលចេះអក្សរខ្មែរ ........ xviii
១. សេចក្តីផ្តើម ........ ១
១.១. សាវតា ........ ១
១.២. គោលបំណង ........ ៥
១.៣. ដែនកំណត់ ........ ៥
១.៤. វិធីសាស្ត្រ ........ ៦
២. ស្ថានភាពប្រជាសាស្ត្ររបស់ជនជាតិដើមភាគតិច ........ ៨
២.១. ចំនួននិងអំបូរជនជាតិដើមភាគតិច ........ ៨
២.១.១. ចំនួនជនជាតិដើមភាគតិចតាមអំបូរនីមួយៗ ........ ៩
២.១.២. ចំនួនអំបូរជនជាតិដើមភាគតិចនៅតាមខេត្តនីមួយៗ ........ ១១
២.១.៣. របាយភាគរយនៃជនជាតិដើមភាគតិចតាមខេត្តនីមួយៗ តាមអំបូរជនជាតិ ........ ១៥
២.១.៤. ចំនួនភូមិដែលមានជនជាតិដើមភាគតិចរស់នៅ ........ ១៦
២.២. ស្ថានភាពប្រជាសាស្ត្រនៃជនជាតិដើមភាគតិច ........ ១៧
២.២.១. រចនាសម្ព័ន្ធអាយុភេទ ........ ១៧
២.២.២. គ្រួសារនិងអាពាហ៍ពិពាហ៍ ........ ២៥
២.២.៣. អត្រាកំណើត ........ ៣៤

២.២.៤. អត្រាមរណភាព.................................................................................................................៣៨
២.២.៥. ទេសន្តរប្រវេសន៍.................................................................................................................៣៩
២.២.៦. ប្រជាជនវ័យចាស់ .................................................................................................................៤២
៣. ស្ថានភាពសង្គម-សេដ្ឋកិច្ច.................................................................................................................៤៥
៣.១. ការអប់រំ.................................................................................................................៤៥
៣.១.១. អត្រាអក្ខរភាព .................................................................................................................៤៥
៣.១.២. អត្រាការចូលរៀន និងមិនបានចូលរៀន.................................................................................................................៤៦
៣.១.៣. អត្រាបោះបង់ការសិក្សាតាមអាយុនិងតាមភេទ .................................................................................................................៤៧
៣.១.៤. ការចូលរៀនយឺតនិងរៀននៅកម្រិតទាបជាងអាយុ.................................................................................................................៤៨
៣.១.៥. ការទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ.................................................................................................................៥០
៣.១.៦. ការទទួលបានការអប់រំ គិតតាមភេទ .................................................................................................................៥២
៣.២. ការងារនិងស្ថានភាពសេដ្ឋកិច្ច.................................................................................................................៥៣
៣.២.១. ប្រជាជនសកម្មសេដ្ឋកិច្ចនិងអសកម្មសេដ្ឋកិច្ច.................................................................................................................៥៤
៣.២.២. កម្លាំងពលកម្មតាមភេទ .................................................................................................................៥៥
៣.២.៣. កម្លាំងពលកម្មតាមក្រុមអាយុនិងតាមភេទ .................................................................................................................៥៥
៣.២.៤. ប្រជាជនសកម្មសេដ្ឋកិច្ចតាមអំបូរជនជាតិដើមភាគតិច.................................................................................................................៥៦
៣.២.៥. អត្រាគ្មានការងារធ្វើតាមភេទនិងក្រុមអាយុ.................................................................................................................៥៨
៣.២.៦. អត្រាគ្មានការងារធ្វើតាមអំបូរជនជាតិដើមភាគតិច.................................................................................................................៥៩
៣.២.៧. ស្ថានភាពការងាររបស់ជនជាតិដើមភាគតិច .................................................................................................................៦០
៣.២.៨. ការងារតាមវិស័យសេដ្ឋកិច្ច .................................................................................................................៦១
៣.២.៩. ការងារតាមផ្នែក.................................................................................................................៦១
៣.២.១០. កម្រិតវប្បធម៌របស់ជនជាតិភាគតិចដែលមានការងារធ្វើ .................................................................................................................៦២
៣.២.១១. ប្រាក់ចំណូល .................................................................................................................៦៣
៣.៣. សុខភាពនិងអនាម័យ.................................................................................................................៦៣
៣.៣.១. ការមានជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ .................................................................................................................៦៣

៣.៣.២. ជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ ........ ៦៤
៣.៣.៣. ការរកសេវាពិគ្រោះព្យាបាលជំងឺ ........ ៦៥
៣.៣.៤. ការទទួលបានសេវាសុខភាពមាតា ........ ៦៧
៣.៣.៥. ការបំបៅដោះនិងការចិញ្ចឹមកូន ........ ៦៨
៣.៣.៦. ពិការភាព ........ ៦៩
៣.៣.៧. អនាម័យ ........ ៧០
៣.៤. សាសនានិងជំនឿ ........ ៧១
៤. លំនៅឋាន ដីធ្លី និងកម្មសិទ្ធិ ........ ៧២
៤.១. លំនៅឋាន ........ ៧២
៤.២. ដីធ្លីនិងកម្មសិទ្ធិ ........ ៧៥
៤.២.១. ដីធ្លីនិងកម្មសិទ្ធិឯកជន ........ ៧៥
៤.២.២. ដីធ្លីនិងកម្មសិទ្ធិជាលក្ខណៈសមូហភាពសហគមន៍ជនជាតិដើមភាគតិច ........ ៧៥
៥. សេចក្តីសន្និដ្ឋាន ........ ៧៧
ឧបសម្ព័ន្ធទី១. ប្រវត្តិសកម្មភាពនិងលទ្ធផលការងារនៃការរៀបចំ របាយការណ៍ ........ ៧៩
ឧបសម្ព័ន្ធទី២. ភូមិដែលមានជនជាតិដើមភាគតិច ១០នាក់ឡើង ........ ៩០
ឧបសម្ព័ន្ធទី៣. ភូមិគ្រួសារជនជាតិដើមភាគតិច ........ ១១០
ឧបសម្ព័ន្ធទី៤. សហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ ........ ១៤២
ឧបសម្ព័ន្ធទី៥. សហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ........ ១៤៩
ឧបសម្ព័ន្ធទី៦. ដីសហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីនិងចែកប័ណ្ណ ........ ១៥៦
ឧបសម្ព័ន្ធទី៧. ក្រុមការងាររៀបចំផលិតរបាយការណ៍ ........ ១៥៩
សទ្ទានុក្រម ........ ១៦០

# បញ្ជីតារាង


តារាងទី១. ចំនួនប្រជាជននិងអំបូរជនជាតិដើមភាគតិច និងអត្រាកំណើនប្រចាំឆ្នាំ ............ ៨

តារាងទី២. ចំនួនជនជាតិដើមភាគតិចតាមអំបូរនីមួយៗ ............ ១០

តារាងទី៣. ចំនួនអំបូរជនជាតិដើមភាគតិចដែលមានប្រជាជនយ៉ាងតិច១០០នាក់ ............ ១៣

តារាងទី៤. ចំនួនអំបូរជនជាតិដើមភាគតិចដែលមានប្រជាជនតិចជាង១០០នាក់ ............ ១៤

តារាងទី៥. ចំនួននិងភាគរយជនជាតិដើមភាគតិចក្នុងរាជធានីខេត្តចំនួន៣ដែលមានចំនួនច្រើនជាងគេតាមអំបូរនីមួយៗ ............ ១៥

តារាងទី៦. ខេត្ត/ស្រុក/ឃុំ/ភូមិ ដែលមានជនជាតិដើមភាគតិច ១០នាក់/១ភូមិឡើងទៅ ............ ១៦

តារាងទី៧. របាយភេទនៃជនជាតិដើមភាគតិច ............ ១៨

តារាងទី៨. ភាគរយស្ត្រីតាមអំបូរជនជាតិដើមភាគតិច ............ ១៩

តារាងទី៩. របាយអាយុនៃជនជាតិដើមភាគតិចតាមក្រុមអាយុ៥ឆ្នាំ ............ ២០

តារាងទី១០. របាយអាយុនៃជនជាតិដើមភាគតិចតាមវ័យ ............ ២១

តារាងទី១១. ផលធៀបអ្នកក្នុងបន្ទុក ............ ២៥

តារាងទី១២. ចំនួនគ្រួសារ និងភាគរយនៃគ្រួសារដែលស្ត្រីជាមេគ្រួសារ ............ ២៦

តារាងទី១៣. ស្ថានភាពអាពាហ៍ពិពាហ៍ ............ ២៨

តារាងទី១៤. អាយុស្ត្រីនាពេលមានកូនដំបូង ............ ៣៣

តារាងទី១៥. អត្រាមរណភាពទូទៅនិងអត្រាកំណើតក្នុងរយៈ១២ខែកន្លង ............ ៣៤

តារាងទី១៦. អត្រាមរណភាពទារក ............ ៣៩

តារាងទី១៧. ចំនួននិងភាគរយអ្នកផ្លាស់ទីលំនៅ ............ ៤០

តារាងទី១៨. លំហូរទេសន្តរប្រវេសន៍ (ឆ្នាំ២០១៣) ............ ៤១

តារាងទី១៩. មូលហេតុទេសន្តរប្រវេសន៍ (របាយភាគរយ) ............ ៤១

តារាងទី២០. ភាគរយមនុស្សចាស់ទៅតាមអំបូរជនជាតិដើមភាគតិច ............ ៤៣

តារាងទី២១. របាយមនុស្សចាស់តាមខេត្ត ឆ្នាំ២០១៣ ............ ៤៤

តារាងទី២២. ភាគរយមិនបានរៀន កំពុងរៀន និងឈប់រៀន ឆ្នាំ២០១៣ ....................................៤៧

តារាងទី២៣. កម្រិតសិក្សាអប់រំ និងវិជ្ជាជីវៈរបស់ប្រជាជនអាយុ១៥ឆ្នាំឡើងនិងអាយុ២៥ឆ្នាំឡើង ឆ្នាំ ២០១៣ .......................................................................................................................... ៥២

តារាងទី២៤. កម្រិតអប់រំខ្ពស់បំផុតដែលបានបញ្ចប់គិតតាមភេទ ឆ្នាំ២០១៣................................៥៣

តារាងទី២៥. ប្រជាជនសកម្មនិងអសកម្មសេដ្ឋកិច្ចអាយុ៥ឆ្នាំឡើង និងអាយុ១៥ឆ្នាំឡើង ឆ្នាំ២០១៣ ៥៤

តារាងទី២៦. ប្រជាជនសកម្មសេដ្ឋកិច្ចតាមភេទ ឆ្នាំ២០១៣ .................................................... ៥៥

តារាងទី២៧. ផ្នែកនៃការងាររបស់ជនជាតិដើមភាគតិចដែលមានការងារធ្វើ ឆ្នាំ២០១៣ .................៦២

តារាងទី២៨. ពិការភាពនៃជនជាតិដើមភាគតិចពីកំណើត និងក្រោយកំណើត.............................. ៦៩

តារាងទី២៩. ពិការភាព តាមភេទនិងក្រុមអាយុ ឆ្នាំ២០១៣ .....................................................៧០

តារាងទី៣០. គ្រួសារជនជាតិមានបង្គន់អនាម័យនិងទឹកស្អាតបរិភោគ.........................................៧១

តារាងទី៣១. សាសនារបស់ជនជាតិដើមភាគតិច ...................................................................៧១

តារាងទី៣២. លំនៅឋានជនជាតិដើមភាគតិច .......................................................................៧២

តារាងទី៣៣. ប្រភពភ្លើងបំភ្លឺរបស់គ្រួសារជនជាតិដើមភាគតិច................................................ ៧៣

តារាងទី៣៤. ប្រភពថាមពលចម្អិនរបស់គ្រួសារជនជាតិដើមភាគតិច........................................ ៧៣

តារាងទី៣៥. សម្ភារៈប្រើប្រាស់នៅក្នុងផ្ទះរបស់គ្រួសារជនជាតិដើមភាគតិច ................................៧៤

តារាងទី៣៦.ចំនួនសហគមន៍ជនជាតិដើមភាគតិច ដែលចុះបញ្ជីនៅក្រសួងមហាផ្ទៃ គិតត្រឹមខែមិថុនា ឆ្នាំ ២០២១ ..........................................................................................................................៧៥

តារាងទី៣៧. ដីសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីនិងដែលបានចែកប័ណ្ណ ពីឆ្នាំ២០១១ ដល់ ២០២០ .....................................................................................................................៧៦

# បញ្ជីក្រាហ្វិក


ក្រាហ្វិកទី១. ខេត្តនិងចំនួនអំបូរជនជាតិដែលមានប្រជាជនយ៉ាងតិច១.០០០នាក់ ........................ ១២

ក្រាហ្វិកទី២. ផលធៀបភេទតាមក្រុមអាយុ ........................ ១៨

ក្រាហ្វិកទី៣. របាយវ័យនៃជនជាតិដើមភាគតិចតាមអំបូរធំៗទាំង១២ ........................ ២២

ក្រាហ្វិកទី៤. ពីរ៉ាមីដប្រជាជនកម្ពុជានិងជនជាតិដើមភាគតិច ឆ្នាំ២០១៣ ........................ ២៤

ក្រាហ្វិកទី៥. ភាគរយនៃស្ត្រីជាមេគ្រួសារតាមខេត្តនីមួយ ឆ្នាំ២០១៣ ........................ ២៧

ក្រាហ្វិកទី៦. ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច នៅឆ្នាំ២០០៨ ........................ ៣១

ក្រាហ្វិកទី៧. អាពាហ៍ពិពាហ៍កាត់ជនជាតិ នៅឆ្នាំ២០០៨ ........................ ៣២

ក្រាហ្វិកទី៨. អាយុរៀបការដំបូង ........................ ៣៣

ក្រាហ្វិកទី៩. ចំនួនកូនដែលបានបង្កើតតាមក្រុមអាយុស្ត្រី នៅឆ្នាំ២០១៣ ........................ ៣៥

ក្រាហ្វិកទី១០. ភាគរយស្ត្រីសម្រាលកូនទៅតាមវត្តមានបុគ្គលិកសុខាភិបាល ........................ ៣៦

ក្រាហ្វិកទី១១. ភាគរយស្ត្រីសម្រាលកូនទៅតាមអំបូរជនជាតិនិងវត្តមានបុគ្គលិកសុខាភិបាល ........................ ៣៦

ក្រាហ្វិកទី១២. ភាគរយកុមារអាយុក្រោម១ឆ្នាំបានចុះបញ្ជីកំណើត នៅឆ្នាំ២០១៣ ........................ ៣៧

ក្រាហ្វិកទី១៣. របាយភាគរយស្ត្រីរៀបការហើយ តាមចំនួនកូនដែលបានបង្កើត នៅឆ្នាំ២០១៣ ........................ ៣៨

ក្រាហ្វិកទី១៤. ភាគរយមនុស្សចាស់អាយុ៦០ឆ្នាំឡើង៖ ឆ្នាំ២០០៨និង២០១៣ ........................ ៤២

ក្រាហ្វិកទី១៥. អត្រាអក្ខរភាពមនុស្សទូទៅនិងអក្ខរភាពមនុស្សពេញវ័យ ឆ្នាំ២០១៣ ........................ ៤៦

ក្រាហ្វិកទី១៦. អត្រាបោះបង់ការសិក្សាតាមអាយុរបស់កុមារជនជាតិដើមភាគតិចនៅឆ្នាំ២០១៣ ........................ ៤៨

ក្រាហ្វិកទី១៧. អាយុនិងកម្រិតសិក្សាកំពុងរៀន នៅឆ្នាំ២០១៣ ........................ ៤៩

ក្រាហ្វិកទី១៨. របាយភាគរយជនជាតិដើមភាគតិចអាយុ៦-១៨ឆ្នាំ ដែលមិនបានចូលរៀន កំពុងរៀន និង ឈប់រៀន តាមអំបូរធំៗឆ្នាំ២០១៣ ........................ ៥០

ក្រាហ្វិកទី១៩. កម្លាំងពលកម្មតាមភេទនិងក្រុមអាយុ ឆ្នាំ២០១៣ ........................ ៥៦

ក្រាហ្វិកទី២០. ប្រជាជនសកម្មសេដ្ឋកិច្ចតាមអំបូរជនជាតិដើមភាគតិច ឆ្នាំ២០១៣ ........................ ៥៧

ក្រាហ្វិកទី២១. អត្រាគ្មានការងារធ្វើតាមអាយុនិងភេទ ឆ្នាំ២០១៣ ........................ ៥៨

ក្រាហ្វិកទី២២.អត្រាគ្មានការងារធ្វើតាមអំបូរជនជាតិ ..................................................................... ៥៩
ក្រាហ្វិកទី២៣.ស្ថានភាពការងារជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងមានការងារធ្វើឆ្នាំ២០១៣ .... ៦០
ក្រាហ្វិកទី២៤. ការងារតាមវិស័យសេដ្ឋកិច្ចនៃជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ឆ្នាំ២០១៣ ..... ៦១
ក្រាហ្វិកទី២៥. កម្រិតវប្បធម៌របស់ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើ ......... ៦២
ក្រាហ្វិកទី២៦. ភាគរយមានជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ តាមភេទនិងក្រុមអាយុ ឆ្នាំ២០១៥ ........ ៦៤
ក្រាហ្វិកទី២៧. ជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ ឆ្នាំ២០១៥ ........................................................ ៦៥
ក្រាហ្វិកទី២៨. ការរកសេវាពិគ្រោះព្យាបាលនិងរយៈពេលមានជំងឺ ឆ្នាំ២០១៥ .............................. ៦៦
ក្រាហ្វិកទី២៩. សេវាសុខភាពដែលបានទៅរកមុនគេពេលឈឺ (២០១៥) .................................. ៦៦
ក្រាហ្វិកទី៣០. សេវាថែទាំគភ៌ចុងក្រោយ ឆ្នាំ២០១៥ ............................................................... ៦៧
ក្រាហ្វិកទី៣១. ទីកន្លែងសម្រាលចុងក្រោយ ........................................................................... ៦៨

# បញ្ជីអក្សរកាត់

| | |
|---|---|
| AIPP | Asia Indigenous Peoples´Pact<br>សម្ព័ន្ធជនជាតិដើមអាស៊ី |
| CDB | Commune Database<br>ទិន្នន័យឃុំសង្កាត់ |
| CDHS | Cambodia Demographic and Health Survey<br>អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា |
| CIPA | Cambodia Indigenous Peoples Alliance<br>សម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា |
| CIPL | Conserve Indigenous People Languages Organization<br>អង្គការអភិរក្សភាសាជនជាតិដើមភាគតិច |
| CIPO | Cambodia Indigenous Peoples Organization<br>អង្គការជនជាតិដើមភាគតិចកម្ពុជា |
| CIPS | Cambodia Inter-Censal Population Survey<br>អង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា |
| CIWA | Cambodia Indigenous Women Association.<br>សមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា |
| CIYA | Cambodia Indigenous Youth Association<br>សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា |
| CSES | Cambodia Socio-Economic Survey<br>របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |
| Diakonia | អង្គការឌៀកូនៀ |
| HA | Highlanders Association<br>អង្គការសមាគមខ្មែរលើ |
| HBF | Heinrich Boll Stitung<br>មូលនិធិហេនរេចបូល |
| IADC | Indigenous Peoples for Agricuture Development in Cambodia<br>អង្គការជនជាតិដើមភាគតិចអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| ILO | International Labour Organization<br>អង្គការពលកម្មអន្តរជាតិ |

| | |
|---|---|
| IRAM | Indigenous Rights Active Members<br>សមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិច |
| NPA | Norwegian People's Aid Cambodia<br>អង្គការជំនួយនៃប្រជាពលរដ្ឋន័រវេស្សន៍ ប្រចាំប្រទេសកម្ពុជា |
| NGO FORUM | The NGO Forum on Cambodia<br>វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា |
| ODC | Open Development Cambodia<br>អង្គការទិន្នន័យអំពីការអភិវឌ្ឍ |
| OPKC | Organization for the Promotion of Kui Culture.<br>អង្គការលើកស្ទួយវប្បធម៌កួយ |
| Oxfam in Cambodia | អង្គការអុកស្វាមប្រចាំប្រទេសកម្ពុជា |
| SMAM | Singulate Mean Age at Marriage<br>វិធីមួយ ប្រើសម្រាប់គណនារកអាយុមធ្យមនៅពេលរៀបការដំបូង |
| UN-DESA/DSPD | UN Department of Economic and Social Affairs / Division for Social Policy and Development<br>នាយកដ្ឋានកិច្ចការសេដ្ឋកិច្ចនិងសង្គម ផ្នែកអភិវឌ្ឍន៍និងគោលនយោបាយសង្គម របស់អង្គការសហប្រជាជាតិ |
| UNDP | United Nations Development Programme<br>កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| UNFPA | United Nations Population Fund<br>មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |

# បុព្វកថា

របាយការណ៍ជាតិស្តីពី ***ស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា*** ជារបាយការណ៍លើកដំបូងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលបានបង្កើតឡើងដោយផ្អែកលើទិន្នន័យមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការព័ត៌មានថ្នាក់ជាតិដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ លម្អិត និងសង្គតិភាព អំពីជនជាតិដើមភាគតិចនៅកម្ពុជា សម្រាប់ការងាររៀបចំផែនការនិងសកម្មភាពអភិវឌ្ឍន៍ជនជាតិដើមភាគតិចនៅកម្ពុជា ដែលតែងតែទទួលបានការគាំទ្រនិងយកចិត្តទុកដាក់បំផុតពីរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ នៅក្នុងបរិការណ៍នេះ របាយការណ៍នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ជាព័ត៌មានទូទៅនិងលម្អិតអំពីស្ថានភាពប្រជាសាស្ត្រ ស្ថានភាពសង្គម-សេដ្ឋកិច្ច និងការរស់នៅរបស់ជនជាតិដើមភាគតិចនៅកម្ពុជា សម្រាប់ជាមូលដ្ឋានតម្រង់ទិសដល់ការរៀបចំផែនការ និងសកម្មភាពអភិវឌ្ឍន៍ជនជាតិដើមភាគតិចឱ្យចំគោលដៅ ការសិក្សាស្រាវជ្រាវពាក់ព័ន្ធនានា និងការធ្វើបច្ចុប្បន្នភាពព័ត៌មានជនជាតិដើមភាគតិចនៅកម្ពុជា។

របាយការណ៍ជាតិស្តីពី **ស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា** គឺជាសមិទ្ធិផលរួមគ្នារវាងក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានការចូលរួមគាំទ្រផ្នែកស្មារតីពីមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (United Nations Population Fund) និងនាយកដ្ឋានស្តីពីកិច្ចការសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិ / ផ្នែកគោលនយោបាយនិងអភិវឌ្ឍន៍សង្គម (UN Department of Economic and Social Affairs/Division for Social Policy and Development) រួមទាំងអង្គការជនជាតិដើមភាគតិចកម្ពុជា (Cambodia Indigenous Peoples organization) និងការគាំទ្រផ្នែកហិរញ្ញវត្ថុពីមូលនិធិហេនរេចបូលរបស់អាល្លឺម៉ង់ (The Heinrich Böll Foundation) សម្ព័ន្ធជនជាតិដើមភាគតិចអាស៊ី (Asia Indigenous Peoples Pact) អង្គការអុកស្វាមប្រចាំកម្ពុជា (Oxfam in Cambodia) អង្គការដៀកូនៀ (Diakonia) និងជំនួយប្រជាពលរដ្ឋន័រវេស្សន៍ (Norwegian People's Aid, NPA) តាមរយៈអង្គការជនជាតិដើមភាគតិចកម្ពុជា។ របាយការណ៍ដែលមាន៥ជំពូកនេះ (ទី១ សេចក្តីផ្តើម ទី២ ស្ថានភាពប្រជាសាស្ត្រ ទី៣ ស្ថានភាពសង្គម-សេដ្ឋកិច្ច ទី៤ លំនៅឋាន ដីធ្លី និងកម្មសិទ្ធិសមូហភាព និងទី៥ សេចក្តីសន្និដ្ឋាន) ត្រូវបានរៀបចំឡើងដោយមានការឯកភាពលើទម្រង់ ចំណុចគោលសំខាន់ៗ និងខ្លឹមសារ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ចំនួន១៤លើក រវាងក្រុមការងារបច្ចេកទេសនិងថ្នាក់ដឹកនាំនៃក្រសួងទាំងពីរ រួមជាមួយនឹងសមាជិកសម្ព័ន្ធជនជាតិដើមកម្ពុជា រួមមាន CIPO, CIYA, CIPL, OPKC, HA, IRAM, IADC, CIWA និងODC បានដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់ទូលាយពីអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ដែលមានសមាសភាពចូលរួមចំនួន៦៤នាក់ មកពីក្រសួងស្ថាប័នចំនួន១៧ អង្គការជាតិនិងអន្តរជាតិដែលធ្វើការងារពាក់ព័ន្ធនឹងជនជាតិដើមភាគតិចនៅកម្ពុជា និងតំណាងសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា

កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ នៅសណ្ឋាគារសោខាន់វេ ក្រោមអធិបតីភាពរបស់**លោកជំទាវ ម៉ាត់ ម៉ារ៉ា** រដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមថ្នាក់ដឹកនាំនៃក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**ឯកឧត្តមបណ្ឌិត ប៉ូច បុណ្ណាក់** រដ្ឋលេខាធិការក្រសួងផែនការ ដែលបានដឹកនាំការងារសរសេររបាយការណ៍នេះ និងសូមអគុណចំពោះក្រុមការងាររបស់អគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍនៃក្រសួងផែនការ ព្រមទាំងក្រុមការងាររបស់នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ និងសមាជិកសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា ជាពិសេស អង្គការជនជាតិដើមភាគតិចកម្ពុជា ដែលបានផ្តួចផ្តើមនិងចូលរួមយ៉ាងសកម្មនិងសហការល្អប្រសើរក្នុងដំណើរការរៀបចំរបាយការណ៍នេះ។ យើងខ្ញុំ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរដល់មូលនិធិហេនរេចបូលរបស់អាល្លឺម៉ង់ សម្ព័ន្ធជនជាតិដើមភាគតិចអាស៊ី អង្គការអុកស្វាមកម្ពុជា អង្គការជៀកូនៀ និងអង្គការ ជំនួយប្រជា-ពលរដ្ឋន័រវេស្សន៍ ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការរៀបចំរបាយការណ៍នេះឡើង។ សូមអរគុណចំពោះតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលចូលរួមផ្តល់ធាតុចូលបន្ថែមក្នុងការកែលម្អរបាយការណ៍នេះឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទូលំទូលាយ និងសុក្រឹត។

យើងខ្ញុំមានជំនឿយ៉ាងមុតមាំថា **របាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គមសេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា** នឹងផ្តល់នូវព័ត៌មានបឋមដ៏មានសារសំខាន់ពាក់ព័ន្ធនឹងស្ថានភាពប្រជាសាស្ត្រ សង្គមសេដ្ឋកិច្ច និងសហគមន៍នៃជនជាតិដើមភាគតិចនៅកម្ពុជា ដល់អ្នករៀបចំផែនការអភិវឌ្ឍន៍ វិនិយោគិន អ្នកសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធក្នុងកិច្ចការអភិវឌ្ឍន៍ជនជាតិដើមភាគតិចនៅកម្ពុជា។

ថ្ងៃ ចន្ទ ៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី ក្រសួងផែនការ**

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

**រដ្ឋមន្ត្រី**
**ក្រសួងអភិវឌ្ឍន៍ជនបទ**

**ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន**

# សេចក្តីសង្ខេប

របាយការណ៍នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ជាព័ត៌មានលម្អិតជាបឋមអំពីស្ថានភាពប្រជាសាស្ត្រ ស្ថានភាពសង្គម-សេដ្ឋកិច្ច និងការរស់នៅរបស់ជនជាតិដើមភាគតិច ដោយផ្អែកលើទិន្នន័យមានស្រាប់ ដែលជាមូលដ្ឋានតម្រង់ទិសដល់ការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងការស្រាវជ្រាវបន្ត។

ដោយប្រើភាសានិយាយពីកំណើតសម្រាប់កំណត់អត្តសញ្ញាណជនជាតិដើមភាគតិចនៅកម្ពុជា មានចំនួន២២អំបូរ ដែលមានចំនួនប្រជាជនសរុប ១៧៩.១៩៣នាក់ ស្មើនឹង ១,៣៤% នៃប្រជាជនកម្ពុជាសរុប នៅឆ្នាំ២០០៨ និង មានចំនួន១៨៣.៨៣១នាក់ ស្មើនឹង១,២៥% នៃប្រជាជនកម្ពុជាសរុប នៅឆ្នាំ២០១៣ (អត្រាកំណើនមានត្រឹម0,៥១% ក្នុងមួយឆ្នាំ)។ ក្នុងចំណោមអំបូរទាំង២២ ជនជាតិដើមភាគតិចដែលមានចំនួនច្រើនជាង១ម៉ឺននាក់ មានតែ៦អំបូរប៉ុណ្ណោះ គឺ ទំពួន ព្នង គ្រឹង កួយ ចារាយ និងព្រៅ ដែលសរុបមានចំនួនស្មើនឹង៨៨%នៃប្រជាជនជនជាតិដើមភាគតិចទាំង២២អំបូរ។ ទោះជាបច្ចុប្បន្ន ជនជាតិដើមភាគតិចរស់នៅស្ទើរគ្រប់រាជធានីខេត្ត ភាគច្រើនលើសលប់នៃជនជាតិដើមភាគតិចរស់នៅ ក្នុងខេត្តចំនួន៦ប៉ុណ្ណោះ គឺខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង កំពង់ធំ និងព្រះវិហារ ដែលមានចំនួន ៩២,៤%នៃជនជាតិដើមភាគតិចរស់ទាំងអស់នៅឆ្នាំ២០១៣។

១. ស្ថានភាពប្រជាសាស្ត្រនៃជនជាតិដើមភាគតិច

ប្រជាជននៃជនជាតិដើមភាគតិចជាប្រជាជនវ័យក្មេង ដែលប្រជាជនអាយុក្រោម១៥ឆ្នាំមានដល់ទៅ៤១,៧% នៅឆ្នាំ២០០៨ និងថយចុះត្រឹម ៣៧,៤% នៅឆ្នាំ២០១៣។ ក៏ប៉ុន្តែ ប្រជាជនជនជាតិដើមភាគតិចក្នុងវ័យធ្វើការ ក៏កើនឡើងដែរក្នុងចន្លោះឆ្នាំ២០០៨-២០១៣ ដោយអត្រាកំណើនប្រចាំឆ្នាំស្មើនឹង ១,២៣%។ គិតតាមវ័យ នៅឆ្នាំ២០០៨ កុមារអាយុក្រោម៥ឆ្នាំមានចំនួន១៣,៦% អាយុ៥ឆ្នាំ-១៧ឆ្នាំមានចំនួន៣៤,៤% វ័យចាប់ផ្តើមការងារអាយុ១៨ឆ្នាំ-៣៥ឆ្នាំមានចំនួន២៨,៨% វ័យកណ្តាលអាយុ៣៦ឆ្នាំ-៥៩ឆ្នាំមានចំនួន១៧,៨% និងវ័យចាស់អាយុ៦០ឆ្នាំឡើងមានចំនួន៥,៤%។ នៅឆ្នាំ២០១៣ របាយភាគរយនៃអាយុតាមវ័យនេះ ប្រែប្រួលតិចតួច។

ភាគរយស្ត្រីជនជាតិដើមភាគតិច ប្រហាក់ប្រហែលនឹងប្រជាជនកម្ពុជាទូទៅ នឹងមិនប្រែប្រួលគួរឱ្យកត់សម្គាល់ទេ (៥០,៩%នៅឆ្នាំ២០០៨ និង ៥១,១%នៅឆ្នាំ២០១៣)។ បើគិតពីផលធៀបភេទតាមក្រុមអាយុ ជនជាតិដើមភាគតិចមានផលធៀបភេទធំជាង១០០ក្នុងចំណោមប្រជាជនវ័យក្មេង តែផលធៀបភេទនេះមានទំហំកាន់តែតូច កាលណាអាយុប្រជាជនកាន់តែកើន។

គ្រួសារជនជាតិដើមភាគតិច មានទំហំគ្រួសារធំជាងទំហំគ្រួសាររបស់ប្រជាជនកម្ពុជាទូទៅ ដែលមានចំនួនសមាជិកជាមធ្យមក្នុងមួយគ្រួសារ ៥,៣នាក់នៅឆ្នាំ២០០៨និង៤,៩នាក់នៅឆ្នាំ២០១៣។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានចំនួន១៤%នៅឆ្នាំ២០០៨ និង២២%ភាគរយនៅឆ្នាំ២០១៣ និងប្រហែល១៨%នៃគ្រួសារជនជាតិដើមភាគតិច ជាគ្រួសារដែលមានតែប្តីជាជនជាតិដើម ឯប្រពន្ធជាជនជាតិផ្សេងទៀត ឬជាគ្រួសារដែលមានតែប្រពន្ធជាជនជាតិដើមភាគតិច ឯប្តីជាជនជាតិផ្សេងទៀត។

ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច ជាទូទៅប្រហាក់ប្រហែលគ្នានឹងស្ថានភាពអាពាហ៍ពិពាហ៍របស់ប្រជាជនកម្ពុជាទាំងមូល និងប្រែប្រួលតិចតួចពីឆ្នាំ២០០៨ដល់២០១៣។ ជាទូទៅស្ត្រីជនជាតិដើមភាគតិចដែលមិនទាន់រៀបការមានភាគរយទាបជាងបុរស តែស្ត្រីមេម៉ាយ/លែងលះ/បែកបាក់ មានភាគរយខ្ពស់ជាងបុរស។ ក៏ប៉ុន្តែ ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិចខុសគ្នាខ្លាំងពីអំបូរជនជាតិមួយទៅអំបូរជនជាតិមួយទៀត។ ជនជាតិដើមភាគតិចឆាប់រៀបការជាងប្រជាជនកម្ពុជាទូទៅដោយចំនួន២ឆ្នាំ ដែលអាយុមធ្យមពេលរៀបការដំបូងនៃជនជាតិដើមភាគតិចគឺ២២,៧ឆ្នាំ ធៀបនឹងអាយុ២៤,៩ឆ្នាំនៃប្រជាជនកម្ពុជាទូទៅគិតជាមធ្យម។ ចំពោះបុរសជនជាតិដើមភាគតិចឆាប់រៀបការជាងប្រជាជនកម្ពុជាទូទៅដោយចំនួនជិត៣ឆ្នាំ (គឺ២៣,៤ឆ្នាំ ទល់នឹង២៦,២ឆ្នាំ)។ ចំពោះស្ត្រី ជនជាតិដើមភាគតិចឆាប់រៀបការជាងប្រជាជនកម្ពុជាទូទៅដោយចំនួនជិត២ឆ្នាំ (គឺ២២,១ឆ្នាំ ទល់នឹង២៣,៧ឆ្នាំ)។

ការឆាប់រៀបការ បណ្តាលឱ្យឆាប់មានកូននិងមានកូនច្រើន។ អត្រាកំណើតដុលរបស់ជនជាតិដើមភាគតិច ស្មើនឹង៣,៤នាក់ក្នុងចំណោមស្ត្រីរៀបការហើយចំនួន១០០នាក់នៅឆ្នាំ២០០៨ និង ៣,៧នាក់នៅឆ្នាំ២០១៣។ គិតតាមក្រុមអាយុ ស្ត្រីជនជាតិដើមភាគតិចដែលរៀបការហើយ មានចំនួនកូនដែលបានបង្កើតច្រើនជាងស្ត្រីកម្ពុជានៅគ្រប់វ័យ ពិសេសស្ត្រីក្នុងក្រុមអាយុពី២០ឡើងទៅ ហើយចំនួនខុសគ្នានេះកាន់តែធំកាលណាស្ត្រីអាយុកាន់តែច្រើន។

ទិន្នន័យអំពីអាយុនៅពេលមានកូនដំបូងបង្ហាញថា ស្ត្រីជនជាតិដើមភាគតិចដែលរៀបការហើយ និងមានកូនដំបូងនៅអាយុក្រោម២០ឆ្នាំ មានចំនួនជិត២ដងនៃចំនួនស្ត្រីកម្ពុជាសរុប (៣៩%ទល់នឹង២១,៦%) រីឯស្ត្រីជនជាតិដើមភាគតិចដែលរៀបការហើយនិងដែលមានកូនដំបូងនៅអាយុ២០ឆ្នាំឡើងទៅ មានចំនួនភាគរយតិចជាងស្ត្រីកម្ពុជាគ្រប់ក្រុមអាយុទាំងអស់។ ស្ត្រីជនជាតិដើមភាគតិចដែលមានកូននៅអាយុ២០-២៤ឆ្នាំមានចំនួន៤៣,៣% នៅអាយុ២៥-២៩ឆ្នាំមានចំនួន១៣,៩% និងនៅអាយុ៣០ឆ្នាំឡើងមានចំនួន៣,៨% (ធៀបនឹងស្ត្រីកម្ពុជា ដែលមានចំនួនរៀងគ្នា ៥២,៧% ១៨,៦% និង៧,១%)។ ក៏ប៉ុន្តែ ស្ត្រីជនជាតិដើមភាគតិច ច្រើនសម្រាលកូនដោយឆ្មបបុរាណ (៦៥,៦% នៃកំណើតក្នុងរយៈ១២ខែកន្លងមក ធៀបនឹងស្ត្រីកម្ពុជាដែលមានត្រឹមតែ៩,៨%) ជាពិសេសជនជាតិគ្រឹង ទំពួន ចារាយ ការ៉ែត

និងកួយ។ គួរកត់សម្គាល់ផងដែរថា កុមារជនជាតិដើមភាគតិចអាយុក្រោម១ឆ្នាំតែមួយភាគប្រាំប៉ុណ្ណោះ (២០,៣%) ដែលបានចុះបញ្ជីកំណើត។ ឯជនជាតិដើមភាគតិចដែលបានចុះបញ្ជីកំណើតកូនអាយុក្រោម១ឆ្នាំបានច្រើនជាងគេ គឺជនជាតិព្រៅ ការ៉ែត ព្នង គ្រឹង ទំពួន និងចារាយ។

ជារួមអត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំរបស់ជនជាតិដើមភាគតិចមានកម្រិតខ្ពស់ និងថយចុះតិចតួច (១៣៩នាក់នៅឆ្នាំ២០០៨ និង ១២៦នាក់នៅឆ្នាំ២០១៣ ក្នុងចំណោមកំណើតរស់១.០០០នាក់ ធៀបនឹងកម្ពុជាសរុបដែលមានត្រឹម៣៣នាក់នៅឆ្នាំ២០១៣)។ គ្មានទិន្នន័យអំពីអត្រាមរណភាពមាតារបស់ជនជាតិដើមភាគតិចទេ។

ជនជាតិដើមភាគតិចធ្វើទេសន្តរប្រវេសន៍ក្នុងទំហំតិចជាងប្រជាជនកម្ពុជាសរុប (ជិត១០%នៃជនជាតិដើមភាគតិចទាំងអស់ ៩%ក្នុងចំណោមអ្នករស់នៅជនបទ និងជិត៥៣%ក្នុងចំណោមអ្នករស់នៅទីប្រជុំជន)។ ជនជាតិដើមភាគតិចច្រើនធ្វើទេសន្តរប្រវេសន៍ពីតំបន់ជនបទមួយទៅកាន់តំបន់ជនបទមួយផ្សេងទៀត (៨៥,៤%) បន្ទាប់មកគឺទេសន្តរប្រវេសន៍រវាងទីប្រជុំជន (៦,៦%) និងទេសន្តរប្រវេសន៍ពីតំបន់ទីប្រជុំជនទៅកាន់តំបន់ជនបទ (៥,៩%)។ ជារួម ស្ត្រីជនជាតិដើមភាគតិចផ្លាស់ទីទៅកាន់ទីប្រជុំជនច្រើនជាងបុរស។ រីឯមូលហេតុចម្បងនៃទេសន្តរប្រវេសន៍ គឺគ្រួសារនិងការរៀបការ (៧២,១%) ការវិលត្រឡប់មកស្រុកវិញ (១០,១%សរុប) និងការស្វែងរកការងារ (៩,៩%សរុប)។

ប្រជាជនវ័យចាស់អាយុ៦០ឆ្នាំឡើងក្នុងចំណោមជនជាតិដើមភាគតិច មានចំនួន៥,៤% នៅឆ្នាំ២០០៨ និង ៦,៧% នៅឆ្នាំ២០១៣។ ជាទូទៅ ស្ត្រីវ័យចាស់អាយុ៦០ឆ្នាំឡើង មានចំនួនច្រើនជាងបុរសវ័យចាស់អាយុ៦០ឆ្នាំឡើង តែភាពខុសគ្នាមានទំហំតូចក្នុងចំណោមជនជាតិដើមភាគតិច ជាងក្នុងចំណោមប្រជាជនកម្ពុជាសរុប។ គួរកត់សម្គាល់ថា ជនជាតិដើមភាគតិចតូចៗចំនួនពីរអំបូរ មានប្រជាជនវ័យចាស់ច្រើន គឺជនជាតិស្អូច (២៨%) និងជនជាតិចាអុង (១០%) នៅឆ្នាំ២០១៣។

២. ស្ថានភាពសង្គម-សេដ្ឋកិច្ច

<u>ការអប់រំ</u>

ជនជាតិដើមភាគតិចបានទទួលការអប់រំតិច ដោយសារអត្រាចូលរៀនទាប ការរៀននៅកម្រិតទាបជាងអាយុ និងការបោះបង់ការសិក្សា។ ប្រហែល១ភាគ៣នៃជនជាតិដើមភាគតិចប៉ុណ្ណោះ ដែលចេះអាននិងសរសេរភាសាខ្មែរ (៣៤,៣%ក្នុងចំណោមជនជាតិដើមភាគតិចអាយុ៧ឆ្នាំឡើង និង៣៣.៨%ក្នុងចំណោមជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង) ហើយបុរសជាទូទៅមានអត្រាអក្ខរភាពខ្ពស់ជាងស្ត្រី។ កុមារជនជាតិដើមភាគតិចជិត៥០% មិនដែលបានរៀនសោះ រីឯភាគរយកុមារជនជាតិដើមភាគតិចកំពុង

នៅរៀនមានចំនួនតិចជាង៥០% (៤៩,០៣% ក្នុងក្រុមអាយុ៦-១៣ឆ្នាំ និង៤៣,៥៦% ក្នុងក្រុមអាយុ៦-១៨ឆ្នាំ)។ ថ្វីត្បិតការបោះបង់ការសិក្សាមានតិចតួចក្នុងចំណោមក្មេងប្រុសអាយុក្រោម១៤ឆ្នាំ និងក្មេងស្រីអាយុក្រោម១៥ឆ្នាំ ការបោះបង់ការសិក្សាចាប់ផ្តើមមានទំហំគួរឱ្យកត់សម្គាល់ចាប់ពីអាយុ១៤-១៥ឆ្នាំទៅ និងការបោះបង់ការសិក្សាច្រើនបំផុតត្រូវបានសង្កេតឃើញនៅក្នុងក្រុមអាយុ១៦-១៨ឆ្នាំ។ លើសពីនេះទៀត ជនជាតិដើមភាគតិចនៅបានទទួលការអប់រំយឺតយ៉ាវជាងវ័យសិក្សារបស់ខ្លួនច្រើនទៀតផង ដែលអាចបណ្តាលមកពីការចូលរៀនយឺតឬការរៀនត្រួតថ្នាក់។

ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ជិត៦៦%មិនបានរៀនឬបញ្ចប់កម្រិតសិក្សាអ្វីទាំងអស់ រីឯ២៤,១%ទៀតបានរៀនត្រឹមបឋមសិក្សាប៉ុណ្ណោះ (ជាសរុប ៩០%បានរៀនតិចតួចឬមិនបានរៀនសោះ)។ រីឯអ្នកបានរៀនយ៉ាងហោចណាស់ដល់កម្រិតមធ្យមសិក្សាបឋមភូមិមានចំនួនប្រហែល១០% ដែលក្នុងនោះអ្នករៀនបានកម្រិតមធ្យមសិក្សាទុតិយភូមិមានចំនួន៤% និងអ្នកបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួនក្រោម១%។ ទោះយ៉ាងណាក្តី ទិន្នន័យបង្ហាញថាជនជាតិដើមភាគតិចវ័យក្មេង មានអត្រាទទួលបានការអប់រំល្អប្រសើរជាងជនជាតិដើមភាគតិចវ័យចាស់ និងបុរសបានទទួលការអប់រំច្រើនជាងស្ត្រី។

ការងារនិងស្ថានភាពសេដ្ឋកិច្ច

ជនជាតិដើមភាគតិចមានអត្រាសកម្មសេដ្ឋកិច្ចនិងអត្រាមានការងារធ្វើខ្ពស់ និងខុសគ្នាតិចតួចរវាងបុរសនិងស្ត្រី។ ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ៨៧,១%ជាប្រជាជនសកម្មសេដ្ឋកិច្ច (៨៦,៦%ជាអ្នកមានការងារធ្វើ និង០,៥%ជាអ្នកគ្មានការងារធ្វើ) និង១២,៩%ជាប្រជាជនមិនសកម្មសេដ្ឋកិច្ច។ អត្រាមានការងារធ្វើមានចំនួន៨៧,៧%ក្នុងចំណោមបុរស និង៨៥,៥%ក្នុងចំណោមស្ត្រី និងអត្រាគ្មានការងារធ្វើមានចំនួន០,៦%ក្នុងចំណោមបុរស និង០,៥%ក្នុងចំណោមស្ត្រី។ គិតតាមអំបូរជនជាតិ អំបូរដែលមានប្រជាជនច្រើន ច្រើនមានអត្រាចូលរួមកម្លាំងពលកម្មច្រើន ដូចជាទំពួន ព្នង គ្រឹង ព្រៅ កួយ ក្រោល និងការ៉ែត។

ក៏ប៉ុន្តែ ភាគច្រើននៃជនជាតិដើមភាគតិច ធ្វើការងារដោយគ្មានប្រាក់ខែប្រាក់កម្រៃ (៥៧,៣%) និងប្រកបរបររកស៊ីដោយខ្លួនឯង (៣៨%) ដែលក្នុងនោះ បុរសច្រើនធ្វើការងាររកស៊ីដោយខ្លួនឯង (៥៨,៩%) ឯស្ត្រីច្រើនធ្វើការងារដោយគ្មានប្រាក់ខែប្រាក់កម្រៃ (៧៨,៤%)។ គិតតាមវិស័យសេដ្ឋកិច្ច ភាគច្រើនលើសលប់នៃជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើ ប្រកបរបរក្នុងវិស័យកសិកម្ម (សរុប៩៣,៣% បុរស៩០,៦% និងស្ត្រី៩៥,៩%) និងតិចតួចដែលធ្វើការក្នុងវិស័យឧស្សាហកម្ម

(សរុប១,៦% បុរស១,៨% និងស្ត្រី១,៤%) និងវិស័យសេវាកម្ម (សរុប៥,១% បុរស៧,៦% និងស្ត្រី ២,៨%)។

<u>សុខភាពនិងអនាម័យ</u>

នៅកម្ពុជា ពុំទាន់មានទិន្នន័យអំពីបញ្ហាសុខភាពរបស់ជនជាតិដើមភាគតិចទេ ក្រៅពីទិន្នន័យអំពីពិការភាពរបស់ជំរឿននិងអង្កេតចន្លោះជំរឿន និងទិន្នន័យអំពីពិការភាព សុខភាពមាតា ការស្វែងរកសេវាសុខភាពនិងចំណាយ និងការថែទាំកុមាររបស់អង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជា ដែលមានតែព័ត៌មានអំពីជនជាតិភាគតិចនៅកម្ពុជា។ យោងតាមទិន្នន័យអង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៥ ជនជាតិភាគតិចក្នុងស្រុកដែលធ្លាប់ឈឺក្នុងរយៈពេល៣០ថ្ងៃមុនពេលអង្កេត មានចំនួន១៤% ហើយកុមារនិងមនុស្សចាស់ឈឺច្រើនជាងគេ ឯមនុស្សក្នុងវ័យកម្លាំងពលកម្មឈឺតិចជាងគេ។ លើសពីនេះទៀត កុមារានិងបុរសវ័យចាស់ជាទូទៅឈឺច្រើនជាងកុមារីនិងស្ត្រីវ័យចាស់ប្រហែល២ដង រីឯស្ត្រីក្នុងវ័យកម្លាំងពលកម្មឈឺច្រើនជាងបុរស ២,៧ដង។ កុមារាដែលឈឺច្រើនជាងកុមារី អាចបណ្តាលមកពីកុមារាច្រើនតាមឪពុកម្តាយចេញទៅធ្វើការងារកសិកម្មឬការងារប្រមូលអនុផលព្រៃឈើផ្សេងៗ។ ជំងឺដែលឈឺច្រើនជាងគេ គឺជំងឺគ្រុនចាញ់ ជំងឺផ្លូវដង្ហើម ជំងឺគ្រុនសន្និ និងជំងឺរបេង។ សេវាសុខភាពដែលបានទៅរក មានឱសថស្ថាន មន្ទីរពេទ្យរដ្ឋ និងគ្លីនិកឯកជន។

ចំពោះសេវាសុខភាពរបស់មាតា ទារក និងកុមារ ទិន្នន័យបង្ហាញថា ស្ត្រីដែលមានកូនអាយុក្រោម៥ឆ្នាំ នាពេលធ្វើអង្កេត ច្រើនទទួលសេវាថែទាំគភ៌ពីឆ្មប (៥៨,៨%) ឆ្មបបុរាណ (២០,៦%) និងពីគិលានុបដ្ឋាយិកា (១២,៩%)។ ជនជាតិភាគតិចច្រើនសម្រាលកូននៅតាមផ្ទះ (៥៣%) និងសម្រាលកូននៅមន្ទីរពេទ្យ (៣៨%)។ ការសម្រាលកូននៅមណ្ឌលសុខភាព មានចំនួនត្រឹម៦%ប៉ុណ្ណោះ។ ស្ត្រីជាម្តាយសុទ្ធតែបានបំបៅកូនដោយទឹកដោះម្តាយទាំងអស់ គឺ៣២,២% បានចាប់ផ្តើមបំបៅដោះកូនក្នុងរយៈពេលតិចជាង១ម៉ោងក្រោយកើត ៥៦,៤%នៅក្នុងកំឡុង២ម៉ោងក្រោយកើត និង១១,៤%ក្នុងកំឡុង៥-៦ម៉ោងក្រោយកើត។ ជាពិសេសទៅទៀត ម្តាយដែលមានអាយុក្រោម២ឆ្នាំទាំងអស់នៅបន្តបំបៅដោះកូននៅឡើយ (១០០%)។

ទិន្នន័យពិការភាពបង្ហាញថា ជិត១,៥%នៃប្រជាជនជនជាតិដើមភាគតិចមានពិការភាព ដែលក្នុងនោះ ជិត៧០%ជាអ្នកពិការក្រោយកំណើត និងភាគច្រើនជាអ្នកពិការភ្នែក និងពិការអវៈយវៈ។

ការមានបង្គន់អនាម័យប្រើប្រាស់និងការមានទឹកស្អាតបរិភោគ នៅជាបញ្ហាចំពោះជនជាតិដើមភាគតិច ដោយសារភាគច្រើននៃគ្រួសារមិនទាន់មានបង្គន់អនាម័យប្រើប្រាស់ (ជាង៨០%នៅឆ្នាំ

២០១៣) និងមិនទាន់មានប្រភពទឹកស្អាតបរិភោគ (ជាង៦០%នៅឆ្នាំ២០១៣) ដែលភាគច្រើនប្រើប្រាស់ទឹកទន្លេ បឹង ស្ទឹង ព្រែក ជាប្រភពទឹកសម្រាប់បរិភោគ។

៣. លំនៅឋាន និងកម្មសិទ្ធិ

នៅឆ្នាំ២០១៣ ជាង៩៥%នៃគ្រួសារជនជាតិដើមភាគតិចមានលំនៅឋានខ្លួនឯង គឺមានចំនួន ៩៦,៣% នៅឆ្នាំ២០១៣។ ភាគច្រើននៃគ្រួសារជនជាតិដើមភាគតិច ប្រើប្រាស់ចង្កៀងប្រេងកាតនិងអាគុយជាប្រភពភ្លើងបំភ្លឺ រីឯគ្រួសារដែលប្រើប្រាស់ភ្លើងអគ្គិសនីឬម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន មានចំនួន ២០,៦%នៅឆ្នាំ២០១៣។ ចំពោះប្រភពថាមពលចម្អិន ភាគច្រើននៃគ្រួសារជនជាតិដើមភាគតិច ប្រើប្រាស់ឧសជាប្រភពថាមពលចម្អិនអាហារ (៩៥% នៅឆ្នាំ២០១៣)។

ចំពោះសម្ភារៈគ្រួសារសម្រាប់ព័ត៌មាននិងការប្រស្រ័យទាក់ទង គ្រួសារជនជាតិដើមភាគតិច ជិត១ភាគ៣មានទូរទស្សន៍ប្រើ ១១០%មានទូរស័ព្ទដៃ និងតិចជាង១%មានអ៊ីនធឺណែត។ ចំពោះសម្ភារៈគ្រួសារសម្រាប់ការធ្វើដំណើរ គ្រួសារជនជាតិដើមភាគតិចចំនួន៧៦,១%មានម៉ូតូ ២,២%មានរថយន្ត ៩,១%មានគោយន្ត ៧,៨%មានទូក និង៣៧,៤%មានកង់ (ឆ្នាំ២០១៣)។

គ្មានទិន្នន័យអំពីដីធ្លី និងកម្មសិទ្ធិឯកជនរបស់ជនជាតិដើមភាគតិចទេ។ ចំពោះកម្មសិទ្ធិដីធ្លីជាលក្ខណៈសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច សូមមើលលម្អិតនៅចំណុច ៤.២.២។

# ផែនទីចំនួនប្រជាជនជនជាតិដើមភាគតិច និងភាគរយនៃប្រជាជន អាយុ១៥-៥៩ឆ្នាំ ដែលចេះអក្សរខ្មែរ តាមរាជធានីខេត្ត

ចំនួនប្រជាជនជនជាតិដើមភាគតិចនៅតាមខេត្តនីមួយៗនៃប្រទេសកម្ពុជា




ភាគរយនៃប្រជាជនជនជាតិដើមភាគតិចអាយុ ១៥-៥៩ ឆ្នាំដែលចេះអក្សរខ្មែរនៅតាមខេត្តនីមួយៗនៃប្រទេសកម្ពុជា



# ១. សេចក្តីផ្តើម

## ១.១. សាវតា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការអភិវឌ្ឍជនជាតិដើមភាគតិច តាំងពីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជាកអំឡុងទសវត្សឆ្នាំ៨០ និងដើមទសវត្សឆ្នាំ៩០នៃសតវត្សទី២០ ដោយសារតែជនជាតិដើមភាគតិច គឺជាជនជាតិដែលរស់នៅលើដែនដីព្រះរាជាណាចក្រកម្ពុជា ហើយជនជាតិទាំងនោះបង្ហាញនូវឯកភាពជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច និងប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់តាមក្បួនខ្នាត និងទំនៀមទម្លាប់នៃការប្រើប្រាស់ដីជាសមូហភាព រួមទាំងប្រកាន់យកវប្បធម៌ ទំនៀមទំលាប់ ប្រពៃណី ជំនឿនិងភាសាផ្សេងៗគ្នាទៅតាមក្រុមរបស់ខ្លួន។ ចំណែកឯមុខរបរសំខាន់សម្រាប់ចិញ្ចឹមជីវិតរបស់ពួកគាត់ គឺការធ្វើកសិកម្មពនេចរតាមលក្ខណៈប្រពៃណី ដោយការធ្វើស្រែនិងចម្ការវិលជុំ ការប្រមូលអនុផលព្រៃឈើ ការប្រមាញ់ ការនេសាទ និងការចិញ្ចឹមសត្វជាដើម។ ការរស់នៅរបស់ពួកគាត់ គឺពឹងផ្អែកទាំងស្រុងទៅលើដីធ្លី និងធនធានធម្មជាតិ។ ម្យ៉ាងទៀតតំបន់ជនជាតិដើមភាគតិចរស់នៅ គឺនៅមានកត្តាប្រឈមជាច្រើនដូចជា ផ្លូវគមនាគមន៍ និងមធ្យោបាយធ្វើដំណើររបស់បងប្អូនមានការលំបាកនិងខ្វះខាត សុខភាពបងប្អូនជនជាតិដើមភាគតិចនៅមានភាពងាយរងគ្រោះ កង្វះប្រព័ន្ធទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនិងដាំដំណាំ ការអប់រំចំណេះដឹងទូទៅនៅមានកម្រិត កម្រិតជីវភាពរស់នៅមានកម្រិតទាប និងធនធានដីធ្លីនិងធម្មជាតិកំពុងប្រឈមការបាត់បង់។

ដើម្បីឆ្លើយតបទៅនឹងការយកចិត្តទុកដាក់ ក្នុងការដោះស្រាយបញ្ហាដែលជនជាតិដើមភាគតិចកំពុងជួបប្រទះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំអនុវត្តនិងសម្រេចបាននូវកិច្ចអភិវឌ្ឍន៍នានាជាច្រើន មានដូចជាការបង្កើតឱ្យមានច្បាប់ជាតិនិងបទដ្ឋានគតិយុត្តនានាជាច្រើន ដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច ដើម្បីទទួលស្គាល់និងគោរពសិទ្ធិជនជាតិដើមភាគតិច ដែលរួមមាន៖ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ (មាត្រា៣៤ ៤៤ និង៥៨) ច្បាប់ភូមិបាលឆ្នាំ២០០១ (ជំពូកទី២ មាត្រា២៣ដល់២៨) ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ច្បាប់និងគោលនយោបាយនានា រួមទាំងកិច្ចការអភិវឌ្ឍន៍ផ្សេងៗជាច្រើន ដូចជា៖

- បានបង្កើតគណៈកម្មាធិការពង្រឹង និងអភិវឌ្ឍន៍ភូមិភាគឦសាន្ត ក្នុងគោលបំណងជំរុញការអភិវឌ្ឍលើគ្រប់វិស័យជូនបងប្អូនជនជាតិដើមភាគតិច។

- ជួយជំរុញ និងលើកកម្ពស់ក្នុងវិស័យអប់រំ ដោយរដ្ឋាភិបាលបានផ្តល់អាទិភាពអនុគ្រោះដល់សិស្ស មកពីភូមិភាគឦសានដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចូលរៀននៅមហាវិទ្យាល័យនានានៅទីក្រុងភ្នំពេញក្នុងអត្រាមួយសមស្រប។

- មានកម្មវិធីប្រព័ន្ធអប់រំពីរភាសា ពីកំរិតមតេយ្យរហូតដល់ថ្នាក់ទី៣ នៅភូមិភាគឦសាន្ត និងមានកម្មវិធីអប់រំក្រៅប្រព័ន្ធ។

- ជួយក្នុងវិស័យថាមពលសំណង់មួយដែលមានចរិតប្រវត្តិសាស្ត្រ គឺសំណង់វារីអគ្គិសនីអូរជុំ ដែលជាប្រភេទវារីអគ្គិសនីធុនមធ្យម អាចផ្តល់អានុភាពជាង ១០០០ គីឡូវ៉ាត់ ដែលត្រូវបានចាប់ផ្តើមកសាងឡើងនាខែធ្នូ ឆ្នាំ១៩៩០ និងដាក់ឲ្យដំណើរការនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៩៣ សម្រាប់ការងារកែច្នៃកៅស៊ូឈើ និងសម្រាប់រោងចក្រ សិប្បកម្មនានា ប្រជាពលរដ្ឋ និងបណ្តាជនជាតិនៅក្នុងទីរួមខេត្តរតនគិរីប្រើប្រាស់។

- ឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវគណៈកម្មាធិការអន្តរក្រសួងសម្រាប់ធ្វើការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិក្នុងការរៀបចំគម្រោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច។

- ឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើត "នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច" ចំណុះក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងគោលដៅកែលម្អលក្ខខណ្ឌរស់នៅរបស់ជនជាតិដើមភាគតិច ក៏ដូចជាថែរក្សាវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងជំនឿរបស់ពួកគេ។ បន្ទាប់មកទៀត ក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាល ក៏បានអនុម័តអនុក្រឹត្យនិងគោលនយោបាយជាតិសំខាន់ៗដាក់លាក់ចំពោះជនជាតិដើមភាគតិចមួយចំនួនដូចជា៖ អនុក្រឹត្យនិងគោលនយោបាយស្តីពីការចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច។ ការរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច បានទទួលការគាំទ្របច្ចេកទេសនិងហិរញ្ញវត្ថុពីអង្គការ ILO និង UNDP និងត្រូវបានដឹកនាំនិងសម្របសម្រួលដោយនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ និងទទួលបានការអនុម័តដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩។ ក្នុងគោលបំណងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិចព្រមទាំងថែរក្សាវប្បធម៌ប្រពៃណីល្អ ទំនៀមទម្លាប់ និងជំនឿរបស់ពួកគាត់ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច បានផ្តោតលើការអភិវឌ្ឍវិស័យសំខាន់ៗ សរុបចំនួន ១០វិស័យ រួមមានជាអាទិ៍៖ វិស័យវប្បធម៌ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល បរិស្ថាន ដីធ្លី កសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពល។

ដើម្បីសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍលើវិស័យពាក់ព័ន្ធខាងលើ ក៏ដូចជាការជំរុញការអនុវត្ត គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ឱ្យកាន់តែប្រសើរនិងមានប្រសិទ្ធិភាព រាជរដ្ឋាភិបាលកម្ពុជា រួមមានក្រសួងស្ថាប័នពាក់ព័ន្ធជាច្រើន បាននិងកំពុងតែបន្តការយកចិត្តទុកដាក់ និងខិតខំរៀបចំផែនការអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ទៅតាមអាណត្តិការងាររបស់ខ្លួនរៀងៗខ្លួន។ លទ្ធផលជាក់ស្តែងមានដូចជា គិតត្រឹមខែមិថុនា ឆ្នាំ២០២១ ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចសរុប១៥៥សហគមន៍ និងក្រសួងមហាផ្ទៃបាន ចុះបញ្ជីនិងទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចជាសហគមន៍នីតិបុគ្គលសរុប១៥២សហគមន៍ទូទាំងប្រទេសកម្ពុជា។ ដោយឡែកក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ចុះបញ្ជីដីសហគមន៍នីតិបុគ្គលបានចំនួន៣៣ សហគមន៍ទូទាំងប្រទេសកម្ពុជា គិតត្រឹមខែធ្នូឆ្នាំ២០២០។

ដោយឡែកកាលពីឆ្នាំ២០១៧ ក្រសួងអភិវឌ្ឍន៍ជនបទបានសហការជាមួយនាយកដ្ឋានស្តីពីសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ (UN-DESA) រៀបចំសិក្ខាសាលាថ្នាក់ជាតិ នៅខេត្ត សៀមរាប នាថ្ងៃទី១១ដល់១៣ ខែមករា ឆ្នាំ២០១៧ ស្តីពីការឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ក្រោមអធិបតីភាព**ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងដោយមានការចូលរួមពីតំណាងថ្នាក់ដឹកនាំពីក្រសួងនិងស្ថាប័នពាក់ព័ន្ធចំនួន ១៦ រួមទាំងតំណាងអង្គការនិងជនជាតិដើមភាគតិច។ ជាលទ្ធផល អង្គសិក្ខាសាលាបានបង្ហាញអំពីតម្រូវការអាទិភាពមួយក្នុងចំណោមតម្រូវការអាទិភាពផ្សេងៗ ដែលជាផ្នែកមួយដ៏សំខាន់នៃការចូលរួមរៀបចំការអភិរក្ស និងអភិវឌ្ឍដល់ជនជាតិដើមភាគតិចឱ្យកាន់តែប្រសើរ គឺការបង្កើតឱ្យមានរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច របស់ជនជាតិដើមភាគតិចនៅកម្ពុជា ពីព្រោះអង្គសិក្ខាសាលាបានទទួលស្គាល់ពីការលំបាកក្នុងការលើកគម្រោងផែនការអភិវឌ្ឍន៍នានា ការកំណត់ទិសដៅលើវិស័យអាទិភាព និងការវាយតម្លៃនានាពាក់ព័ន្ធជនជាតិដើមភាគតិច ដោយសារតែកង្វះខាតទិន្នន័យឯកភាពថ្នាក់ជាតិជាផ្លូវការមួយដែលអាចប្រើប្រាស់ជាប្រយោជន៍សម្រាប់ការងារនេះ។

ផ្អែកលើស្មារតីនៃអង្គសិក្ខាសាលានេះ ក្រសួងផែនការបានឯកភាពនិងសហការជាមួយនឹងក្រសួងអភិវឌ្ឍន៍ជនបទ រៀបចំបង្កើតរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនេះឡើង តាមរយៈលិខិតផ្លូវការលេខ០៨០៦/១៧ ក.អ.ជ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ របស់ឯកឧត្តមអ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីសំណើកិច្ចសហការរៀបចំរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច របស់ជនជាតិដើមភាគតិចនៅកម្ពុជា និងការធ្វើបច្ចុប្បន្នភាពរបាយការណ៍ជាតិ និងលិខិតឆ្លើយតបលេខ ១០៩៨ ផក ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៧ របស់**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ដែលខ្លឹមសារគូស

បញ្ជាក់ថា របាយការណ៍ជាតិស្ដីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ច របស់ជនជាតិដើមភាគតិច នៅកម្ពុជានេះ ពិតជាមានសារៈសំខាន់ក្នុងការជំរុញការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍជនជាតិដើមភាគតិច ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច ជាពិសេស**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** បានផ្ដល់អនុសាសន៍ដើម្បីបង្កើតក្រុមការងារបច្ចេកទេសផ្ដោតលើការផលិតរបាយការណ៍ជាតិនេះ ដែលមានសមាសភាពពីក្រសួងផែនការ ក្រសួងអភិវឌ្ឍន៍ជនបទ និងតំណាងស្ថាប័នឱ្យជនជាតិដើមភាគតិច។

យោងតាមអនុសាសន៍ណែនាំខាងលើ ក្រុមការងារបច្ចេកទេសក៏បានបង្កើតឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០១៧ ដែលដឹកនាំសម្របសម្រួលដោយផ្ទាល់ពីក្រសួងផែនការ និងដែលមានការចូលរួមពីក្រសួងអភិវឌ្ឍន៍ជនបទ រួមទាំងតំណាងសម្ព័ន្ធជនជាតិដើមភាគតិច ក្រោមការចូលរួមគាំទ្រផ្នែកស្មារតីពីអង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និងការគាំទ្រផ្នែកហិរញ្ញវត្ថុពីមូលនិធិហែនរេចបូលរបស់អាល្លឺម៉ង់ (HBS) សម្ព័ន្ធជនជាតិដើមភាគតិចអាស៊ី (AIPP) អង្គការអុកស្វាមប្រចាំកម្ពុជា (Oxfam in Cambodia) អង្គការដៀកូនៀ (Diakonia) និងអង្គការជំនួយនៃប្រជាពលរដ្ឋន័រវេស្សន៍ (NPA) ប្រចាំប្រទេសកម្ពុជា តាមរយៈអង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) រួមទាំងមានការចូលរួមគាំទ្រដោយសកម្មផងដែរពី សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA) អង្គការសមាគមខ្មែរលើ (HA) អង្គការលើកស្ទួយវប្បធ៌មកួយ (OPKC) អង្គការលើកកម្ពស់ភាសាជនជាតិដើមភាគតិច (CIPL) សមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិច (IRAM) អង្គការអភិវឌ្ឍន៍កសិកម្មជនជាតិដើមភាគតិចនៅកម្ពុជា (IADC) និងសមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា (CIWA) រួមនឹងអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC)។

ជាលទ្ធផល ក្រុមការងារបច្ចេកទេសដែលដឹកនាំដោយផ្ទាល់ពីក្រសួងផែនការក៏បង្កើតបានជារបាយការណ៍ជាតិស្ដីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចមួយ ដែលសមស្របទៅតាមលទ្ធផលនៃការស្នើសុំពីបណ្ដាក្រសួង-ស្ថាប័នពាក់ព័ន្ធនានា អង្គការជាតិ និងអន្តរជាតិ រួមទាំងតំណាងជនជាតិដើមភាគតិច។ របាយការណ៍នេះ បានឆ្លងការពិគ្រោះយោបល់និងការឯកភាពលើទម្រង់ ខ្លឹមសារ និងចំណុចគោលសំខាន់ៗនៃរបាយការណ៍យោងតាមទិន្នន័យមានស្រាប់ សម្រាប់ការរៀបចំផែនការអភិវឌ្ឍជនជាតិដើមភាគតិចលើវិស័យពាក់ព័ន្ធ និងជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើបច្ចុប្បន្នភាពរបាយការណ៍ជាតិនាពេលអនាគត ឱ្យកាន់តែមានភាពពេញលេញនិងប្រសើរឡើងតាមទិន្នន័យមានថ្មី។

## ១.២. គោលបំណង

គោលបំណងនៃបង្កើតរបាយការណ៍ជាតិស្តីពី ***ស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា*** គឺដើម្បីបង្ហាញអំពីស្ថានភាពប្រជាសាស្ត្រ ស្ថានភាពសង្គម-សេដ្ឋកិច្ច និងការរស់នៅរបស់ជនជាតិដើមភាគតិច ដោយផ្អែកលើទិន្នន័យមានស្រាប់ក្នុងឆ្នាំ១៩៩៨ និង២០០៨ សម្រាប់ជាមូលដ្ឋានតម្រង់ទិសដល់ការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងការស្រាវជ្រាវបន្តដើម្បីបង្កើតជារបាយការណ៍ស៊េរី ផ្អែកតាមលទ្ធភាពនៃទិន្នន័យមានថ្មីនៅពេលខាងមុខ ដែលរបាយការណ៍នេះមានជារបាយការណ៍ទីមួយ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាព បន្ទាប់ពីមានទិន្នន័យជំរឿនឆ្នាំ២០១៩។

## ១.៣. ដែនកំណត់

របាយការណ៍នេះ ផ្តោតជាចម្បងទៅលើស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ប្រជាជននៃជនជាតិដើមភាគតិចក្នុងឆ្នាំ១៩៩៨ និង២០០៨ ដោយមានការប្រៀបធៀបអំពីបញ្ហាខ្លះៗទៅនឹងប្រជាជនកម្ពុជាទាំងមូល ដើម្បីយល់ពីស្ថានភាពជនជាតិដើមភាគតិចឱ្យបានកាន់តែច្បាស់។

កន្លងមក គ្មានការស្រាវជ្រាវដើម្បីចងក្រងទិន្នន័យកម្រិតជាតិជាក់លាក់អំពីជនជាតិដើមភាគតិចនៅកម្ពុជា ក្រៅពីជំរឿននិងអង្កេតមួយចំនួន ដែលធ្វើដោយក្រសួងផែនការ។ ដូច្នេះ របាយការណ៍នេះពឹងផ្អែកជាចម្បងទៅលើទិន្នន័យមានស្រាប់ ដែលបានពីជំរឿននិងអង្កេតទាំងនោះ ជាពិសេសគឺជំរឿនឆ្នាំ១៩៩៨និង២០០៨ និងអង្កេតចន្លោះជំរឿនឆ្នាំ២០១៣។ ទិន្នន័យអង្កេតប្រជាសាស្ត្រនិងសុខភាព ទិន្នន័យអង្កេតសង្គមកិច្ចសេដ្ឋកិច្ច និងទិន្នន័យរដ្ឋបាល ក៏បានបញ្ចូលក្នុងរបាយការណ៍នេះ ទៅតាមករណីពាក់ព័ន្ធ។

ការប្រើឈ្មោះអំបូរជនជាតិដើមភាគតិចនៅក្នុងរបាយការណ៍នេះ គឺយោងទៅតាមការអនុម័តរបស់កិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង រួមជាមួយតំណាងអង្គការជនជាតិដើមភាគតិចនៅកម្ពុជា ដែលបានសម្រេចយកតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាគោល។ ក្នុងករណីពុំមានឈ្មោះអំបូរជនជាតិដើមភាគតិចនៅក្នុងគោលនយោបាយនោះ ឈ្មោះអំបូរជនជាតិដើមភាគត្រូវយកតាមវចនានុក្រមសម្តេចជួន ណាត ឬតាមការឯកភាពគ្នារបស់ក្រុមការងារបច្ចេកទេសរួមជាមួយតំណាងអង្គការជនជាតិដើមភាគតិចនៅកម្ពុជា ។

យ៉ាងណាមិញ ទិន្នន័យដែលបានបង្ហាញក្នុងរបាយការណ៍ អាចនឹងមានចំណុចខ្វះខាតមួយចំនួនពាក់ព័ន្ធនឹងព័ត៌មានជនជាតិដើមភាគតិចធៀបនឹងស្ថានភាពជាក់ស្តែង ក៏ប៉ុន្តែរបាយការណ៍នេះក៏ជារបាយការណ៍បឋមនិងមូលដ្ឋានមួយក្នុងការចាប់ផ្តើម និងតម្រូវឲ្យមានការយកចិត្តទុកដាក់បន្តដើម្បីពិនិត្យ

និងរៀបចំផែនការលម្អិតបន្ថែម ដើម្បីធ្វើយ៉ាងណាឲ្យមានភាពកាន់តែប្រសើរ និងសុក្រឹត្យ នាពេលបង្កើតរបាយការណ៍ស៊េរីនាថ្ងៃអនាគត។

## ១.៤. វិធីសាស្ត្រ

ប្រភពទិន្នន័យចម្បងៗ សម្រាប់របាយកាណ៍នេះ មានជំរឿនប្រជាជន អង្កេតចន្លោះជំរឿន អង្កេតសង្គមកិច្ចសេដ្ឋកិច្ច អង្កេតប្រជាសាស្ត្រនិងសុខភាព អង្កេតសង្គមកិច្ចសេដ្ឋកិច្ច និងទិន្នន័យរដ្ឋបាលឃុំសង្កាត់ដែលអាចប្រើប្រាស់បាន។ លើកលែងតែមានការបញ្ជាក់បន្ថែម រាល់ទិន្នន័យគោលដែលប្រើក្នុងរបាយការណ៍នេះ មានប្រភពមកពីជំរឿនឆ្នាំ២០០៨ អង្កេតចន្លោះជំរឿនឆ្នាំ២០១៣ និងអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០១៤។

ការលំបាកមួយក្នុងការបង្កើតរបាយការណ៍នេះ គឺកង្វះទិន្នន័យដែលប្រមូលឡើងដើម្បីការសិក្សាអំពីជនជាតិដើមភាគតិច។ ដូច្នេះ របាយការណ៍នេះ ត្រូវពឹងផ្អែកទាំងស្រុងលើទិន្នន័យពីប្រភពនានាដូចបានរៀបរាប់នៅខាងដើម ដែលទិន្នន័យទាំងនោះប្រមូលឡើងក្នុងគោលបំណងផ្សេងៗគ្នា និងដែលមានចំណុចខ្វះខាតរៀងៗខ្លួន ក្នុងការយកមកប្រើប្រាស់ដើម្បីសិក្សាបង្កើតរបាយការណ៍នេះ។

ចំណុចទីមួយគឺពេលខុសៗគ្នា គោលបំណងខុសៗគ្នា ប្រភេទស្រាវជ្រាវខុសៗគ្នា និងប្រើប្រាស់សំណាកគំរូខុសៗគ្នា ដែលគ្មានទិន្នន័យណាមួយ (ក្រៅពីជំរឿន) រៀបចំឡើងដោយមានប្រមូលទិន្នន័យអំពីជនជាតិដើមភាគតិច។ ទិន្នន័យដែលបានពីអង្កេតទាំងអស់ ផ្អែកលើការជ្រើសរើសសំណាកគំរូតាមវិធីប្រូបាប តែមិនបញ្ចូលក្រុមជនជាតិដើមភាគតិចទៅក្នុងវិធីនៃការរើសសំណាកទេ ដែលនាំឱ្យចំនួនជនជាតិដើមភាគតិចដែលបានសម្ភាសន៍ អាចមិនតំណាងឱ្យជនជាតិដើមភាគតិចទាំងអស់នៅកម្ពុជា។

ចំណុចទីពីរគឺនិយមន័យជនជាតិដើមភាគតិច។ ជំរឿននិងអង្កេតចន្លោះជំរឿន ប្រើប្រាស់សំណួរអំពីភាសាកំណើត សម្រាប់សម្គាល់ជាតិសាសន៍និងជាតិពន្ធុនានាដែលរស់នៅក្នុងប្រទេសកម្ពុជា។ អង្កេតសង្គមកិច្ចសេដ្ឋកិច្ច ជាអង្កេតដែលផ្តល់ទិន្នន័យសម្បូរបែបជាងគេ ប្រើប្រាស់សំណួរអំពីជាតិសាសន៍និងជនជាតិនានា តាមរយៈការបែងចែកប្រជាជនដែលរស់នៅកម្ពុជា ជាជនជាតិខ្មែរនិងជនជាតិដទៃទៀត ដែលក្នុងចំណោមជនជាតិដទៃ មានក្រុមជនជាតិភាគតិចដទៃទៀតនៅក្នុងស្រុក តែមិនបានបំបែកចេញជាអំបូរជនជាតិដើមភាគតិចទេ។ អង្កេតប្រជាសាស្ត្រសុខភាព គ្មានទិន្នន័យអំពីជនជាតិដើមភាគតិចទេ។ ទិន្នន័យឃុំ/សង្កាត់ ជាទិន្នន័យផ្តុំ (Aggregated data) ប្រមូលដោយមេភូមិនិងចងក្រងនៅថ្នាក់ឃុំ/សង្កាត់ ក្នុងគោលបំណងបង្កើតជាព័ត៌មានសម្រាប់ជួយដល់ការធ្វើផែនការអភិវឌ្ឍន៍ថ្នាក់ឃុំ/សង្កាត់ និងមានទិន្នន័យរួមអំពីចំនួនជនជាតិដើមភាគតិច។

ចំណុចទីបីគឺការប្រៀបធៀបគ្នា និងការវិភាគលម្អិត។ ទិន្នន័យដែលមានគោលបំណងខុសៗគ្នា ប្រភេទស្រាវជ្រាវខុសៗគ្នា និងប្រើប្រាស់សំណាកគំរូខុសៗគ្នា ពិបាកនឹងធ្វើការប្រៀបធៀបគ្នាដើម្បីពិនិត្យមើលការប្រែប្រួលពីពេលមួយទៅពេលមួយទៀត។ ដូចនេះ ការប្រៀបធៀបការប្រែប្រួលរវាងឆ្នាំ២០០៨ និងឆ្នាំ២០១៣ អាចពុំមានលក្ខណៈសុក្រឹត។

# ២. ស្ថានភាពប្រជាសាស្ត្ររបស់ជនជាតិដើមភាគតិច

ជនជាតិដើមភាគតិចនៅក្នុងរបាយការណ៍នេះ សំដៅលើជនជាតិដើមដែលកើតនិងរស់នៅលើតំបន់នានាក្នុងទឹកដីកម្ពុជាតាំងពីយូរមកហើយ។ ជនជាតិភាគតិចដទៃទៀតដែលរស់នៅក្នុងប្រទេសកម្ពុជា ដូចជា វៀតណាម ថៃ ឡាវ កូរ៉េ ចិន។ល។ ជាជាតិសាសន៍ដទៃទៀត ដែលមិនរាប់ជាជនជាតិដើមភាគតិចក្នុងរបាយការណ៍នេះទេ។ ផ្អែកតាមទិន្នន័យដែលមាន ពិសេសទិន្នន័យជំរឿន ជនជាតិដើមភាគតិចត្រូវបានកំណត់តាមរយៈភាសានិយាយពីកំណើត ដែលខុសពីភាសាខ្មែរនិងភាសាជាតិសាសន៍ដទៃទៀត ហើយរបាយការណ៍នេះកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចតាម និយមន័យរបស់ជំរឿន។

## ២.១. ចំនួននិងអំបូរជនជាតិដើមភាគតិច

យោងតាមជំរឿនប្រជាជនឆ្នាំ២០០៨ ជនជាតិដើមភាគតិចនៅកម្ពុជាមានចំនួន២២អំបូរ (តារាងទី១) ដែលមានចំនួន ១៧៩.១៩៣នាក់ ស្មើនឹង ១,៣៤% នៃប្រជាជនកម្ពុជាសរុប។ នៅឆ្នាំ២០១៣ ជនជាតិដើមភាគតិចនៅកម្ពុជាមានចំនួន ១៨៣.៨៣១នាក់ ស្មើនឹង១,២៥% នៃប្រជាជនកម្ពុជាសរុប[១]។ ក្នុងចន្លោះពេល៥ឆ្នាំនេះ កំណើនប្រជាជនជនជាតិដើមភាគតិច មានតែ០,៥១% ក្នុងមួយឆ្នាំប៉ុណ្ណោះ ដែលជាកំណើនប្រជាជនក្នុងទំហំមួយដ៏ទាប ធៀបនឹងកំណើនប្រជាជនកម្ពុជាសរុប ដែលមានកំណើនចំនួន ១,៥%ក្នុងមួយឆ្នាំក្នុងចន្លោះពេលដូចគ្នា។

**តារាងទី១. ចំនួនប្រជាជននិងអំបូរជនជាតិដើមភាគតិច និងអត្រាកំណើនប្រចាំឆ្នាំ**

| | ឆ្នាំ២០០៨ | ឆ្នាំ២០១៣ | អត្រាកំណើន[១] (%) |
|---|---|---|---|
| ចំនួនប្រជាជនកម្ពុជាសរុប | ១៣.៣៩៥.៦៨២ | ១៤.៦៧៦.៥៩១ | ១,៥៤ |
| ចំនួនជនជាតិដើមភាគតិចសរុប | ១៧៩.១៩៣ | ១៨៣.៨៣១ | ០,៥១ |
| ភាគរយជនជាតិដើមភាគតិច | ១,៣៤ | ១,២៥ | |
| ចំនួនអំបូរជនជាតិដើមភាគតិច | ២២ | ២២ | |

[១] អត្រាកំណើនប្រជាជនសរុប ត្រូវបានគណនាដោយបញ្ចូលចំនួនប្រជាជនដែលរាប់ខ្វះនៅឆ្នាំ២០០៨។

[១] យោងតាមទិន្នន័យ CDB ឆ្នាំ២០១៤ ជនជាតិដើមភាគតិចមានចំនួន ២៥២.៣៣៧នាក់ ដែលចំនួននេះ ហាក់ខុសឆ្ងាយពីចំនួននៅឆ្នាំ២០១៣។ យោងតាមទិន្នន័យអង្កេតសង្គម-សេដ្ឋកិច្ច ដែលចែកប្រជាជននៅកម្ពុជាជាជនជាតិផ្សេងទៀត ជនជាតិភាគតិចក្នុងស្រុកមានចំនួន ២៤៣.៣៥៧នាក់ នៅឆ្នាំ២០១៥។ នេះបញ្ជាក់ឱ្យឃើញថា ប្រភពទិន្នន័យទាំងអស់ផ្តល់ទិន្នន័យផ្សេងៗគ្នា ហើយប្រជាជនជនជាតិដើមភាគតិចនៅឆ្នាំ២០១៣អាចរាប់ខ្វះ។ បើយកទិន្នន័យCSESឆ្នាំ២០១៥ជាចំណុចដៅនោះអត្រាកំណើនប្រជាជនពីឆ្នាំ២០០៨ដល់២០១៥មានដល់ទៅ៤,៤%ក្នុងមួយឆ្នាំ។

### ២.១.១. ចំនួនជនជាតិដើមភាគតិចតាមអំបូរនីមួយៗ

ក្នុងចំណោមអំបូរជនជាតិដើមភាគតិចទាំង២២អំបូរ អំបូរជនជាតិដើមភាគតិចធំៗ ដែលមានប្រជាជនច្រើនជាង១ម៉ឺននាក់ មានតែ៦អំបូរប៉ុណ្ណោះ ដែលជាចំនួនសរុប ប្រជាជននៃជនជាតិដើមភាគតិចទាំង៦អំបូរនេះ មានចំនួនស្មើនឹង៨៨%នៃប្រជាជនជនជាតិដើមភាគតិចទាំង២២អំបូរ (ឆ្នាំ២០១៣)។ អំបូរទាំងនោះគឺ៖

១) ជនជាតិទំពួនមានចំនួន ៥១.៩៤៧ នាក់

២) ជនជាតិព្នង មានចំនួន ៤៧.២៩៦ នាក់

៣) ជនជាតិគ្រឹង មានចំនួន ២២.៣៨៥ នាក់

៤) ជនជាតិកួយ មានចំនួន ១៣.៥៣០ នាក់

៥) ជនជាតិចារាយ មានចំនួន ១៣.៣២៦ នាក់ និង

៦) ជនជាតិព្រៅ មានចំនួន១៣.៩០២ នាក់។

រីឯអំបូរជនជាតិដើមភាគតិចដែលមានចំនួនប្រជាជនតិចជាង១ពាន់នាក់ក្នុងមួយអំបូរ មានចំនួន ១០អំបូរ គឺល្មូន សួយ ខោញ គ្លឹង ស្ទួច កាវ្រួក លុន រដែ មន និងកាចក់ ដែលមានប្រជាជនសរុបត្រឹម ៤ ៣៩៧នាក់ប៉ុណ្ណោះ ស្មើនឹង២,៤៥%នៃប្រជាជនជនជាតិដើមភាគតិចទាំងអស់។ ក្នុងពេលបច្ចុប្បន្នក្នុងរបាយការណ៍នេះអ្នកវិភាគមិនអាចបញ្ជាក់អំពីវត្តមាន និងភូមិសាស្ត្រជនជាតិដើមមួយចំនួនដូចជា ល្មូន ការវ្រួក លុន រដែរ និងមននៅឡើយទេ។

## តារាងទី២. ចំនួនជនជាតិដើមភាគតិចតាមអំបូរនីមួយៗ

| ចំនួនជនជាតិដើមភាគតិចតាមអំបូរ | | | | |
|---|---|---|---|---|
| អំបូរជនជាតិដើមភាគតិច | | ឆ្នាំ២០០៨ | ឆ្នាំ២០១៣ | បម្រែបម្រួល |
| ១ | ព្នង | ៣៧.៥០៧ | ៤៧.២៩៦ | ៩.៧៨៩ |
| ២ | ទំពួន | ៣១.០១៣ | ៥១.៩៤៧ | ២០.៩៣៤ |
| ៣ | កួយ | ២៨.៦១២ | ១៣.៥៣០ | -១៥.០៨២ |
| ៤ | ចារាយ | ២៦.៣៣៥ | ១៣.៣២៦ | -១៣.០០៩ |
| ៥ | គ្រឹង | ១៩.៩៨៨ | ២២.៣៨៥ | ២.៣៩៧ |
| ៦ | ព្រៅ | ៩.០២៥ | ១៣.៩០២ | ៤.៨៧៧ |
| ៧ | ស្ទៀង | ៦.៥៤១ | ១.២៧៩ | -៥.២៦២ |
| ៨ | កាវ៉ែត | ៦.២១៨ | ៥.៦១៨ | -៦០០ |
| ៩ | ក្រោល | ៤.២០២ | ៧.៤១៣ | ៣.២១១ |
| ១០ | ចាអុង | ១.៨៣១ | ២៦៦ | -១.៥៦៥ |
| ១១ | ព័រ | ១.៨២៧ | ២១៥ | -១.៦១២ |
| ១២ | មិល | ១.៦៩៧ | ១.៩០៥ | ២០៨ |
| ១៣ | ល្មូន | ៨៦៥ | ៧៦៣ | -១០២ |
| ១៤ | ស្អូយ | ៨៥៧ | ០ | -៨៥៧ |
| ១៥ | ខោញ | ៧៤៣ | ២៧០ | -៤៧៣ |
| ១៦ | គ្លឹង | ៧០២ | ២០៨ | -៤៩៤ |
| ១៧ | ស្អូច | ៤៤៥ | ៨៣៧ | ៣៩២ |
| ១៨ | កាជ្រូក | ៤០៨ | ៧៣១ | ៣២៣ |
| ១៩ | លុន | ៣២៧ | ៤៣៦ | ១០៩ |
| ២០ | រដែ | ២១ | ១.០០៣ | ៩៨២ |
| ២១ | មន | ១៩ | ១៧៤ | ១៥៥ |
| ២២ | កាចក់ | ១០ | ៣២៨ | ៣១៨ |
| | សរុប | ១៧៩.១៩៣ | ១៨៣.៨៣២ | ៤.៦៣៩ |

## ២.១.២. ចំនួនអំបូរជនជាតិដើមភាគតិចនៅតាមខេត្តនីមួយៗ

ជនជាតិដើមភាគតិចកម្ពុជា ច្រើនមានប្រភពមកពីភាគខាងជើងនិងខាងកើតនៃប្រទេសកម្ពុជា។ បច្ចុប្បន្ន ជនជាតិដើមភាគតិចរស់នៅមានលក្ខណៈរាយប៉ាយជាងមុន គឺគេឃើញមានរស់នៅស្ទើរគ្រប់ខេត្តក្រុង។ ក្រាហ្វិកទិ១ តារាងទី៣ និងតារាងទី៤ខាងក្រោម បង្ហាញពីចំនួនអំបូរជនជាតិដើមភាគតិច នៅតាមខេត្តនីមួយៗ ដោយគិតទៅតាមចំនួនប្រជាជនជា៣ប្រភេទ៖ ក) ក្រាហ្វិកទី១ បង្ហាញពីខេត្តនិងចំនួនអំបូរជនជាតិដើមភាគភាគតិចដែលមានប្រជាជនយ៉ាងតិច១.០០០នាក់តាមអំបូរក្នុងខេត្តនីមួយៗ ខ)តារាងទី៣ បង្ហាញពីអំបូរជនជាតិដើមភាគតិចដែលមានចំនួនប្រជាជនពី១០០នាក់ដល់ក្រោម១.០០០នាក់ក្នុងអំបូរនីមួយៗក្នុងខេត្តនីមួយៗ និង គ) តារាងទី៤បង្ហាញពីអំបូរជនជាតិដើមភាគតិចតូចៗ ដែលមានចំនួនប្រជាជនជនជាតិក្នុងខេត្តដែលអំបូរនីមួយៗមានចំនួនតិចជាង១០០នាក់។ គួរកត់សម្គាល់ថា ចំនួនសរុបនៃប្រជាជនជនជាតិដើមនីមួយៗនៅក្នុងខេត្ត មិនបានរាប់បញ្ចូលក្នុងការបែងចែកនេះឡើយ។

### ក. ចំនួនអំបូរដែលមានចំនួនប្រជាជនយ៉ាងតិច១.០០០នាក់នៅក្នុងខេត្ត

ក្រាហ្វិកទី១ បង្ហាញថា អំបូរជនជាតិដើមភាគតិចដែលមានចំនួនប្រជាជនយ៉ាងតិច១.០០០ក្នុងអំបូរនីមួយៗ មាននៅក្នុងខេត្តចំនួន៦ប៉ុណ្ណោះ។ ខេត្តរតនគិរី និងខេត្តក្រចេះ មានជនជាតិដើមភាគតិចចំនួន៥អំបូរផ្សេងៗពីគ្នា៖ ខេត្តរតនគិរី មានជនជាតិចារាយ កាវ៉ែត គ្រឹង ព្រៅ និងទំពួន ឯខេត្តក្រចេះមានជនជាតិកួយ ព្នង ស្ទៀង ក្រោល និងមិល។ ខេត្តព្រះវិហារមាន២អំបូរ គឺជនជាតិកួយនិងព័រ។ ខេត្តស្ទឹងត្រែងមាន២អំបូរ គឺជនជាតិកាវ៉ែតនិងកួយ។ ឯខេត្តកំពង់ធំ មានជនជាតិកួយ និងខេត្តមណ្ឌលគិរីមានជនជាតិព្នង។

### ខ. ចំនួនអំបូរដែលមានចំនួនប្រជាជនពី១០០នាក់ទៅ៩៩៩នាក់នៅក្នុងខេត្ត

គិតតាមចំនួនប្រជាជនជនជាតិដើមភាគតិចចំនួនពី១០០នាក់ទៅដល់ចំនួនក្រោម១.០០០នាក់តាមអំបូរនីមួយៗ រាជធានី-ខេត្តដែលមានចំនួនអំបូរច្រើនជាងគេ គឺ ១) រាជធានីភ្នំពេញ ដែលមាន៥អំបូរ គឺចារាយ កាវ៉ែត គ្លឹង ស្ទៀង និង ចាអុង ២) ខេត្តស្ទឹងត្រែងមានចំនួន៤អំបូរគឺគ្រឹង លុន ព្នង និង ព្រៅ ៣) ខេត្តកំពង់ចាមមាន៤អំបូរ គឺចារាយ កាវ៉ែត ស្ទៀង និង ចាអុង និង ៤) ខេត្ត កណ្ដាលមាន៤អំបូរ គឺចារាយ គ្លឹង ស្ទៀង និង ចាអុង។ ខេត្តក្រចេះ មណ្ឌលគិរី បាត់ដំបង ព្រៃវែង និងសៀមរាប មាន៣អំបូរជនជាតិក្នុងខេត្តនីមួយៗ។ ខេត្តកំពង់ស្ពឺ កំពត ពោធិ៍សាត់ និងតាកែវ មាន២អំបូរជនជាតិក្នុងខេត្តនីមួយៗ។ ខេត្តរតនគិរី ព្រះវិហារ កំពង់ធំ បន្ទាយមានជ័យ កំពង់ឆ្នាំង ព្រះសីហនុ និងស្វាយរៀង មានតែមួយអំបូរប៉ុណ្ណោះ។ តាមទិន្នន័យនេះ (តារាងទី៣) គេសង្កេតឃើញថា ជនជាតិចារាយ មានរស់នៅសឹងគ្រប់រាជធានីខេត្ត ចំនួនពី១០០នាក់ ទៅ៩៩៩នាក់ ក្នុងរាជធានីខេត្តនីមួយៗ។

**ក្រាហ្វិកទី១.	ខេត្តនិងចំនួនអំបូរជនជាតិដែលមានប្រជាជនយ៉ាងតិច១.០០០នាក់**




**គ. ចំនួនអំបូរដែលមានចំនួនប្រជាជនតិចជាង១០០នាក់នៅក្នុងខេត្ត**

តារាងទី៤ខាងក្រោម បង្ហាញថា គ្រប់រាជធានីខេត្តសុទ្ធតែមានជនជាតិដើមភាគតិចរស់នៅយ៉ាងតិច ៤ទៅ៥អំបូរ ដែលក្នុងមួយអំបូរៗមានចំនួនក្រោម១០០នាក់។ ដោយឡែក រាជធានីភ្នំពេញនិងខេត្តកណ្ដាលមានចំនួនអំបូរច្រើនជាងគេ គឺ១៥អំបូរនិង១៣អំបូរ រៀងគ្នា។

ចំនួនតិចតួចនៃជនជាតិដើមភាគតិច ដែលរស់នៅក្នុងរាជធានីខេត្ត ក្រៅពីខេត្តនៅក្នុងក្រាហ្វិកទី១ និងតារាងទី៣ខាងលើ អាចបណ្ដាលមកពីការចូលមកធ្វើការងារឬរៀបការជាមួយប្រជាជនខ្មែរឬជនជាតិផ្សេងទៀត។

### តារាងទី៣. ចំនួនអំបូរជនជាតិដើមភាគតិចដែលមានប្រជាជនយ៉ាងតិច១០០នាក់

| ល.រ | រាជធានី/ខេត្ត | ឈ្មោះអំបូរជនជាតិដើមភាគតិច | ចំនួនអំបូរ |
|---|---|---|---|
| ១ | ភ្នំពេញ | ចារាយ កាវ៉ែត គ្លឹង ស្ទៀង ចាអុង | ៥ |
| ២ | ស្ទឹងត្រែង | គ្រឹង លុន ព្នង ព្រៅ | ៤ |
| ៣ | កំពង់ចាម | ចារាយ កាវ៉ែត ស្ទៀង ចាអុង | ៤ |
| ៤ | កណ្តាល | ចារាយ គ្លឹង ស្ទៀង ចាអុង | ៤ |
| ៥ | ក្រចេះ | ចារាយ ល្មូន ខោញ | ៣ |
| ៦ | មណ្ឌលគិរី | ស្ទៀង ក្រោល ល្មូន | ៣ |
| ៧ | បាត់ដំបង | ចារាយ ស្ទៀង ចាអុង | ៣ |
| ៨ | ព្រៃវែង | ចារាយ ស្ទៀង ចាអុង | ៣ |
| ៩ | សៀមរាប | ចារាយ ស្ទៀង ចាអុង | ៣ |
| ១០ | កំពង់ស្ពឺ | ចារាយ សួយ | ២ |
| ១១ | កំពត | ចារាយ ចាអុង | ២ |
| ១២ | ពោធិ៍សាត់ | ចារាយ ព័រ | ២ |
| ១៣ | តាកែវ | ចារាយ ចាអុង | ២ |
| ១៤ | រតនគិរី | ព្នង | ១ |
| ១៥ | ព្រះវិហារ | ចារាយ | ១ |
| ១៦ | កំពង់ធំ | ចារាយ | ១ |
| ១៧ | បន្ទាយមានជ័យ | ចារាយ | ១ |
| ១៨ | កំពង់ឆ្នាំង | ចារាយ | ១ |
| ១៩ | ព្រះសីហនុ | ចារាយ | ១ |
| ២០ | ស្វាយរៀង | ចារាយ | ១ |

## តារាងទី៤. ចំនួនអំបូរជនជាតិដើមភាគតិចដែលមានប្រជាជនតិចជាង១០០នាក់

| ល.រ | រាជធានីខេត្ត | ឈ្មោះអំបូរជនជាតិដើមភាគតិច | ចំនួនអំបូរ |
|---|---|---|---|
| ១ | ភ្នំពេញ | កួយ គ្រឹង លុន ពួង ព្រៅ ទំពួន ក្រោល រដែ ល្មូន មិល សួយ ស្អូច កាជ្រុក មន កាចក់ | ១៥ |
| ២ | កណ្ដាល | កាវ៉ែត កួយ លុន ពួង ព្រៅ ទំពួន ក្រោល រដែ ល្មូន សួយ ស្អូច កាជ្រុក មន | ១៣ |
| ៣ | កំពង់ឆ្នាំង | កាវ៉ែត គ្លឹង កួយ គ្រឹង លុន ទំពួន ស្ទៀង ចាអុង ក្រោល រដែ ស្អូច កាជ្រុក | ១២ |
| ៤ | ព្រះសីហនុ | កាវ៉ែត គ្លឹង កួយ គ្រឹង ព្រៅ ទំពួន ស្ទៀង ចាអុង ក្រោល មិល ស្អូច កាជ្រុក | ១២ |
| ៥ | ព្រះវិហារ | កាវ៉ែត គ្លឹង ពួង ព្រៅ ទំពួន ស្ទៀង ចាអុង ក្រោល ល្មូន ស្អូច កាជ្រុក | ១១ |
| ៦ | បាត់ដំបង | កាវ៉ែត គ្លឹង កួយ គ្រឹង ពួង ក្រោល ល្មូន សួយ ស្អូច កាជ្រុក | ១០ |
| ៧ | កំពង់ចាម | គ្លឹង កួយ ពួង ព្រៅ ក្រោល រដែ មិល ស្អូច កាជ្រុក មន | ១០ |
| ៨ | កំពង់ស្ពឺ | កាវ៉ែត គ្លឹង កួយ គ្រឹង លុន ស្ទៀង ចាអុង ក្រោល ស្អូច កាជ្រុក | ១០ |
| ៩ | មណ្ឌលគិរី | ចារាយ កាវ៉ែត កួយ គ្រឹង ព្រៅ ទំពួន ចាអុង មិល ស្អូច កាជ្រុក | ១០ |
| ១០ | បន្ទាយមានជ័យ | កាវ៉ែត គ្លឹង កួយ ព្រៅ ស្ទៀង ចាអុង ក្រោល ស្អូច កាជ្រុក | ៩ |
| ១១ | កំពត | កាវ៉ែត គ្លឹង កួយ លុន ពួង ស្ទៀង ខោញ ស្អូច កាជ្រុក | ៩ |
| ១២ | ក្រចេះ | កាវ៉ែត គ្លឹង លុន ព្រៅ ចាអុង ព័រ សួយ ស្អូច កាជ្រុក | ៩ |
| ១៣ | ពោធិសាត់ | កាវ៉ែត គ្លឹង កួយ គ្រឹង ស្ទៀង ចាអុង ក្រោល ស្អូច កាជ្រុក | ៩ |
| ១៤ | សៀមរាប | កាវ៉ែត គ្លឹង កួយ គ្រឹង ពួង ក្រោល ស្អូច កាជ្រុក មន | ៩ |
| ១៥ | ឧត្តរមានជ័យ | ចារាយ កាវ៉ែត គ្លឹង កួយ ពួង ស្ទៀង ចាអុង ស្អូច កាជ្រុក | ៩ |
| ១៦ | រតនគិរី | គ្លឹង កួយ លុន ស្ទៀង ចាអុង ក្រោល ល្មូន សួយ | ៨ |
| ១៧ | ស្វាយរៀង | កាវ៉ែត គ្លឹង កួយ ស្ទៀង ចាអុង ស្អូច កាជ្រុក កាចក់ | ៨ |
| ១៨ | តាកែវ | កាវ៉ែត គ្លឹង កួយ ពួង ស្ទៀង ល្មូន ស្អូច កាជ្រុក | ៨ |
| ១៩ | កំពង់ធំ | កាវ៉ែត គ្លឹង ពួង ស្ទៀង ចាអុង ស្អូច កាជ្រុក | ៧ |
| ២០ | ព្រៃវែង | កាវ៉ែត គ្លឹង កួយ ក្រោល រដែ ស្អូច កាជ្រុក | ៧ |
| ២១ | កោះកុង | ចារាយ កាវ៉ែត ស្ទៀង ចាអុង ស្អូច កាជ្រុក | ៦ |
| ២២ | ស្ទឹងត្រែង | ចារាយ គ្លឹង ទំពួន ស្ទៀង ចាអុង ស្អូច | ៦ |
| ២៣ | ប៉ៃលិន | ចារាយ គ្លឹង កួយ ស្ទៀង ចាអុង | ៥ |
| ២៤ | កែប | ចារាយ កាវ៉ែត ស្ទៀង ស្អូច | ៤ |

### ២.១.៣. របាយភាគរយនៃជនជាតិដើមភាគតិចតាមខេត្តនីមួយៗ តាមអំបូរជនជាតិ

របាយតាមខេត្តទាំងអស់ ត្រូវបានដាក់ចូលក្នុងឧបសម្ព័ន្ធ។ តារាងខាងក្រោម បង្ហាញពីរាជធានីខេត្តចំនួន៣ ដែលមានអំបូរជនជាតិដើមនីមួយៗរស់នៅច្រើនជាងគេ យោងតាមទិន្នន័យអង្កេតចន្លោះជំរឿនឆ្នាំ២០១៣។ ជាឧទាហរណ៍ ៦៩,៥%នៃជនជាតិចារាយរស់នៅក្នុងខេត្តរតនៈគិរី ៥,៦%នៅរាជធានីភ្នំពេញ និង៤,៨%នៅខេត្តសៀមរាប ដែលសរុបជនជាតិចារាយនៅក្នុងខេត្តទាំង៣មានចំនួនស្មើនឹង ៧៩,៩% នៃជនជាតិចារាយទាំងអស់។

**តារាងទី៥. ចំនួននិងភាគរយជនជាតិដើមភាគតិចក្នុងរាជធានីខេត្តចំនួន៣ដែលមានចំនួនច្រើនជាងគេតាមអំបូរនីមួយៗ**

| | សរុបក្នុងខេត្តទាំង៣ | | របាយតាមខេត្តទាំង៣ | | | | | |
|---|---|---|---|---|---|---|---|---|
| អំបូរ | ចំនួន | % | ខេត្ត | % | ខេត្ត | % | ខេត្ត | % |
| កួយ | 13,53 | 99.9% | កំពង់ធំ | 53.9% | ព្រះវិហារ | 45.3% | ក្រចេះ | 0.6% |
| គ្រឹង | 22,385 | 99.8% | រតនៈគិរី | 98.0% | ស្ទឹងត្រែង | 1.0% | ត្បូងឃ្មុំ | 0.8% |
| ទំពួន | 51,947 | 99.4% | រតនៈគិរី | 98.3% | ស្ទឹងត្រែង | 0.7% | ព្រៃវែង | 0.5% |
| ពូនង | 47,296 | 97.9% | មណ្ឌលគិរី | 78.8% | ក្រចេះ | 18.2% | ព្រៃវែង | 0.9% |
| ក្រោល | 7,413 | 96.8% | ក្រចេះ | 61.4% | មណ្ឌលគិរី | 32.1% | បាត់ដំបង | 3.3% |
| កាវែត | 5,618 | 96.3% | ស្ទឹងត្រែង | 87.4% | កំពង់ស្ពឺ | 5.4% | កំពង់ឆ្នាំង | 3.5% |
| ព្រៅ | 13,902 | 93.4% | រតនៈគិរី | 70.8% | ស្ទឹងត្រែង | 20.9% | កំពង់ចាម | 1.7% |
| ល្មូន | 763 | 92.8% | មណ្ឌលគិរី | 62.3% | តាកែវ | 19.9% | កំពង់ស្ពឺ | 10.6% |
| ស្អូច | 837 | 92.5% | កំពង់ចាម | 45.5% | ភ្នំពេញ | 23.8% | តាកែវ | 23.2% |
| មិល | 1,905 | 87.3% | ក្រចេះ | 39.4% | ត្បូងឃ្មុំ | 37.5% | សៀមរាប | 10.4% |
| កាជ្រូក | 731 | 86.2% | តាកែវ | 39.8% | ព្រៃវែង | 25.2% | កណ្ដាល | 21.2% |
| ចាអុង | 266 | 81.9% | តាកែវ | 57.1% | ស្ទឹងត្រែង | 14.2% | ក្រចេះ | 10.6% |
| ចារ៉ាយ | 13,326 | 79.9% | រតនៈគិរី | 69.5% | ភ្នំពេញ | 5.6% | សៀមរាប | 4.8% |
| ស្ទៀង | 1,279 | 76.1% | មណ្ឌលគិរី | 30.9% | កំពង់ស្ពឺ | 29.5% | បាត់ដំបង | 15.7% |
| រដែ | 1,003 | 74.7% | ភ្នំពេញ | 33.8% | កំពង់ស្ពឺ | 25.6% | បាត់ដំបង | 15.3% |
| គ្លឹង | 208 | 100.0% | រតនៈគិរី | 100.0% | - | 0 | - | 0 |
| លន់ | 436 | 100.0% | សៀមរាប | 94.8% | រតនៈគិរី | 5.2% | - | 0 |
| ខោញ | 270 | 100.0% | ភ្នំពេញ | 71.7% | ឧត្តរមានជ័យ | 16.3% | ស្ទឹងត្រែង | 12.0% |
| ព័រ | 215 | 100.0% | កំពង់ស្ពឺ | 54.5% | កំពត | 39.6% | មណ្ឌលគិរី | 5.9% |
| មន | 174 | 100.0% | ព្រៃវែង | 100.0% | - | 0 | - | 0 |
| កាចក់ | 328 | 100.0% | ភ្នំពេញ | 85.0% | ព្រះសីហនុ | 15.0% | - | 0 |

### ២.១.៤. ចំនួនភូមិដែលមានជនជាតិដើមភាគតិចរស់នៅ

ទិន្នន័យជំរឿនឆ្នាំ២០០៨ អាចយកមកប្រើដើម្បីស្វែងរកស្រុកភូមិដែលជនជាតិដើមភាគតិចរស់នៅ។ ទិន្នន័យនេះបង្ហាញថា មានជនជាតិភាគតិចនៅរាយប៉ាយតាមភូមិនានាជាច្រើន រហូតដល់ចំនួន ៥២៦៣ភូមិ ដែលក្នុងនោះ មានភូមិជាច្រើនមិនមែនជាភូមិជនជាតិដើមភាគតិច តែមានជនជាតិដើមភាគតិចតិចតួចរស់នៅ (ភាគច្រើនពី១ទៅ៥នាក់ប៉ុណ្ណោះក្នុងមួយភូមិ)។ ការរាយប៉ាយនៃជនជាតិដើមភាគតិចក្នុងភូមិទាំងនេះ អាចមកពីកត្តាជាច្រើន ដូចជាការចូលទៅធ្វើការងារ ការទៅរៀនសូត្រ ការរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិផ្សេងជាដើម។

ផ្អែកលើមូលហេតុខាងលើ ការរាប់ចំនួនភូមិដែលមានជនជាតិដើមភាគតិចរស់នៅ គិតចាប់ពីភូមិដែលមានជនជាតិដើមភាគតិចរស់នៅយ៉ាងតិច១០នាក់ក្នុងមួយភូមិ។ បើរាប់ភូមិដែលមានជនជាតិដើមភាគតិចរស់នៅចាប់ពី១០នាក់ឡើងទៅក្នុងមួយភូមិ ចំនួនភូមិដែលជនជាតិដើមភាគតិចរស់នៅ មានចំនួន ៥៤២ភូមិ នៅក្នុង២២ខេត្តនៃប្រទេសកម្ពុជា ដែលគិតជាសរុប មានជនជាតិដើមភាគតិចចំនួន ១៦៩ ២៤៨នាក់ រស់នៅក្នុងភូមិទាំង៥៤២ភូមិ (តារាងទី៦)។

នេះមានន័យថា មានជនជាតិដើមភាគតិចចំនួនជិត១ម៉ឺននាក់ទៀត រស់នៅរាយប៉ាយក្នុងភូមិចំនួន ៤៦៩១ភូមិទៀត ដែលភូមិដែលមានជនជាតិដើមភាគតិចតែម្នាក់រស់នៅក្នុងភូមិនីមួយៗមានចំនួន ២៥២២ភូមិ (ចំនួន២៥២២នាក់) ភូមិដែលមានជនជាតិដើមភាគតិចតែ២នាក់រស់នៅក្នុងភូមិនីមួយៗ មានចំនួន៩៨៤ភូមិ (ចំនួន១៩៦៨នាក់) ភូមិដែលមានជនជាតិដើមភាគតិចតែ៣នាក់រស់នៅក្នុងភូមិនីមួយៗមានចំនួន៤៧៩ភូមិ (ចំនួន១៤៣៧នាក់) ភូមិដែលមានជនជាតិដើមភាគតិចតែ៤នាក់រស់នៅក្នុងភូមិនីមួយៗមានចំនួន២៦៧ភូមិ (ចំនួន១០៦៨នាក់)។ល។

**តារាងទី៦. ខេត្ត/ស្រុក/ឃុំ/ភូមិ ដែលមានជនជាតិដើមភាគតិច ១០នាក់/១ភូមិឡើងទៅ**

| ខេត្ត/រាជធានី | ចំនួនស្រុក | ចំនួនឃុំ | ចំនួនភូមិ | ចំនួនជនជាតិដើមភាគតិច |
|---|---:|---:|---:|---:|
| រតនគិរី | ៩ | ៤៤ | ១៩២ | ៨២.៧២៨ |
| មណ្ឌលគិរី | ៥ | ២១ | ៧៧ | ២៨.៦៩៤ |
| ក្រចេះ | ៤ | ១៩ | ៦២ | ២៥.៣៩៧ |
| ព្រះវិហារ | ៧ | ២២ | ៤៩ | ១៩.២៣២ |
| ស្ទឹងត្រែង | ៥ | ១៤ | ២៨ | ៦.១៣៣ |
| កំពង់ធំ | ៥ | ១១ | ២០ | ៤.១៤៧ |
| កំពង់ស្ពឺ | ២ | ២ | ៦ | ៨៥៦ |
| ភ្នំពេញ | ៧ | ២៤ | ៣៩ | ៨៤៥ |

| ខេត្ត/រាជធានី | ចំនួនស្រុក | ចំនួនឃុំ | ចំនួនភូមិ | ចំនួនជនជាតិដើមភាគតិច |
|---|---:|---:|---:|---:|
| ពោធិ៍សាត់ | ៣ | ៥ | ៩ | ៣០៤ |
| សៀមរាប | ៣ | ៧ | ១៣ | ២១១ |
| កណ្ដាល | ៦ | ៩ | ១៤ | ១៨៣ |
| ព្រះសីហនុ | ២ | ៧ | ៦ | ១៤៣ |
| បន្ទាយមានជ័យ | ៤ | ៤ | ៥ | ១១៤ |
| កំពង់ចាម | ៥ | ៦ | ៧ | ១០៨ |
| បាត់ដំបង | ៦ | ៦ | ៦ | ៩៥ |
| កំពត | ៣ | ៦ | ៦ | ៨១ |
| កំពង់ឆ្នាំង | ២ | ៤ | ៤ | ៥២ |
| ត្បូងឃ្មុំ | ២ | ៣ | ៣ | ៤១ |
| ស្វាយរៀង | ១ | ១ | ១ | ២២ |
| កោះកុង | ២ | ២ | ២ | ២១ |
| ឧត្ដរមានជ័យ | ១ | ១ | ១ | ១២ |
| កែប | ១ | ១ | ១ | ១០ |
| **ចំនួនសរុប** | **៨៥** | **២១៦** | **៥៤២** | **១៦៩.៤២៩** |

## ២.២. ស្ថានភាពប្រជាសាស្ត្រនៃជនជាតិដើមភាគតិច

ស្ថានភាពប្រជាសាស្ត្រនៅក្នុងរបាយការណ៍នេះ សំដៅលើកត្តាឌីណាមិកប្រជាសាស្ត្រទាំងបី (គឺការកើត ការស្លាប់ និងការផ្លាស់ទីលំនៅ) ព្រមទាំងកត្តាបម្រែបម្រួលប្រជាសាស្ត្រមួយចំនួនទៀត ដែលទាក់ទងជិតស្និទ្ធទៅនឹងកត្តាឌីណាមិកប្រជាសាស្ត្រទាំងបី ដូចជាបម្រែបម្រួលរចនាសម្ព័ន្ធអាយុនិងភេទ គ្រួសារនិងអាពាហ៍ពិពាហ៍ ជាដើម។

### *២.២.១. រចនាសម្ព័ន្ធអាយុភេទ*

#### ១. របាយភេទនិងផលធៀបភេទតាមក្រុមអា

ជនជាតិដើមភាគតិច គិតជាសរុប មានភាគរយស្ត្រីប្រហាក់ប្រហែលនឹងប្រជាជនកម្ពុជាទូទៅ នឹងមិនប្រែប្រួលពីពេលមួយទៅពេលមួយគួរឱ្យកត់សម្គាល់ទេ។ ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចសរុប ស្ត្រីមានចំនួន៥០,៩%នៅឆ្នាំ២០០៨ និង ៥១,១%នៅឆ្នាំ២០១៣។

តារាងទី៧. របាយភេទនៃជនជាតិដើមភាគតិច

| | ២០០៨ | | | ២០១៣ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ប្រជាជនកម្ពុជាសរុប | ៤៨,៦ | ៥១,៤ | ១០០,០ | ៤៨,៥ | ៥១,៥ | ១០០,០ |
| ជនជាតិដើមភាគតិច | ៤៩,១ | ៥០,៩ | ១០០,០ | ៤៨,៩ | ៥១,១ | ១០០,០ |

ក្រាហ្វិកទី២. ផលធៀបភេទតាមក្រុមអាយុ




បើគិតពីផលធៀបភេទតាមក្រុមអាយុ ដែលជាចំនួនមនុស្សប្រុសក្នុងចំណោមមនុស្សស្រី ១០០នាក់តាមក្រុមអាយុនីមួយៗ ប្រជាជនជនជាតិដើមភាគតិចមានផលធៀបភេទ ធំជាង១០០ក្នុងចំណោមប្រជាជនវ័យក្មេង ពោលគឺចំនួនមនុស្សប្រុសច្រើនជាងមនុស្សស្រី នៅឆ្នាំ២០១៣។ ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ កុមារាមានចំនួន១០៧នាក់ក្នុងចំណោមកុមារី១០០នាក់។ ផលធៀបភេទនេះមានទំហំកាន់តែតូច កាលណាអាយុប្រជាជនកាន់តែកើន ពោលគឺចំនួនមនុស្សប្រុសកាន់តែតិចជាងចំនួនមនុស្សស្រី។ ចាប់ពីអាយុ៥៥ឆ្នាំទៅ ចំនួនមនុស្សប្រុសមានតិចជាង៧០នាក់ក្នុងចំណោមមនុស្សស្ត្រី១០០នាក់។

## ២. ភាគរយស្ត្រីតាមអំបូរជនជាតិនីមួយៗ

យោងតាមទិន្នន័យឆ្នាំ២០០៨ ភាគច្រើននៃអំបូរជនជាតិដើមភាគតិចទាំងអស់ មានស្ត្រីច្រើនជាងបុរសតិចតួច (ក្នុងរង្វង់ពី ៥០,៤% ដល់ ៥៣,៣%) លើកលែងតែជនជាតិកាជ្រូកដែលមានស្ត្រីចំនួន ៥៦,៩% ជនជាតិស្អូចដែលមានស្ត្រីចំនួន ៦៤,៣% ជនជាតិមនដែលមានស្ត្រីចំនួន ៤២,១% និងជនជាតិកាចក់ដែលមានស្ត្រីចំនួនត្រឹមតែ២០%។

**តារាងទី៨. ភាគរយស្ត្រីតាមអំបូរជនជាតិដើមភាគតិច**

| អំបូរជនជាតិដើម | ជំរឿន២០០៨ | អង្កេតចន្លោះជំរឿន២០១៣ |
|---|---:|---:|
| ចារាយ | ៥០,៩ | ៥០,២ |
| កាវ៉ែត | ៥២,៥ | ៤៦,៥ |
| គ្លឹង | ៤៩,៧ | ៦៦,៧ |
| កួយ | ៥១,៨ | ៥០,១ |
| គ្រឹង | ៥១,០ | ៥៤,៦ |
| លុន | ៥៣,២ | ៩៤,៩ |
| ព្នង | ៥០,៤ | ៥១,២ |
| ព្រៅ | ៥០,៨ | ៥២,១ |
| ទំពួន | ៥០,៥ | ៥០,៥ |
| ស្ទៀង | ៤៩,៦ | ៥៧,២ |
| ចាអុង | ៥៣,៣ | ៧៤,៨ |
| ក្រោល | ៥០,៩ | ៥១,២ |
| រដែ | ៥២,៤ | ៥៨,៤ |
| ល្មូន | ៥០,៨ | ៥២,៦ |
| មិល | ៥១,៣ | ៣២,៨ |
| ខោញ | ៤៩,៤ | ១៦,៣ |
| ព័រ | ៥១,៧ | ៤៥,៦ |
| សួយ | ៥១,៧ | - |
| ស្អូច | ៦៤,៣ | ២៣,៨ |
| កាជ្រូក | ៥៦,៩ | ៥៥,១ |
| មន | ៤២,១ | ០,០ |
| កាចក់ | ២០,០ | ៨៥,១ |
| **សរុប** | **៥០,៩** | **៥១,១** |

### ៣. របាយភាគរយតាមក្រុមអាយុនៃជនជាតិដើមភាគតិច

តារាងទី៩ បង្ហាញពីរបាយភាគរយតាមក្រុមអាយុ៥ឆ្នាំ និងតារាងទី១០បង្ហាញពីរបាយភាគរយតាមវ័យប្រជាជននៃជនជាតិដើមភាគតិច នៅឆ្នាំ២០០៨ និង២០១៣ ដែលអាចប្រៀបធៀបនឹងរបាយអាយុនិងរបាយវ័យនៃប្រជាជនកម្ពុជាសរុបមាន។

**តារាងទី៩. របាយអាយុនៃជនជាតិដើមភាគតិចតាមក្រុមអាយុ៥ឆ្នាំ**

| ក្រុមអាយុ | ២០០៨ | | | | ២០១៣ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជាសរុប | | ជនជាតិដើមភាគតិច | | កម្ពុជាសរុប | | ជនជាតិដើមភាគតិច | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ០-៤ | ១.៣៧២.៦១៥ | ១០,២ | ២៤.៣១២ | ១៣,៦ | ១.៣០៣.៥៨៨ | ៨,៩ | ២១.៦១៧ | ១១,៨ |
| ៥-៩ | ១.៤៧០.៦៧២ | ១១,០ | ២៦.០០១ | ១៤,៥ | ១.៤៧៤.៦៥០ | ១០,០ | ២៥.១២២ | ១៣,៧ |
| ១០-១៤ | ១.៦៧០.៥០៥ | ១២,៥ | ២៤.៣២៤ | ១៣,៦ | ១.៥៤៣.១៦០ | ១០,៥ | ២៣.៧៦០ | ១២,៩ |
| ១៥-១៩ | ១.៦១៩.២៩០ | ១២,១ | ១៩.១២៦ | ១០,៧ | ១.៥៥៨.០០៤ | ១០,៦ | ២០.៩១១ | ១១,៤ |
| ២០-២៤ | ១.៣៦៩.២០២ | ១០,២ | ១៦.០៧០ | ៩,០ | ១.៦១៣.៩៤០ | ១១,០ | ១៦.៣៤០ | ៨,៩ |
| ២៥-២៩ | ១.២៣៣.៣៦១ | ៩,២ | ១៤.៨៦៤ | ៨,៣ | ១.៣៤២.៩១៩ | ៩,២ | ១៤.៥៣០ | ៧,៩ |
| ៣០-៣៤ | ៦៩៣.២៣៥ | ៥,២ | ៩.៩៧៩ | ៥,៦ | ១.២១០.៩៣៦ | ៨,៣ | ១២.៤៩២ | ៦,៨ |
| ៣៥-៣៩ | ៨៤៤.៩៤៨ | ៦,៣ | ៩.៨៤១ | ៥,៥ | ៧៣៤.៩៧០ | ៥,០ | ៩.៦៦៧ | ៥,៣ |
| ៤០-៤៤ | ៧៣៧.៤៥១ | ៥,៥ | ៨.២៤៣ | ៤,៦ | ៨៤៤.៨២៣ | ៥,៨ | ៩.០១៣ | ៤,៩ |
| ៤៥-៤៩ | ៦៥៣.៦៥០ | ៤,៩ | ៧.២២២ | ៤,០ | ៧៧២.៥៩៩ | ៥,៣ | ៨.១០៧ | ៤,៤ |
| ៥០-៥៤ | ៤៩០.៧២៦ | ៣,៧ | ៥.៤៩៤ | ៣,១ | ៦៦១.៣៥០ | ៤,៥ | ៥.៤៦៤ | ៣,០ |
| ៥៥-៥៩ | ៣៩១.១១៦ | ២,៩ | ៤.០៦៦ | ២,៣ | ៤៩៨.៥០៤ | ៣,៤ | ៤.៤០៣ | ២,៤ |
| ៦០-៦៤ | ២៧៧.៦១១ | ២,១ | ៣.៣៤០ | ១,៩ | ៣៩០.៦១៩ | ២,៧ | ៤.៨៦៣ | ២,៦ |
| ៦៥-៦៩ | ២១៦.៨៣៩ | ១,៦ | ២.៤៤២ | ១,៤ | ២៧២.៦៥៧ | ១,៩ | ២.៥៩៦ | ១,៤ |
| ៧០-៧៤ | ១៥៨.៩៤៥ | ១,២ | ១.៧៩២ | ១,០ | ២០១.៩៨៩ | ១,៤ | ១.៦៨០ | ០,៩ |
| ៧៥-៧៩ | ១០៧.៨៨៦ | ០,៨ | ១.០០១ | ០,៦ | ១៣០.៨០៩ | ០,៩ | ១.៦៣៩ | ០,៩ |
| ៨០ឆ្នាំឡើង | ៨៧.៦៣០ | ០,៧ | ១.០៧៦ | ០,៦ | ១២១.០៧២ | ០,៨ | ១.៦២៨ | ០,៩ |
| សរុប | ១៣.៣៩៥.៦៨២ | ១០០,០ | ១៧៩.១៩៣ | ១០០,០ | ១៤.៦៧៦.៥៨៩ | ១០០,០ | ១៨៣.៨៣១ | ១០០,០ |

*ប្រភព៖ ជំរឿនប្រជាជន ២០០៨ (GPCC 2008) និងអង្កេតពាក់កណ្ដាលជំរឿនប្រជាជន ២០១៣ (CIPS 2013)*

នៅឆ្នាំ២០០៨ ប្រជាជននៃជនជាតិដើមភាគតិច ជាប្រជាជនវ័យក្មេង គឺប្រជាជនអាយុក្រោម១៥ឆ្នាំមានចំនួនដល់ទៅ ៤១,៧% នៃប្រជាជននៃជនជាតិដើមភាគតិចសរុប (ធៀបនឹងប្រជាជនកម្ពុជាសរុបដែលមានចំនួន ៣៣,៧%)។ នៅឆ្នាំ២០១៣ ចំនួននេះបានថយចុះត្រឹម ៣៧,៤% ធៀបនឹងប្រជាជនកម្ពុជាសរុបដែលថយចុះដល់ ២៩,៤%។ រីឯប្រជាជនអាយុ១៥-៥៩ឆ្នាំ (ដែលជាប្រជាជនក្នុងវ័យធ្វើការ

យោងតាមនិយមន័យជំរឿន) មានចំនួន ៥៣% ក្នុងចំណោមជនជាតិដើមភាគតិច ធៀបនឹង ៦០% ក្នុងចំណោមប្រជាជនកម្ពុជាសរុប នៅឆ្នាំ២០០៨ និង មានចំនួន ៥៤,៩% ក្នុងចំណោមជនជាតិដើមភាគតិច ធៀបនឹង ៦២,៩% ក្នុងចំណោមប្រជាជនសរុប នៅឆ្នាំ២០១៣។ នេះបង្ហាញថា ប្រជាជនជនជាតិដើមភាគតិចក្នុងវ័យធ្វើការ ក៏កើនឡើងដែរក្នុងចន្លោះឆ្នាំ២០០-៨២០១៣ តែអត្រាកំណើនប្រចាំឆ្នាំនៃប្រជាជនជនជាតិដើមភាគតិចក្នុងវ័យធ្វើការ ស្មើនឹង ១,២៣% ទាបជាងអត្រាកំណើនរបស់ប្រជាជនកម្ពុជាសរុប ដែលស្មើនឹង ២,៨០%។

តារាងទី១០ បង្ហាញពីរបាយប្រជាជនតាមវ័យ យោងតាមទិន្នន័យឆ្នាំ២០០៨និង២០១៣។ វ័យត្រូវបានបែងចែកចេញជា៥ក្រុម[២] ដែលរួមមាន៖ ១) វ័យទារកនិងកុមារតូចអាយុក្រោម៥ឆ្នាំ, ២) វ័យកុមារនិងជំទង់ក្នុងវ័យសិក្សា អាយុ៥-១៧ឆ្នាំ, ៣) វ័យចាប់ផ្តើមការងារ អាយុ១៨-៣៥ឆ្នាំ, ៤) វ័យកណ្តាល (ឬ មជ្ឈិមវ័យ) អាយុ៣៦-៥៩ឆ្នាំ, និង ៥) វ័យចូលនិវត្តន៍ឬវ័យចាស់ អាយុ៦០ឆ្នាំឡើង។

ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចនៅឆ្នាំ២០០៨ ទារកនិងកុមារតូចអាយុក្រោម៥ឆ្នាំមានចំនួន ១៣,៦% កុមារនិងជំទង់ក្នុងវ័យសិក្សាអាយុ៥-១៧ឆ្នាំមានចំនួន ៣៤,៤% វ័យចាប់ផ្តើមការងារអាយុ១៨-៣៥ឆ្នាំមានចំនួន ២៨,៨% វ័យកណ្តាលអាយុ៣៦-៥៩ឆ្នាំមានចំនួន ១៧,៨% និងវ័យចូលនិវត្តន៍ឬវ័យចាស់អាយុ៦០ឆ្នាំឡើងមានចំនួន ៥,៤%។ នៅឆ្នាំ២០១៣ របាយអាយុតាមវ័យនេះ ប្រែប្រួលខ្លះៗតាមលំអាននៃប្រជាជនកម្ពុជាសរុប គឺប្រជាជនវ័យក្មេងថយចុះ ប្រជាជនក្នុងវ័យធ្វើការកើនឡើង និង ប្រជាជនវ័យចាស់កើនឡើង តែទំហំនៃការប្រែប្រួលគឺនៅតូចនៅឡើយ។

**តារាងទី១០. របាយអាយុនៃជនជាតិដើមភាគតិចតាមវ័យ**

| ក្រុមអាយុ | ២០០៨ | | | | ២០១៣ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជាសរុប | | ជនជាតិដើមភាគតិច | | កម្ពុជាសរុប | | ជនជាតិដើមភាគ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ០-៤ | ១.៣៤៨.៣០៣ | ១០,១ | ២៤.៣១២ | ១៣,៦ | ១.២៨១.៩៧១ | ៨,៧ | ២១.៦១៧ | ១១,៨ |
| ៥-១៧ | ៤.០៥៣.៣៨២ | ៣០,៣ | ៦១.៧១១ | ៣៤,៤ | ៣.៨៥៣.៤៤៣ | ២៦,៣ | ៦០.៧០១ | ៣៣,០ |
| ១៨-៣៥ | ៤.០៧៥.៨៩៥ | ៣០,៤ | ៥១.៥៥៨ | ២៨,៨ | ៤.៩៣៨.៣១២ | ៣៣,៦ | ៥៥.០៤៥ | ២៩,៩ |
| ៣៦-៥៩ | ២.៨៩៩.៦៤៩ | ២១,៦ | ៣១.៩៦១ | ១៧,៨ | ៣.៣១៤.២៩៤ | ២២,៦ | ៣៤.០៦១ | ១៨,៥ |
| ៦០ឆ្នាំឡើង | ៨៣.៩២៦ | ៦,៣ | ៩.៦៥១ | ៥,៤ | ១.១០៤.៧៤០ | ៧,៥ | ១២.៤០៦ | ៦,៧ |

[២] ការបែងចែកតាមវ័យដូច្នេះ គឺយោងតាមស្ថានភាពនិងសំណើរបស់ភាគីអនុវត្តន៍ការងារអភិវឌ្ឍន៍ជនជាតិដើមភាគតិច។

## ៤. របាយវ័យនៃជនជាតិដើមភាគតិចតាមអំបូរធំៗទាំង១២

បើគិតតាមអំបូរធំៗនីមួយៗ ជនជាតិចាអុងមានប្រជាជនវ័យក្មេងតិចជាងគេ (៩,១%) និងមានប្រជាជនក្នុងវ័យធ្វើការដំបូង (៤៦,៤%) និងវ័យកណ្តាល (៣៤,៦%) ច្រើនជាងគេ។ បន្ទាប់មក គឺជនជាតិស្ទៀងនិងជនជាតិគ្រោល។ រីឯជនជាតិព្នង ជនជាតិទំពួន និងជនជាតិព័រ មានប្រជាជនអាយុក្រោម៥ឆ្នាំនិងអាយុ៥-១៧ឆ្នាំច្រើនជាងគេ (ជាមធ្យមប្រហែល១៥% និង ៣៦,៥%) និងមានប្រជាជនក្នុងវ័យធ្វើការដំបូង (ជាមធ្យមប្រហែល ២៧%) និងវ័យកណ្តាល (ជាមធ្យមប្រហែល ១៦%) តិចជាងគេ។

**ក្រាហ្វិកទី៣. របាយវ័យនៃជនជាតិដើមភាគតិចតាមអំបូរធំៗទាំង១២**




## ៦. ពីរ៉ាមីដប្រជាជនរបស់ជនជាតិដើមភាគតិច

ពីរ៉ាមីដប្រជាជន គឺជាក្រាហ្វិកដែលបង្ហាញពីរបាយប្រជាជនទៅតាមភេទ (ចំហៀងខាងឆ្វេងជាប្រជាជនប្រុសនិងចំហៀងខាងស្តាំជាប្រជាជនស្រី) និងតាមក្រុមអាយុ៥ឆ្នាំ (ដែលផ្នែកខាងក្រោមជាប្រជាជនវ័យក្មេងបំផុត គឺក្រុមអាយុពីក្រោម១ឆ្នាំដល់អាយុក្រោម៥ឆ្នាំ និងផ្នែកខាងលើជាប្រជាជនវ័យចាស់បំផុត គឺក្រុមអាយុ៨០ឆ្នាំឡើង)។

ពីរ៉ាមីដប្រជាជនក្នុងក្រាហ្វិកខាងក្រោម បង្ហាញថា ប្រជាជនជនជាតិដើមភាគតិច ជាប្រជាជនដែលមានវ័យក្មេងជាងប្រជាជនកម្ពុជាសរុប ដោយហេតុថា ប្រជាជនអាយុក្រោម១៥ឆ្នាំមានចំនួនច្រើនជាង (ជិត ៤០%នៃប្រជាជនសរុប នៅឆ្នាំ២០១៣ ដែលថយចុះតិចតួចពី ៤២%នៅឆ្នាំ២០០៨)។ លើសពីនេះទៀត ពីរ៉ាមីដបង្ហាញឱ្យឃើញថា អត្រាកំណើតរបស់ជនជាតិភាគតិចទើបនឹងថយចុះនៅក្រោយឆ្នាំ២០០៨ ដោយសារភាគរយប្រជាជនអាយុក្រោម៥ឆ្នាំ មានចំនួនតិចជាងភាគរយប្រជាជនអាយុ៥-៩ឆ្នាំ ដែលនៅឆ្នាំ២០១៣ ប្រជាជនអាយុក្រោម៥ឆ្នាំមានចំនួន ១២,៨% និងប្រជាជនអាយុ៥-៩ឆ្នាំ មានចំនួន ១៣,៧%។

ភាគរយនៃកម្លាំងពលកម្មរបស់ប្រជាជនជនជាតិដើមភាគតិច (ប្រជាជនក្នុងវ័យធ្វើការ អាយុ១៥-៦៤ឆ្នាំ) ក៏មានចំនួនតិចជាងភាគរយនៃកម្លាំងពលកម្មរបស់ប្រជាជនកម្ពុជាសរុប ដោយសារភាគរយនៃប្រជាជនអាយុក្រោម១៥ឆ្នាំមានចំនួនច្រើនជាងក្នុងចំណោមប្រជាជនជនជាតិដើមភាគតិច។ នៅឆ្នាំ២០១៣ ភាគរយនៃកម្លាំងពលកម្មរបស់ប្រជាជនជនជាតិដើមភាគតិច មានចំនួនប្រហែល ៥៧% ធៀបនឹងកម្ពុជាសរុបដែលមានចំនួនប្រហែល ៦៦%។ ទោះយ៉ាងនេះក្តី កម្លាំងពលកម្មរបស់ប្រជាជនជនជាតិដើមភាគតិច បានកើនឡើងបន្តិច គឺពីចំនួន ៥៥%នៅឆ្នាំ២០០៨ ដល់ចំនួន ៥៧%នៅឆ្នាំ២០១៣។

## ក្រាហ្វិកទី៤.    ពីរ៉ាមីដប្រជាជនកម្ពុជានិងជនជាតិដើមភាគតិច ឆ្នាំ២០១៣






### ៧. ផលធៀបអ្នកក្នុងបន្ទុក

ផលធៀបអ្នកក្នុងបន្ទុក (Dependency ratio) ជាសូចនាករដែលបង្ហាញពីបន្ទុកសេដ្ឋកិច្ចរបស់ប្រជាជនក្នុងវ័យធ្វើការអាយុ១៥-៦៤ឆ្នាំ ក្នុងការផ្គត់ផ្គង់អ្នករស់នៅក្នុងបន្ទុក ដែលជាទូទៅ គេចែកជាអ្នកក្នុងបន្ទុកវ័យក្មេង (អាយុក្រោម១៥ឆ្នាំ) និងអ្នកក្នុងបន្ទុកវ័យចាស់ (អាយុ៦៥ឆ្នាំឡើង) និងដែលគណនាក្នុងចំណោមប្រជាជនក្នុងវ័យធ្វើការចំនួន១០០នាក់។ រីឯផលធៀបសក្តានុពលគាំទ្រ (Potential support ratio) ជាលទ្ធភាពនៃការគាំទ្រប្រជាជនវ័យចាស់អាយុ៦៥ឆ្នាំឡើង គណនាជាចំនួនប្រជាជនក្នុងវ័យធ្វើការអាយុ១៥-៦៤ឆ្នាំ ក្នុងមនុស្សវ័យចាស់ម្នាក់។

ជនជាតិដើមភាគតិច មានផលធៀបអ្នកក្នុងបន្ទុកសរុបស្មើនឹង ៨២,៣៩ នៅឆ្នាំ២០០៨ និង ៧៣,៧៧ នៅឆ្នាំ២០១៣ ដែលមានន័យថា ក្នុងចំណោមប្រជាជនក្នុងវ័យធ្វើការ១០០នាក់ មានអ្នកក្នុងបន្ទុកសរុបចំនួនជាង ៨២នាក់នៅឆ្នាំ២០០៨ និងជាង ៧៣នាក់នៅឆ្នាំ២០១៣ ដែលខ្ពស់ជាងតួលេខសម្រាប់ប្រជាជនកម្ពុជាសរុបជិត ២០នាក់ ទាំងនៅឆ្នាំ២០០៨និងឆ្នាំ២០១៣។ ភាពខុសគ្នានេះ បណ្តាលមកពីផលធៀបអ្នកក្នុងបន្ទុកវ័យក្មេងខ្ពស់ក្នុងចំណោមជនជាតិដើមភាគតិចធៀបនឹងប្រជាជនកម្ពុជាសរុប គឺ ៧៥,៩៧ ធៀបនឹង ៥៤,៣១ នៅឆ្នាំ២០០៨ និង ៦៦,៦៤ ធៀបនឹង ៤៤,៨៨ នៅឆ្នាំ២០១៣។ ផលធៀបសក្តានុពលគាំទ្របង្ហាញថា ជនជាតិដើមភាគតិចវ័យចាស់ម្នាក់ មានប្រជាជនក្នុងវ័យធ្វើការចំនួន ១៥,៥៧នាក់ នៅឆ្នាំ២០០៨ និង ១៤,០២នាក់ នៅឆ្នាំ២០១៣ ដែលខុសគ្នាតិចតួចទៅនឹងផលធៀបសក្តានុពលគាំទ្រនៃប្រជាជនកម្ពុជាសរុប។

**តារាងទី១១. ផលធៀបអ្នកក្នុងបន្ទុក**

| | | ផលធៀបអ្នកក្នុងបន្ទុកសរុប | ផលធៀបអ្នកក្នុងបន្ទុកវ័យក្មេង | ផលធៀបអ្នកក្នុងបន្ទុកវ័យចាស់ | ផលធៀបសក្តានុពលគាំទ្រ |
|---|---|---|---|---|---|
| ២០០៨ | កម្ពុជាសរុប | ៦១,១៩ | ៥៤,៣១ | ៦,៨៧ | ១៤,៥៥ |
| | ជនជាតិដើមភាគតិច | ៨២,៣៩ | ៧៥,៩៧ | ៦,៤២ | ១៥,៥៧ |
| ២០១៣ | កម្ពុជាសរុប | ៥២,៤៣ | ៤៤,៨៨ | ៧,៥៥ | ១៣,២៥ |
| | ជនជាតិដើមភាគតិច | ៧៣,៧៧ | ៦៦,៦៤ | ៧,១៣ | ១៤,០២ |

## ២.២.២. គ្រួសារនិងអាពាហ៍ពិពាហ៍

### ១. ចំនួនគ្រួសារ និងភាគរយនៃគ្រួសារដែលស្ត្រីជាមេគ្រួសារ

ជាទូទៅ គ្រួសារជនជាតិដើមភាគតិចមានទំហំធំជាងទំហំគ្រួសាររបស់ប្រជាជនកម្ពុជាសរុប។ ទោះជាដូច្នេះក្តី ទំហំគ្រួសាររបស់ជនជាតិដើមភាគតិច ក៏មាននិន្នាការថយចុះដែរ។ គ្រួសារជនជាតិដើម

ភាគតិច មានចំនួនសមាជិកជាមធ្យម ៥,៣នាក់នៅឆ្នាំ២០០៨ និង ៤,៩នាក់នៅឆ្នាំ២០១៣ បើធៀបនឹងប្រជាជនកម្ពុជាសរុប ដែលមានចំនួន ៤,៧នាក់នៅឆ្នាំ២០០៨ និងចំនួន ៤,៤នាក់នៅឆ្នាំ២០១៣។

ក្នុងចំណោមគ្រួសារទាំង ៣៧,២០១គ្រួសារ នៅឆ្នាំ២០១៣ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានចំនួន ២២% ។ ចំនួននេះ បានកើនឡើងគួរឱ្យកត់សម្គាល់ពី ១៤%នៅឆ្នាំ២០០៨។ យោងតាមទិន្នន័យជំរឿនឆ្នាំ២០០៨ ភាគរយនៃស្ត្រីជាមេគ្រួសារជនជាតិដើមភាគតិច ខុសគ្នាពីខេត្តមួយទៅខេត្តមួយគួរឱ្យកត់សម្គាល់ (ក្រាហ្វិកទី៥)។ ខេត្តដែលមានភាគរយនៃស្ត្រីជាមេគ្រួសារទាបជាងភាគរយសរុបទូទាំងប្រទេសសម្រាប់ជនជាតិដើមភាគតិច (គឺ១៤%) មានខេត្តប៉ៃលិន និងរតនគិរី។ ខេត្តដែលមានភាគរយនៃស្ត្រីជាមេគ្រួសារក្នុងរង្វង់ ១០%-១៩% (ប្រហាក់ប្រហែលនឹងភាគរយសរុប) ច្រើនជាខេត្តដែលមានចំនួនជនជាតិដើមភាគតិចច្រើន ដែលរួមមានខេត្តឧត្តរមានជ័យ ស្ទឹងត្រែង មណ្ឌលគិរី ព្រះវិហារ និងក្រចេះ។ រីឯខេត្តដែលមានភាគរយនៃស្ត្រីជាមេគ្រួសារចំនួន ៣០%ឡើងទៅ មានខេត្តតាកែវ ស្វាយរៀង ព្រៃវែង កំពត និងបន្ទាយមានជ័យ។ ខុសពីនេះ គឺជាខេត្តដែលមានភាគរយនៃស្ត្រីជាមេគ្រួសារក្នុងរង្វង់២០%-២៩% ដែលមានចំនួន១៣រាជធានីខេត្ត។

**តារាងទី១២. ចំនួនគ្រួសារ និងភាគរយនៃគ្រួសារដែលស្ត្រីជាមេគ្រួសារ**

| | ២០០៨ | | ២០១៣ | |
|---|---|---|---|---|
| | ជនជាតិដើមភាគតិច | ប្រជាជនកម្ពុជា | ជនជាតិដើមភាគតិច | ប្រជាជនកម្ពុជា |
| ចំនួនប្រជាជន | ១៧៩.១៩៣ | ១៣.៣៩៥.៦៨២ | ១៨៣.៨៣១ | ១៤.៦៧៦.៥៩១ |
| ចំនួនគ្រួសារ | ៣.៣៨២ | ២.៨៤១.៨៩៧ | ៣៧.២០១ | ៣.៣១១.០៥០ |
| ទំហំគ្រួសារគិតជាមធ្យម | ៥,៣ | ៤,៧ | ៤,៩ | ៤,៤ |
| ចំនួនគ្រួសារស្ត្រីជាមេគ្រួសារ | ១៤ | ២៦ | ២២ | ២៧ |

ក្រាហ្វិកទី៥. ភាគរយនៃស្ត្រីជាមេគ្រួសារតាមខេត្តនីមួយ ឆ្នាំ២០១៣



## ២. ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច

ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច គិតជារួម ប្រហាក់ប្រហែលគ្នានឹងស្ថានភាពអាពាហ៍ពិពាហ៍របស់ប្រជាជនកម្ពុជាទាំងមូល និងមានការប្រែប្រួលតិចតួចពីឆ្នាំ២០០៨ដល់២០១៣។ នៅឆ្នាំ២០០៨ ៥៦,០%នៃជនជាតិដើមភាគតិចទាំងអស់ នៅមិនទាន់រៀបការ (កម្ពុជាសរុបចំនួន ៥៥,៤%) ៣៩,៧%រៀបការហើយ (កម្ពុជាសរុបចំនួន ៣៩,៩%) និង ៤,៣%មានគ្រួសារបែកបាក់ (កម្ពុជាសរុបចំនួន ៤,៧%)។ នៅឆ្នាំ២០១៣ ៥៥,៤%នៃជនជាតិដើមភាគតិចទាំងអស់ នៅមិនទាន់រៀបការ (កម្ពុជាសរុបចំនួន ៥១,៤%) ៣៩,៧%រៀបការហើយ (កម្ពុជាសរុបចំនួន ៤៣,៧%) និង៤,៩% មានគ្រួសារបែកបាក់ (កម្ពុជាសរុបចំនួន ៤,៩%)។

**តារាងទី១៣. ស្ថានភាពអាពាហ៍ពិពាហ៍**

| ២០០៨ | ជនជាតិដើមភាគតិច | | | កម្ពុជា | | |
|---|---|---|---|---|---|---|
| | សរុប | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី |
| មិនទាន់រៀបការ | ៥៦,០ | ៥៩,២ | ៥៣,០ | ៥៥,៤ | ៥៩,៤ | ៥១,៦ |
| រៀបការហើយ | ៣៩,៧ | ៣៩,២ | ៤០,១ | ៣៩,៩ | ៣៩,២ | ៤០,៦ |
| មេម៉ាយ/ពោះម៉ាយ | ២,៩ | ០,៨ | ៤,៨ | ៣,៣ | ០,៨ | ៥,៧ |
| លែងលះ/បែកគ្នា | ១,៤ | ០,៧ | ២,១ | ១,៤ | ០,៦ | ២,២ |
| **២០១៣** | **ជនជាតិដើមភាគតិច** | | | **កម្ពុជា** | | |
| | សរុប | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី |
| មិនទាន់រៀបការ | ៥៥,៤ | ៥៩,១ | ៥១,៨ | ៥១,៤ | ៥៥,៥ | ៤៧,៦ |
| រៀបការហើយ | ៣៩,៧ | ៣៩,១ | ៤០,៤ | ៤៣,៧ | ៤៣,០ | ៤៤,២ |
| មេម៉ាយ/ពោះម៉ាយ | ៤,០ | ១,៦ | ៦,៣ | ៣,៥ | ០,៩ | ៦,០ |
| លែងលះ/បែកគ្នា | ០,៩ | ០,៣ | ១,៤ | ១,៤ | ០,៦ | ២,១ |

ភាពខុសគ្នានៃយេនឌ័រអំពីស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច ក៏ដូចជារបស់ប្រជាជនកម្ពុជាទូទៅដែរ បង្ហាញថា ស្ត្រីមានភាគរយមិនទាន់រៀបការទាបជាងបុរស តែមានភាគរយមេម៉ាយ/លែងលះ/បែកបាក់ ខ្ពស់ជាងបុរស។

លើសពីនេះទៀត ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច ខុសគ្នាយ៉ាងខ្លាំងពីអំបូរជនជាតិមួយទៅអំបូរជនជាតិមួយទៀត (ក្រាហ្វិកទី៦)។ អំបូរជនជាតិដើមភាគតិចដែលមានប្រជាជនមិនទាន់រៀបការតិចនិងមានប្រជាជនរៀបការហើយច្រើន គឺ៖

១- ស្អូច (មិនទាន់រៀបការមាន ៦,៥% និង រៀបការហើយមាន ៧៥,៧%)

២- ចាអុង (មិនទាន់រៀបការមាន ១២,៧% និង រៀបការហើយមាន ៧៦,១%)

៣- កាជ្រូក (មិនទាន់រៀបការមាន ១៩,៩% និង រៀបការហើយមាន ៦៦,៩%)

៤- មន (មិនទាន់រៀបការមាន ២១,១% និង រៀបការហើយមាន ៥៧,៩%)

៥- កាចក់ (មិនទាន់រៀបការមាន ៣០,០% និង រៀបការហើយមាន ៤០,០%)

៦- រដែ (មិនទាន់រៀបការមាន ៣៨,១% និង រៀបការហើយមាន ៥២,៤%)

រីឯអំបូរជនជាតិដើមភាគតិចដែលមានប្រជាជនមិនទាន់រៀបការច្រើននិងមានប្រជាជនរៀបការហើយតិច គឺ៖

១- ព្នង (មិនទាន់រៀបការមាន ៦១,០% និង រៀបការហើយមាន ៣៥,៥%)

២- ក្រោល (មិនទាន់រៀបការមាន ៦០,៣% និង រៀបការហើយមាន ៣៧,៦%)

៣- ខោញ (មិនទាន់រៀបការមាន ៦០,៣% និង រៀបការហើយមាន ៣៧,៦%)

៤- ល្មូន (មិនទាន់រៀបការមាន ៥៩,១% និង រៀបការហើយមាន ៣៥,៦%)

៥- ព័រ (មិនទាន់រៀបការមាន ៥៨,៨% និង រៀបការហើយមាន ៣៧,០%)

៦- ទំពួន (មិនទាន់រៀបការមាន ៥៨,៣% និង រៀបការហើយមាន ៣៩,០%)

៧- កួយ (មិនទាន់រៀបការមាន ៥៧,៥% និង រៀបការហើយមាន ៣៨,១%)

អំបូរមួយចំនួនទៀត ដែលមានចំនួនប្រជាជនមិនទាន់រៀបការជាង៥០% មានស្ទួយ មិល ព្រៅ លុន គ្រឹង ការ៉ែត និងចារាយ។

រីឯអំបូរជនជាតិដើមភាគតិច ដែលមានប្រជាជនដែលមានគ្រួសារបែកបាក់ច្រើន (មេម៉ាយ ពោះម៉ាយ ឬលែងលះ) មាន កាចក់ (៣០%), មន (២១,១%), ស្អូច (១៧,៨%), កាជ្រូក (១៥,២%), ចាអុង (១១,២%), និង រដែ (៩,៥%)។

ក្រាហ្វិកទី៦.    ស្ថានភាពអាពាហ៍ពិពាហ៍របស់ជនជាតិដើមភាគតិច នៅឆ្នាំ២០០៨



### ៣. អាពាហ៍ពិពាហ៍កាត់ជនជាតិ

យោងតាមទិន្នន័យឆ្នាំ២០០៨ គ្រួសារជនជាតិដែលមានប្តីប្រពន្ធទាំងពីរនាក់ (ចំនួន ៣១.៣៦៩ គ្រួសារ) ត្រូវបានបែងចែកទៅតាមអំបូរជនជាតិរបស់ប្តីនិងរបស់ប្រពន្ធ ដើម្បីកំណត់រកអាពាហ៍ពិពាហ៍កាត់ជនជាតិ ដែលមានន័យថា តើជនជាតិដើមភាគតិចមានរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិផ្សេងដែរឬទេ។ លទ្ធផលក្នុងក្រាហ្វិកខាងក្រោមបង្ហាញថា ជិត ៨២%នៃគ្រួសារទាំងនេះ ជាគ្រួសារដែលមានប្តីប្រពន្ធជាជនជាតិដើមទាំងអស់។ ក្រៅពីនេះ (ប្រហែល ១៨%) ជាគ្រួសារ ដែលមានតែប្តីជាជនជាតិដើមភាគតិច ឯប្រពន្ធជាជនជាតិផ្សេងទៀត ឬជាគ្រួសារដែលមានតែប្រពន្ធជាជនជាតិដើម ឯប្តីជាជនជាតិផ្សេងទៀត។ ជនជាតិផ្សេងទៀតនៅទីនេះ អាចជាជនជាតិខ្មែរ ឥស្លាម ថៃ ឡាវ វៀតណាម ជាដើម។

**ក្រាហ្វិកទី៧. អាពាហ៍ពិពាហ៍កាត់ជនជាតិ នៅឆ្នាំ២០០៨**




### ៤. អាយុរៀបការដំបូងរបស់ជនជាតិដើមភាគតិច

អាយុមធ្យមនៃការរៀបការលើកដំបូង ត្រូវបានគណនាតាមវិធី SMAM (Singulate Mean Age at Marriage) ដោយប្រើប្រាស់ទិន្នន័យឆ្នាំ២០១៣។ តាមការគណនានេះ (ក្រាហ្វិកទី៨) ជនជាតិដើមភាគតិចឆាប់រៀបការជាងប្រជាជនកម្ពុជាទូទៅដោយចំនួន២ឆ្នាំ គឺជនជាតិដើមភាគតិចរៀបការដំបូងនៅអាយុ២២,៧ឆ្នាំ ឯប្រជាជនកម្ពុជាទូទៅរៀបការដំបូងនៅអាយុ២៤,៩ឆ្នាំ គិតជាមធ្យម។ ចំពោះបុរសជនជាតិដើមភាគតិចឆាប់រៀបការជាងប្រជាជនកម្ពុជាទូទៅដោយចំនួនជិត៣ឆ្នាំ គឺបុរសជនជាតិដើមភាគតិចរៀបការដំបូងនៅអាយុ២៣,៤ឆ្នាំ ឯបុរសកម្ពុជាទូទៅរៀបការដំបូងនៅអាយុ២៦,២ឆ្នាំ គិតជាមធ្យម។ ចំពោះស្ត្រី ជនជាតិដើមភាគតិចឆាប់រៀបការជាងប្រជាជនកម្ពុជាទូទៅដោយចំនួនជិត២ឆ្នាំ គឺគិតជា

មធ្យម ស្ត្រីជនជាតិដើមភាគតិចរៀបការដំបូងនៅអាយុ២២,១ឆ្នាំ ឯស្ត្រីកម្ពុជាទូទៅរៀបការដំបូងនៅអាយុ ២៣,៧ឆ្នាំ។ ការឆាប់រៀបការ អាចជាកត្តាកំណត់ការអាចមានកូនច្រើន។

**ក្រាហ្វិកទី៨. អាយុរៀបការដំបូង**




## ៥. អាយុស្ត្រីពេលមានកូនដំបូង

ការឆាប់រៀបការ អាចបណ្តាលឱ្យឆាប់មានកូន។ តារាងខាងក្រោមបង្ហាញថា ចំនួនស្ត្រីជនជាតិដើមភាគតិចដែលមានកូនដំបូងនៅអាយុក្រោម២០ឆ្នាំ មានចំនួនជិត២ដងនៃចំនួនស្ត្រីកម្ពុជាសរុប (៣៩% ក្នុងចំណោមស្ត្រីជនជាតិដើមភាគតិចអាយុក្រោម២០ឆ្នាំដែលរៀបការហើយ ធៀបនឹង ២១,៦% ក្នុងចំណោមស្ត្រីកម្ពុជាអាយុក្រោម២០ឆ្នាំដែលរៀបការហើយ)។

**តារាងទី១៤. អាយុស្ត្រីនាពេលមានកូនដំបូង**

| | របាយអាយុស្ត្រីរៀបការហើយនាពេលមានកូនដំបូង | | | |
|---|---|---|---|---|
| | ជនជាតិដើមភាគតិច | | ប្រជាជនកម្ពុជា | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| អាយុក្រោម២០ឆ្នាំ | ១៦.៤៤៩ | ៣៩,០ | ៧៩៨.៦៤៨ | ២១,៦ |
| អាយុ២០-២៤ឆ្នាំ | ១៨.២៥៦ | ៤៣,៣ | ១.៩៤៣.២២១ | ៥២,៧ |
| អាយុ២៥-២៩ឆ្នាំ | ៥.៨៤៦ | ១៣,៩ | ៦៨៥.៩៤២ | ១៨,៦ |
| អាយុ៣០ឆ្នាំឡើង | ១.៦១៦ | ៣,៨ | ២៦២.២៩៧ | ៧,១ |
| **សរុប** | **៤២.១៦៧** | **១០០,០** | **៣.៦៩០.១០៨** | **១០០,០** |

រីឯស្ត្រីជនជាតិដើមភាគតិចដែលរៀបការហើយ និងដែលមានកូនដំបូងនៅអាយុ២០ឆ្នាំឡើងទៅ មានចំនួនភាគរយតិចជាងស្ត្រីកម្ពុជា គ្រប់ក្រុមអាយុទាំងអស់។ នៅឆ្នាំ២០១៣ ស្ត្រីជនជាតិដែលមានកូននៅអាយុ២០-២៤ឆ្នាំមានចំនួន ៤៣,៣% នៅអាយុ២៥-២៩ឆ្នាំមានចំនួន ១៣,៩% និងនៅអាយុ៣០ឆ្នាំឡើងមានចំនួន ៣,៨% (ធៀបនឹងស្ត្រីកម្ពុជា ដែលមានចំនួនរៀងគ្នា ៥២,៧% ១៨,៦% និង៧,១%)។

### *២.២.៣. អត្រាកំណើត*

អត្រាកំណើតដុល (Crude Birth Rate) ក្នុងរយៈពេល១២ខែមុនការធ្វើអង្កេត (ទិន្នន័យអំពីកូនអាយុក្រោមមួយឆ្នាំ) និងចំនួនកូនដែលបានបង្កើត (Children Ever Born) (យោងតាមទិន្នន័យអំពីចំនួនកូនដែលបានបង្កើតរបស់ស្ត្រីរៀបការហើយ) ត្រូវបានគណនានិងប្រើប្រាស់ជារង្វាស់កំណើត នៅក្នុងការសិក្សានេះ។ តាមរង្វាស់នេះ អត្រាកំណើតដុល ជាចំនួនកូនសរុបដែលបានបង្កើតក្នុងរយៈពេល១២ខែមុខការធ្វើអង្កេត ក្នុងចំណោមស្ត្រីរៀបការហើយចំនួន១០០នាក់ រីឯចំនួនកូនដែលបានបង្កើត គឺជាចំនួនកូនដែលស្ត្រីរៀបការហើយបានបង្កើតរស់ ដែលរង្វាស់នេះត្រូវបានបំបែកតាមក្រុមអាយុរបស់ម្តាយ។ គួរកត់សម្គាល់ថា រង្វាស់នេះមិនមែនជាចំនួនកូនដែលស្ត្រីមាន ដោយដកចំនួនកូនដែលស្លាប់ក្រោយពេលកើតទេ។

#### ១. អត្រាកំណើតដុល

អត្រាកំណើតដុល (Crude Birth Rate) របស់ជនជាតិដើមភាគតិច ស្មើនឹង ៣,៤នាក់ ក្នុងចំណោមស្ត្រីចំនួន១០០នាក់នៅឆ្នាំ២០០៨ និង ៣,៧នាក់ ក្នុងចំណោមស្ត្រីចំនួន១០០នាក់នៅឆ្នាំ២០១៣ ដែលបង្ហាញពីការកើនតិចតួចនៃអត្រាកំណើត ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១៣។

**តារាងទី១៥. អត្រាមរណភាពទូទៅនិងអត្រាកំណើតក្នុងរយៈ១២ខែកន្លង**

| | ជនជាតិដើមភាគតិច | |
|---|---|---|
| | ២០០៨ | ២០១៣ |
| អត្រាមរណភាព (ក្នុង១.០០០នាក់) | ១០,២២ | ៣,២៩៩ |
| អត្រាកំណើត (%) | ៣,៤៣ | ៣,៦៨ |

#### ២. ចំនួនកូនដែលបានបង្កើត

តាមក្រាហ្វិកទី៩ខាងក្រោម ស្ត្រីជនជាតិដើមភាគតិចដែលរៀបការហើយ មានចំនួនកូនសរុបច្រើនជាងស្ត្រីកម្ពុជានៅគ្រប់វ័យ ពិសេសស្ត្រីរៀបការហើយក្នុងក្រុមអាយុពី២០ឡើងទៅ ហើយចំនួនខុសគ្នានេះកាន់តែធំកាលណាស្ត្រីអាយុកាន់តែច្រើន។

ស្ត្រីជនជាតិដើមភាគតិចអាយុក្រោម២០ឆ្នាំ មានអត្រាកំណើត៥១នាក់ ក្នុងចំណោមស្ត្រី១០០នាក់។ អត្រានេះ មានចំនួន១៩៤នាក់ ក្នុងចំណោមស្ត្រីជនជាតិដើមអាយុ២០-២៤ឆ្នាំ១០០នាក់, ចំនួន២៩៤នាក់ ក្នុងចំណោមស្ត្រីជនជាតិដើមអាយុ២៥-២៩ឆ្នាំ១០០នាក់, ចំនួន៣៦៤នាក់ ក្នុងចំណោមស្ត្រីជនជាតិដើមអាយុ៣០-៣៤ឆ្នាំ១០០នាក់, ចំនួន៤២២នាក់ ក្នុងចំណោមស្ត្រីជនជាតិដើមអាយុ៣៥-៣៩ឆ្នាំ១០០នាក់, ចំនួន៥០៧នាក់ ក្នុងចំណោមស្ត្រីជនជាតិដើមអាយុ៤០-៤៤ឆ្នាំ១០០នាក់ និង ចំនួន៤៦៣នាក់ ក្នុងចំណោមស្ត្រីជនជាតិដើមអាយុ៤៥-៤៩ឆ្នាំ១០០នាក់។ ធៀបនឹងស្ត្រីកម្ពុជាទូទៅ ស្ត្រីជនជាតិដើមភាគតិចអាយុពី៣០ដល់៤៤ឆ្នាំមានចំនួនកូនច្រើនជាងស្ត្រីកម្ពុជា ជាង១០០នាក់ ក្នុងចំណោមស្ត្រី១០០នាក់។ ជាក់ស្តែង ស្ត្រីជនជាតិដើមអាយុ៣០-៣៤ឆ្នាំ១០០នាក់ មានកូនចំនួន១៣១នាក់ លើសស្ត្រីកម្ពុជាទូទៅ ស្ត្រីជនជាតិដើមអាយុ៣៥-៣៩ឆ្នាំ១០០នាក់ មានកូនចំនួន១២៤នាក់ លើសស្ត្រីកម្ពុជាទូទៅ និងស្ត្រីជនជាតិដើមអាយុ៤០-៤៤ឆ្នាំ១០០នាក់ មានកូនចំនួន១៤៩នាក់ លើសស្ត្រីកម្ពុជាទូទៅ។

**ក្រាហ្វិកទី៩. ចំនួនកូនដែលបានបង្កើតតាមក្រុមអាយុស្ត្រី នៅឆ្នាំ២០១៣**




## ៣. ការសម្រាលកូនដោយមានវត្តមានបុគ្គលិកសុខាភិបាល

ក្រៅពីការមានកូនច្រើន ស្ត្រីជនជាតិដើមភាគតិច ច្រើនសម្រាលកូនដោយឆ្មបបុរាណ (៦៥,៦% នៃកំណើតក្នុងរយៈ១២ខែមុនពេលធ្វើអង្កេត ធៀបនឹងស្ត្រីកម្ពុជាដែលមានត្រឹមតែ ៩,៨%) និងដោយឆ្មប

(៣៣,៥% នៃកំណើតក្នុងរយៈ១២ខែមុនពេលធ្វើអង្កេត ធៀបនឹងស្ត្រីកម្ពុជាដែលមានដល់ ៦៧,៦%)។ រីឯស្ត្រីជនជាតិដើមភាគតិចដែលសម្រាលកូនដោយវេជ្ជបណ្ឌិតឬគិលានុបដ្ឋាយិកា មានចំនួនតិចបំផុត។

**ក្រាហ្វិកទី១០. ភាគរយស្ត្រីសម្រាលកូនទៅតាមវត្តមានបុគ្គលិកសុខាភិបាល**




**ក្រាហ្វិកទី១១. ភាគរយស្ត្រីសម្រាលកូនទៅតាមអំបូរជនជាតិនិងវត្តមានបុគ្គលិកសុខាភិបាល**



បើគិតទៅតាមអំបូរជនជាតិដើមនីមួយៗ ដែលមានចំនួនគ្រប់គ្រាន់សម្រាប់គណនា ជនជាតិដើមភាគតិចដែលសម្រាលកូនដោយឆ្មបបុរាណច្រើនជាងគេ គឺជនជាតិគ្រឹងនិងទំពួន (មានចំនួនជិត៨០% នៃស្ត្រីដែលសម្រាលកូនក្នុងរយៈ១២ខែមុនពេលធ្វើអង្កេត) បន្ទាប់មកគឺជនជាតិចារាយ (៧០,៧%) ជនជាតិការ៉ែតនិងកួយ (ជិត៥១%) ជនជាតិព្នង (៤៦%) និងជនជាតិព្រៅ (៤៣,៥%)។

ជនជាតិក្រោល ល្អប្រសើរជាងគេ ក្នុងការសម្រាលកូន ដោយចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណមានចំនួនតែ ២៩,១% និងស្ត្រីសម្រាលកូនដោយឆ្មបមានចំនួនជិត ៧១%។

### ៤. ចំនួននិងភាគរយកុមារដែលបានចុះបញ្ជីកំណើត

មានកុមារជនជាតិដើមភាគតិចអាយុក្រោម១ឆ្នាំ តែមួយភាគប្រាំប៉ុណ្ណោះ (ស្មើនឹង២០,៣%) ដែលបានចុះបញ្ជីកំណើត ធៀបនឹងកុមារកម្ពុជាទូទៅចំនួនជាង ៦២% (ក្រាហ្វិកទី១២)។ ជនជាតិដើមភាគតិចដែលបានចុះបញ្ជីកំណើតកូនអាយុក្រោម១ឆ្នាំបានច្រើនជាងគេ គឺជនជាតិព្រៅ (៥៦,៥%នៃកុមារដែលកើតក្នុងរយៈ១២ខែមុនពេលធ្វើអង្កេត) បន្ទាប់មក គឺជនជាតិការ៉ែត (៣៥,៥%) ជនជាតិព្នង (២១,៩%) ជនជាតិគ្រឹង (២១%) ជនជាតិទំពួន (១៩,៥%) និងជនជាតិចារាយ (១៤,១%)។ រីឯជនជាតិកួយនិងក្រោល មិនបានចុះបញ្ជីកំណើតកូន ដែលកើតក្នុងរយៈ១២ខែមុនពេលធ្វើអង្កេតទេ។

**ក្រាហ្វិកទី១២. ភាគរយកុមារអាយុក្រោម១ឆ្នាំបានចុះបញ្ជីកំណើត នៅឆ្នាំ២០១៣**



ក្រាហ្វិកទី១៣.    របាយភាគរយស្ត្រីរៀបការហើយ តាមចំនួនកូនដែលបានបង្កើត នៅឆ្នាំ២០១៣




### *២.២.៤. អត្រាមរណភាព*

#### ១. អត្រាមរណភាពដុល

អត្រាមរណភាពដុល (Crude mortality rate) គឺជាចំនួនមនុស្សគ្រប់វ័យដែលស្លាប់ ក្នុងចំណោមប្រជាជនចំនួន១.០០០នាក់ នៅឆ្នាំណាមួយ។ យោងតាមតារាងខាងលើ (ក្នុងចំណុច៣.២.៣ អំពីកំណើត) អត្រាមរណភាពទូទៅរបស់ជនជាតិដើមភាគតិច ស្មើនឹង ១០.២នាក់ នៅឆ្នាំ២០០៨ និង ៣.៣ នាក់នៅឆ្នាំ២០១៣។

#### ២. អត្រាមរណភាពទារកនិងកុមារ

អត្រាមរណភាពទារក (Infant Mortality Rate ជាអត្រាស្លាប់របស់ទារកចាប់ពីពេលប្រសូតដល់មុនគម្រប់ខួប១ឆ្នាំ) របស់ជនជាតិដើមភាគតិចមានកម្រិតខ្ពស់ធៀបនឹងអត្រាមរណភាពទារករបស់ប្រជាជនកម្ពុជាទូទៅ និងមានការថយចុះយឺតពីឆ្នាំ២០០៨មកឆ្នាំ២០១៣។ អត្រាមរណភាពទារករបស់ជនជាតិដើមភាគតិច ស្មើនឹង១៣៩នាក់នៅឆ្នាំ២០០៨ និង ១២៦នាក់នៅឆ្នាំ២០១៣ ក្នុងចំណោមកំណើតរស់១.០០០នាក់ (ធៀបនឹងកម្ពុជាសរុបដែលមានត្រឹម៣៣នាក់នៅឆ្នាំ២០១៣)។ ពុំមានទិន្នន័យអំពីមរណភាពកុមាររបស់ជនជាតិដើមភាគតិចទេ។

តារាងទី១៦.	អត្រាមរណភាពទារក

| | ២០០៨ | ២០១៣ |
|---|---|---|
| ស្ត្រីជនជាតិដើមភាគតិចដែលបង្កើតកូនរស់ | ៩៣.៣៣៤ | ៩៣.៨៨៩ |
| ទារកជនជាតិដើមភាគតិចដែលបានកើតរស់ | ១៥៦.៥៨១ | ១៦២.៥២៦ |
| ទារកជនជាតិដើមភាគតិចដែលនៅរស់ | ១៣៤.៨១៩ | ១៤២.១០៨ |
| ទារកជនជាតិដើមភាគតិចដែលស្លាប់ | ២១.៧៦២ | ២០.៤១៨ |
| អត្រាមរណភាពទារកក្នុងកំណើតរស់១.០០០នាក់ | ១៣៩,០ | ១២៥,៦ |

### ៣. អត្រាមរណភាពមាតា

អត្រាមរណភាពមាតា គឺជាចំនួនស្លាប់របស់មាតាដោយសារមូលហេតុនានាពាក់ព័ន្ធនឹងការមានគភ៌ឬការសម្រាលកូន គិតក្នុងកំណើតរស់ចំនួន ១០០.០០០នាក់។ ក៏ប៉ុន្តែ គ្មានទិន្នន័យអំពីអត្រាមរណភាពមាតារបស់ជនជាតិដើមភាគតិចទេ។

### *២.២.៥. ទេសន្តរប្រវេសន៍*

ទេសន្តរប្រវេសន៍ គឺជាដំណើរផ្លាស់ទីលំនៅពីទីតាំងភូមិសាស្ត្រមួយទៅកាន់ទីតាំងភូមិសាស្ត្រមួយទៀត។ យោងតាមទិន្នន័យជំរឿននិងទិន្នន័យអង្កេតចន្លោះជំរឿន ទេសន្តរប្រវេសន៍អាចវាស់វែងបានដោយប្រើទិន្នន័យអំពីទីកន្លែងកំណើត ទិន្នន័យអំពីកន្លែងរស់នៅពីមុន និងទិន្នន័យអំពីកន្លែងរស់នៅនាពេលប្រមូលទិន្នន័យ។ តាមទិន្នន័យទាំងនេះ ជនទេសន្តរប្រវេសន៍ (Migrants) គឺជាជនទាំងឡាយដែលកន្លែងរស់នៅបច្ចុប្បន្ននាពេលធ្វើអង្កេត ខុសពីទីកន្លែងរស់នៅនាមុនពេលធ្វើអង្កេត ។ ជនទេសន្តរប្រវេសន៍យូរមកហើយ (Lifetime migrants) គឺជាជនទាំងឡាយដែលកន្លែងរស់នៅបច្ចុប្បន្ននាពេលធ្វើអង្កេតខុសពីទីកន្លែងកំណើត។

### ១. ចំនួននិងភាគរយជនទេសន្តរប្រវេសន៍

តាមទិន្នន័យឆ្នាំ២០១៣ ជិត១០%នៃជនជាតិដើមភាគតិចទាំងអស់ បានផ្លាស់ទីកន្លែងរស់នៅពេលគឺកន្លែងរស់នៅនាពេលប្រមូលទិន្នន័យខុសពីកន្លែងដែលពួកគាត់រស់នៅពីមុនពេលធ្វើអង្កេត (គឺមានចំនួនតិច បើធៀបនឹងកម្ពុជាសរុប)។ ក្នុងចំណោមជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់ជនបទ អ្នកផ្លាស់ទីលំនៅមានចំនួន៩% និងក្នុងចំណោមជនជាតិដើមភាគតិចដែលរស់នៅក្នុងទីប្រជុំជន អ្នកផ្លាស់ទីលំនៅមានចំនួន ៥២,៦%។

**តារាងទី១៧.　　ចំនួននិងភាគរយអ្នកផ្លាស់ទីលំនៅ**

| | សរុប | ជនបទ | ទីប្រជុំជន |
|---|---|---|---|
| ចំនួនប្រជាជនសរុប | ១៨៣.៨៣២ | ១៨០.៨០៣ | ៣.០២៩ |
| ចំនួនអ្នកមិនផ្លាស់ទី | ១៦៥.៦៥៨ | ១៦៤.២២៣ | ១.៤៣៥ |
| ចំនួនអ្នកផ្លាស់ទី | ១៨.១៧៤ | ១.៦៥៨ | ១.៥៩៤ |
| ភាគរយអ្នកផ្លាស់ទី | ៩,៨៩ | ៩,១៧ | ៥២,៦២ |

## ២. លំហូរទេសន្តរប្រវេសន៍

លំហូរទេសន្តរប្រវេសន៍ បង្ហាញពីដំណើរផ្លាស់ទីលំនៅពីទីកន្លែងរស់នៅពីមុន (ជាតំបន់ជនបទឬទីប្រជុំជន) មកកន្លែងរស់នៅនាពេលធ្វើអង្កេត (ជាតំបន់ជនបទឬទីប្រជុំជន)[៣]។ ជនជាតិដើមភាគតិចភាគច្រើនផ្លាស់ទីទៅកាន់តំបន់ជនបទ ដែលការផ្លាស់ទីពីតំបន់ជនបទមួយទៅកាន់តំបន់ជនបទមួយផ្សេងទៀត មាន៨៥,៤% (ធៀបនឹងប្រជាជនកម្ពុជាសរុបដែលមានចំនួន៥៧,៧%) និងការផ្លាស់ទីពីតំបន់ទីប្រជុំជនទៅកាន់តំបន់ជនបទមានចំនួន ៥,៩% (តារាងទី១៨)។ រីឯជនជាតិដើមភាគតិចដែលផ្លាស់ទីទៅកាន់តំបន់ទីប្រជុំជនមានចំនួនតិចតួច បើធៀបនឹងប្រជាជនកម្ពុជាសរុប គឺពីតំបន់ជនបទទៅកាន់តំបន់ទីប្រជុំជន មានចំនួនតែ២,២% ដែលតួលេខនេះមានដល់ទៅ២២,១% ក្នុងចំណោមប្រជាជនកម្ពុជាសរុប និងពីតំបន់ទីប្រជុំជនមួយទៅកាន់តំបន់ទីប្រជុំជនមួយទៀតមានជិត៦% ក្នុងចំណោមជនជាតិដើមភាគតិចនិងក្នុងចំណោមប្រជាជនកម្ពុជាសរុប។

ភាពខុសគ្នានៃយេនឌ័រអំពីការធ្វើទេសន្តរប្រវេសន៍ ដែលទាក់ទងទៅនឹងទីដៅនៃការផ្លាស់ទី (តំបន់ជនបទឬតំបន់ទីប្រជុំជន) មានទំហំគួរឱ្យកត់សម្គាល់ខ្លះៗ។ ជាក់ស្តែង បុរសជនជាតិដើមភាគតិចដែលផ្លាស់ទីទៅកាន់តំបន់ជនបទ មានចំនួនភាគរយច្រើនជាងស្ត្រី គឺ៩៦,៨%ក្នុងចំណោមបុរសនិង៨៥,៤%ក្នុងចំណោមស្ត្រី ឯស្ត្រីជនជាតិដើមភាគតិចដែលផ្លាស់ទីទៅកាន់តំបន់ទីប្រជុំជន មានចំនួនភាគរយច្រើនជាងបុរស គឺ១៤,៦%ក្នុងចំណោមស្ត្រីនិង៣,២%ក្នុងចំណោមបុរស។ មានន័យថា ស្ត្រីផ្លាស់ទីទៅកាន់ទីប្រជុំជនច្រើនជាងបុរស។

[៣] កន្លែងរស់នៅពីមុន ត្រូវបានបែងចែកជាតំបន់ជនបទនិងទីប្រជុំជន ដោយយោងតាមទិន្នន័យជំរឿនឆ្នាំ២០០៨។

**តារាងទី១៨.   លំហូរទេសន្តរប្រវេសន៍ (ឆ្នាំ២០១៣)**

| | កម្ពុជា | ជនជាតិដើមភាគតិច | | |
|---|---|---|---|---|
| | សរុប | សរុប | ប្រុស | ស្រី |
| ពីទីប្រជុំជនទៅទីប្រជុំជន | ១៤,៣៨ | ៦,៥៦ | ២,៦៣ | ១០,៧២ |
| ពីទីប្រជុំជនទៅជនបទ | ៥,៨៩ | ៥,៨៦ | ៦,៤៧ | ៥,២៣ |
| ពីជនបទទៅទីប្រជុំជន | ២២,០៧ | ២,១៨ | ០,៥៧ | ៣,៨៧ |
| ពីជនបទទៅជនបទ | ៥៧,៦៦ | ៨៥,៤០ | ៩០,៣៣ | ៨០,១៨ |

## ៣. មូលហេតុទេសន្តរប្រវេសន៍

ក្នុងចំណោមមូលហេតុជាច្រើនដែលមានក្នុងទិន្នន័យ ការផ្លាស់ទីទាំងគ្រួសារនិងការរៀបការជាមូលហេតុចម្បងនៃទេសន្តរប្រវេសន៍របស់ជនជាតិដើមភាគតិច (៧២,១%) ទាំងបុរស (៧៣,៩%) ទាំងស្ត្រី (៧០,១%)។ មូលហេតុចម្បងទី២នៃការផ្លាស់ទីលំនៅ គឺការវិលត្រឡប់មកស្រុកវិញ (១០,១%សរុប ៩,៧%ក្នុងចំណោមស្ត្រី និង ១០,៤%ក្នុងចំណោមបុរស)។ រីឯមូលហេតុចម្បងទី៣ គឺការស្វែងរកការងារ (៩,៩%សរុប ១១,៨%ក្នុងចំណោមស្ត្រី និង ៨,០%ក្នុងចំណោមបុរស)។

**តារាងទី១៩.   មូលហេតុទេសន្តរប្រវេសន៍ (របាយភាគរយ)**

| | បុរស | ស្ត្រី | សរុប |
|---|---|---|---|
| ផ្ទេរកន្លែងធ្វើការ | ២,៧ | ០,៦ | ១,៧ |
| ស្វែងរកការងារ | ៨,០ | ១១,៨ | ៩,៩ |
| សិក្សា | ០,៦ | ០,១ | ០,៤ |
| រៀបការ | ៣២,១ | ៩,១ | ២០,៩ |
| ផ្លាស់ទីទាំងគ្រួសារ | ៤១,៨ | ៦១,០ | ៥១,២ |
| បាត់បង់ផ្ទះឬដីធ្លី | ២,៨ | ០,៥ | ១,៧ |
| គ្រោះធម្មជាតិ | ០,០ | ០,០ | ០,០ |
| អសន្តិសុខ | ០,២ | ៣,០ | ១,៦ |
| ត្រឡប់មកស្រុកវិញ | ១០,៤ | ៩,៧ | ១០,១ |
| បាត់បង់ឪពុក/ម្ដាយ | ០,០ | ៣,០ | ១,៥ |
| មកលេង | ១,៣ | ១,២ | ១,២ |
| **ចំនួនសរុប** | **៩២៨** | **៨.៨៩៤** | **១៨.១៧៤** |

### ២.២.៦. ប្រជាជនវ័យចាស់

**១. ជនជាតិដើមភាគតិចអាយុ៦០ឆ្នាំឡើង**

ប្រជាជនវ័យចាស់អាយុ៦០ឆ្នាំឡើងក្នុងចំណោមជនជាតិដើមភាគតិច មានចំនួន៥,៤% នៅឆ្នាំ ២០០៨ និង ៦,៧% នៅឆ្នាំ២០១៣ (ធៀបនឹងប្រជាជនវ័យចាស់កម្ពុជាសរុប ដែលមានចំនួន៦,៣% នៅឆ្នាំ២០០៨ និង ៧,៦% នៅឆ្នាំ២០១៣)។ ជាទូទៅ ស្ត្រីវ័យចាស់អាយុ៦០ឆ្នាំឡើង មានចំនួនច្រើនជាងបុរសវ័យចាស់អាយុ៦០ឆ្នាំឡើង តែភាពខុសគ្នាមានទំហំតូចក្នុងចំណោមជនជាតិដើមភាគតិច ជាងក្នុងចំណោមប្រជាជនកម្ពុជាសរុប។ នៅឆ្នាំ២០០៨ ប្រជាជនជនជាតិដើមភាគតិចដែលមានវ័យចាស់មានចំនួន៥%ក្នុងចំណោមបុរសនិង៥,៧%ក្នុងចំណោមស្ត្រី ធៀបនឹងប្រជាជនកម្ពុជាសរុបដែលមានចំនួន ៥,៣%ក្នុងចំណោមបុរសនិង៧,៣%ក្នុងចំណោមស្ត្រី។ នៅឆ្នាំ២០១៣ ប្រជាជនជនជាតិដើមភាគតិចដែលមានវ័យចាស់កើនដល់ ចំនួន៦,៣%ក្នុងចំណោមបុរសនិង៧,២%ក្នុងចំណោមស្ត្រី ធៀបនឹងប្រជាជនកម្ពុជាសរុបដែលមានចំនួន៦,៣%ក្នុងចំណោមបុរសនិង៨,៩%ក្នុងចំណោមស្ត្រី។

**ក្រាហ្វិកទី១៤. ភាគរយមនុស្សចាស់អាយុ៦០ឆ្នាំឡើង៖ ឆ្នាំ២០០៨និង២០១៣**



## ២. ប្រជាជនវ័យចាស់តាមអំបូរជនជាតិដើមភាគតិច

ភាគច្រើននៃអំបូរជនជាតិដើមភាគតិច មានភាគរយប្រជាជនវ័យចាស់ប្រហាក់ប្រហែលនឹងភាគរយប្រជាជនវ័យចាស់នៃជនជាតិដើមភាគតិចជាសរុប។ ក៏ប៉ុន្តែ អំបូរជនជាតិដើមភាគតិចចំនួនពីរមានភាគរយប្រជាជនវ័យចាស់ច្រើន ដែលជាអំបូរជនជាតិដើមភាគតិចតូចៗ។ នៅឆ្នាំ២០១៣ ប្រជាជនវ័យចាស់មានដល់ទៅជិត២៨% ក្នុងចំណោមជនជាតិស្អូច និង១០%ក្នុងចំណោមជនជាតិចាអុង។

**តារាងទី២០. ភាគរយមនុស្សចាស់ទៅតាមអំបូរជនជាតិដើមភាគតិច**

| អំបូរជនជាតិដើមភាគតិច ដែលមានមនុស្សចាស់១០០នាក់ឡើងទៅ | ភាគរយមនុស្សចាស់ | | | ចំនួនមនុស្សចាស់សរុប |
|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | |
| ព្នង | ៤,១ | ៤,៤ | ៤,២ | ១.៥៩៣ |
| កួយ | ៤,៧ | ៦,២ | ៥,៤ | ១.៥៥៤ |
| ទំពួន | ៤,៩ | ៤,៥ | ៤,៧ | ១.៤៥៤ |
| ចារាយ | ៤,៥ | ៥,៦ | ៥,១ | ១.៣៣៨ |
| គ្រឹង | ៦,៦ | ៦,២ | ៦,៤ | ១២៨ |
| ព្រៅ | ៥,៧ | ៦,៣ | ៦,០ | ៥៤៣ |
| ស្ទៀង | ៦,៩ | ៧,១ | ៧,០ | ៤៥៨ |
| កាវ៉ែត | ៤,៩ | ៨,៥ | ៦,៨ | ៤២៣ |
| ចាអុង | ៩,៨ | ៩,៩ | ៩,៩ | ១៨១ |
| ក្រោល | ៤,៤ | ៤,០ | ៤,២ | ១៧៧ |
| ស្អូច | ២៥,២ | ២៩,៤ | ២៧,៩ | ១២៤ |
| មិល | ៦,២ | ៧,០ | ៦,៦ | ១១២ |
| ព័រ | ៤,៣ | ៧,១ | ៥,៧ | ១០៥ |

## ៣. ប្រជាជនវ័យចាស់តាមរាជធានីខេត្ត

ភាគរយនៃជនជាតិដើមភាគតិចដែលមានវ័យចាស់ ខុសគ្នាគួរឱ្យកត់សម្គាល់ពីខេត្តមួយទៅខេត្តមួយ ដែលខេត្តខ្លះមានរហូតដល់ទៅជាង១ភាគ៤នៃប្រជាជនជនជាតិដើមភាគតិចសរុបក្នុងខេត្ត (គឺមានខេត្តត្បូងឃ្មុំ តាកែវ ព្រៃវែង និងសៀមរាប) និងខេត្តខ្លះដែលប្រជាជនជនជាតិដើមភាគតិចមានចំនួនតិចគ្មានប្រជាជនវ័យចាស់។

## តារាងទី២១.    របាយមនុស្សចាស់តាមខេត្ត ឆ្នាំ២០១៣

| | ចំនួនប្រជាជនសរុប | ចំនួនមនុស្សចាស់ | ភាគរយមនុស្សចាស់ | របាយភាគរយតាមខេត្ត |
|---|---|---|---|---|
| ត្បូងឃ្មុំ | ៨៩២ | ៥៥៧ | ៦២,៤ | ៤,៥ |
| តាកែវ | ១.០១៧ | ៤៩៩ | ៤៩,១ | ៤,០ |
| ព្រៃវែង | ១.០៤២ | ៣៥៨ | ៣៤,៤ | ២,៩ |
| សៀមរាប | ១.៥៤៤ | ៤៩៩ | ៣២,៣ | ៤,០ |
| កំពត | ៤៧៤ | ១១៥ | ២៤,៣ | ០,៩ |
| កំពង់ចាម | ៩៨៦ | ២៣៧ | ២៤,០ | ១,៩ |
| កណ្ដាល | ១.០១៦ | ១៦៥ | ១៦,២ | ១,៣ |
| កំពង់ស្ពឺ | ១.៥០៣ | ២៣៦ | ១៥,៧ | ១,៩ |
| ភ្នំពេញ | ១.៧៥២ | ១៩៩ | ១១,៤ | ១,៦ |
| ឧត្ដរមានជ័យ | ៣០១ | ៣២ | ១០,៦ | ០,៣ |
| កំពង់ធំ | ៧.៥៨៥ | ៧៩៤ | ១០,៥ | ៦,៤ |
| ក្រចេះ | ១៤.៣១៨ | ១.០៩២ | ៧,៦ | ៨,៨ |
| ព្រះវិហារ | ៦.១៨៦ | ៤៦៣ | ៧,៥ | ៣,៧ |
| ស្ទឹងត្រែង | ៨.៦៣១ | ៦២៣ | ៧,២ | ៥,០ |
| រតនគិរី | ៩២.៣៨៨ | ៥១៥ | ៥,៦ | ៤១,៥ |
| មណ្ឌលគិរី | ៤០.៧៧៤ | ១.៣៨៧ | ៣,៤ | ១១,២ |
| បន្ទាយមានជ័យ | ៧១០ | ០ | ០,០ | ០,០ |
| បាត់ដំបង | ៧៨០ | ០ | ០,០ | ០,០ |
| កំពង់ឆ្នាំង | ១.០៤៤ | ០ | ០,០ | ០,០ |
| កោះកុង | ៣៨ | ០ | ០,០ | ០,០ |
| ពោធិ៍សាត់ | ៥១៤ | ០ | ០,០ | ០,០ |
| ព្រះសីហនុ | ១០៩ | ០ | ០,០ | ០,០ |
| ស្វាយរៀង | ១៧៦ | ០ | ០,០ | ០,០ |
| កែប | ១៥ | ០ | ០,០ | ០,០ |
| ប៉ៃលិន | ៣៥ | ០ | ០,០ | ០,០ |
| **សរុប** | ១៨.៣៨៣ | ១២.៤០៦ | ៦,៧ | ១០០,០ |

( CIPS 2013)

# ៣. ស្ថានភាពសង្គម-សេដ្ឋកិច្ច

ស្ថានភាពសង្គម-សេដ្ឋកិច្ច គឺជារង្វាស់សមាសអំពីស្ថានភាពសង្គមនិងស្ថានភាពសេដ្ឋកិច្ចរបស់បុគ្គលឬគ្រួសារនៅក្នុងសង្គម។ ជាទូទៅ ស្ថានភាពសង្គម-សេដ្ឋកិច្ចមានសមាសធាតុជាច្រើន ហើយការកំណត់សូចនាករនៃសមាសធាតុស្ថានភាពសង្គម-សេដ្ឋកិច្ច អាស្រ័យទៅលើគោលដៅនៃការសិក្សា និងមុខងារនៃសូចនាករទាំងនោះនៅក្នុងការសិក្សា (ជាកត្តាបង្កឬជាលទ្ធផល)។ ទោះយ៉ាងណាក៏ដោយ សមាសធាតុចម្បងៗនៃស្ថានភាពសង្គម-សេដ្ឋកិច្ច ច្រើនមានការអប់រំ សុខភាព មុខរបរ ប្រាក់ចំណូលឬទ្រព្យសម្បត្តិ និង ឋានៈឬតួនាទីក្នុងសង្គម។

ដោយអាស្រ័យលើទិន្នន័យដែលមាន ការសិក្សានេះនឹងបរិយាយអំពីសមាសធាតុនៃស្ថានភាពសង្គម-សេដ្ឋកិច្ចមួយចំនួនរបស់ជនជាតិដើមភាគតិច គឺ ការអប់រំ សុខភាព ការងារ និងសាសនា។

## ៣.១. ការអប់រំ

មានសូចនាករមួយចំនួនដែលអាចប្រើដើម្បីសិក្សាអំពីស្ថានភាពអប់រំរបស់ប្រជាជនបាន ដូចជាចំនួនឆ្នាំឬកម្រិតថ្នាក់ខ្ពស់បំផុតដែលបានរៀនចប់ ដែលជារង្វាស់មួយនៃការទទួលបានការអប់រំ។ អត្រាអក្ខរភាព អត្រាចូលរៀន និងអត្រាបោះបង់ការសិក្សា ក៏ជាសូចនាករនៃការអប់រំដែរ។

### *៣.១.១. អត្រាអក្ខរភាព*

អត្រាអក្ខរភាពក្នុងក្រាហ្វិកខាងក្រោម បង្ហាញពីភាគរយនៃជនជាតិដើមភាគតិចដែលចេះអាននិងចេះសរសេរភាសាខ្មែរ ក្នុងចំណោមប្រជាជនអាយុ៧ឆ្នាំឡើង (អត្រាអក្ខរភាពមនុស្សទូទៅ) និងក្នុងចំណោមប្រជាជនអាយុ១៥ឆ្នាំឡើង (អត្រាអក្ខរភាពមនុស្សពេញវ័យ) នៅឆ្នាំ២០១៣។ ក្នុងចំណោមជនជាតិដើមភាគតិចអាយុ៧ឆ្នាំឡើង ៣៤.៣%ចេះអាននិងសរសេរភាសាខ្មែរ (៤១,៩%ក្នុងចំណោមបុរសនិង២៧,៣%ក្នុងចំណោមស្ត្រី)។ ក្នុងចំណោមជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ៣៣.៨%ចេះអាននិងសរសេរភាសាខ្មែរ (៤៣,៨%ក្នុងចំណោមបុរសនិង២៤,៦%ក្នុងចំណោមស្ត្រី)។ ដូច្នេះ មានជនជាតិដើមភាគតិចទាំងពីរភេទប្រហែល១ភាគ៣ប៉ុណ្ណោះ ដែលចេះអាននិងសរសេរភាសាខ្មែរ ហើយបុរសជាទូទៅមានអត្រាអក្ខរភាពខ្ពស់ជាងស្ត្រី។

ក្រាហ្វិកទី១៥. អត្រាអក្ខរភាពមនុស្សទូទៅនិងអក្ខរភាពមនុស្សពេញវ័យ ឆ្នាំ២០១៣




### ៣.១.២. អត្រាការចូលរៀន និងមិនបានចូលរៀន

ដោយយោងតាមតម្រូវការព័ត៌មានអំពីការសិក្សារបស់កុមារ ការបានចូលរៀននិងមិនបានចូលរៀនរួមទាំងការបោះបង់ការសិក្សា ត្រូវបានគណនាចំពោះកុមារក្នុងក្រុមអាយុ៦-១៣ឆ្នាំ និង អាយុ៦-១៨ឆ្នាំដោយឡែកពីគ្នា ដោយប្រើប្រាស់ទិន្នន័យឆ្នាំ២០១៣។

ទិន្នន័យក្នុងតារាងខាងក្រោម បញ្ជាក់ឱ្យឃើញថាមានកុមារជនជាតិដើមភាគតិចជិត៥០% (ទាំងក្រុមអាយុ៦-១៣ឆ្នាំ និងអាយុ៦-១៨ឆ្នាំ) មិនដែលបានរៀនសោះ។ បើធៀបនឹងកម្ពុជាសរុប ចំនួននេះជិតស្មើនឹង៤ទៅ៥ដងនៃចំនួនកុមារកម្ពុជាសរុបដែលមិនបានរៀនសោះ (គឺ១៣%ក្នុងក្រុមអាយុ៦-១៣ឆ្នាំ និង ១០,៥៩%ក្នុងក្រុមអាយុ៦-១៨ឆ្នាំ ក្នុងចំណោមកុមារកម្ពុជាក្នុងវ័យដូចគ្នា)។ រីឯភាគរយកុមារជនជាតិដើមភាគតិចកំពុងនៅរៀនមានចំនួនតិចជាង៥០% (៤៩,០៣% ក្នុងក្រុមអាយុ៦-១៣ឆ្នាំ និង ៤៣,៥៦% ក្នុងក្រុមអាយុ៦-១៨ឆ្នាំ) ដែលក្នុងចំណោមកុមារកម្ពុជាសរុប តួលេខនេះស្មើនឹង ៨៥,១៥% ក្នុងចំណោមកុមារកម្ពុជាអាយុ៦-១៣ឆ្នាំ និង ៧៥,៣១% ក្នុងចំណោមកុមារកម្ពុជាអាយុ៦-១៨ឆ្នាំ។ នេះបញ្ជាក់ឱ្យឃើញថា ជនជាតិដើមភាគតិចបានទទួលការអប់រំតិច។

តារាងទី២២.	ភាគរយមិនបានរៀន កំពុងរៀន និងឈប់រៀន ឆ្នាំ២០១៣

| | ជនជាតិដើមភាគតិច | | កម្ពុជាសរុប | |
|---|---|---|---|---|
| | អាយុ៦-១៣ឆ្នាំ | អាយុ៦-១៨ឆ្នាំ | អាយុ៦-១៣ឆ្នាំ | អាយុ៦-១៨ឆ្នាំ |
| ចំនួនសរុប | ៣៨.៥៧៣ | ៦០.០៩៦ | ២.៤២៦.៧៣០ | ៣.៩៨៧.៦៩៨ |
| ភាគរយមិនបានរៀនសោះ | ៤៩,៤ | ៤៧,៩ | ១៣,០ | ១០,៦ |
| ភាគរយកំពុងរៀន | ៤៩,០ | ៤៣,៦ | ៨៥,២ | ៧៥,៣ |
| ភាគរយឈប់រៀន | ១,៦ | ៨,៦ | ១,៩ | ១៤,១ |
| **សរុប** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |

### ៣.១.៣. *អត្រាបោះបង់ការសិក្សាតាមអាយុនិងតាមភេទ*

តារាងទី២២ខាងលើអំពីភាគរយមិនបានរៀន កំពុងរៀន និងឈប់រៀន និង ក្រាហ្វិកទី១៦ខាងក្រោមអំពីការបោះបង់ការសិក្សាតាមអាយុពី៦ឆ្នាំដល់១៨ឆ្នាំ បង្ហាញថា បញ្ហានៃការអប់រំដែលកុមារជនជាតិដើមភាគតិចអាយុក្រោម១៥ឆ្នាំកំពុងជួបប្រទះ មិនមែនជាការបោះបង់ការសិក្សា

ទេ តែជាការមិនបានចូលរៀនឬចូលរៀនយឺត ពីព្រោះជិត៥០%នៃកុមារជនជាតិដើមភាគតិច មិនបានរៀនអ្វីទាំងអស់ (តារាងទី២២ខាងលើ) តែអត្រាបោះបង់ការសិក្សាក្នុងចំណោមកុមារអាយុក្រោម១៥ឆ្នាំដែលបានចូលរៀន មានកម្រិតទាប (ក្រាហ្វិកខាងក្រោម)។

ជាក់ស្តែង ក្នុងចំណោមកុមារដែលបានចូលរៀន ការបោះបង់ការសិក្សា[៤]មានតិចតួច ក្នុងចំណោមក្មេងប្រុសអាយុក្រោម១៤ឆ្នាំ និងក្នុងចំណោមក្មេងស្រីអាយុក្រោម១៥ឆ្នាំ។ ក៏ប៉ុន្តែ ការបោះបង់ការសិក្សាចាប់ផ្តើមមានទំហំគួរឱ្យកត់សម្គាល់ចាប់ពីអាយុ១៤-១៥ឆ្នាំទៅ និងការបោះបង់ការសិក្សាច្រើនបំផុតត្រូវបានសង្កេតឃើញនៅក្នុងក្រុមអាយុ១៦-១៨ឆ្នាំ។ ជាង៦០%នៃក្មេងប្រុសអាយុ១៧-១៨ឆ្នាំបានឈប់រៀន រីឯក្មេងស្រីច្រើនឈប់រៀននៅអាយុ១៦ឆ្នាំ (៦៥,៤%) និងជិត៥០%នៃក្មេងស្រីបានឈប់រៀននៅអាយុ១៧-១៨ឆ្នាំ ដែលនិន្នាការនៃការឈប់រៀននៅវ័យនេះក៏មានទំហំធំដូចគ្នាដែរ នៅក្នុងចំណោមស្ត្រីកម្ពុជា ជាទូទៅ។ ដូចនេះ ជាទិដ្ឋភាពរួម ការអភិវឌ្ឍធនធានជនជាតិដើមភាគតិចជាដំបូង ត្រូវផ្តោតជាចម្បងទៅលើការជំរុញឱ្យកុមារជនជាតិដើមភាគតិចបានចូលសាលារៀន។

[៤] អត្រាបោះបង់ការសិក្សាជាភាគរយអ្នកឈប់រៀនក្នុងចំណោមអ្នកបានរៀន គិតតាមអាយុនីមួយៗ។

ក្រាហ្វិកទី១៦.  អត្រាបោះបង់ការសិក្សាតាមអាយុរបស់កុមារជនជាតិដើមភាគតិចនៅឆ្នាំ២០១៣




### ៣.១.៤. ការចូលរៀនយឺតនិងរៀននៅកម្រិតទាបជាងអាយុ

ក្រៅពីបានចូលរៀនបានតិចនិងទទួលបានការអប់រំតិច  ជនជាតិដើមភាគតិចនៅបានទទួលការអប់រំយឺតយ៉ាវជាងវ័យសិក្សារបស់ខ្លួនច្រើនទៀតផង[៥] ដែលអាចបណ្ដាលមកពីការចូលរៀនយឺតឬការរៀនត្រួតថ្នាក់។ ក្រាហ្វិកខាងក្រោមបង្ហាញថា លើកលែងតែកុមារអាយុ៦ឆ្នាំ ដែលបានចូលរៀននៅថ្នាក់ទី១ សឹង១០០% កុមារអាយុ៧ដល់១៣ឆ្នាំជាច្រើន កំពុងរៀននៅកម្រិតថ្នាក់សិក្សាដែលទាបជាងអាយុរបស់ខ្លួន។ ជាក់ស្ដែង៖

- កុមារអាយុ៧ឆ្នាំចំនួន៤០,៧% កំពុងរៀននៅថ្នាក់ទី២ដែលត្រូវនឹងវ័យរបស់ខ្លួន ក្រៅពីនេះ កំពុងរៀននៅថ្នាក់ទី១។
- កុមារអាយុ៨ឆ្នាំចំនួន១៦,២% កំពុងរៀននៅថ្នាក់ទី៣ដែលត្រូវនឹងវ័យរបស់ខ្លួន ក្រៅពីនេះ កំពុងរៀននៅថ្នាក់ទី១និងទី២។

[៥] តាមប្រព័ន្ធអប់រំកម្ពុជា កុមារអាយុ៦ឆ្នាំត្រូវរៀនថ្នាក់ទី១ អាយុ៧ឆ្នាំរៀនថ្នាក់ទី២ អាយុ៨ឆ្នាំរៀនថ្នាក់ទី៣ ...អាយុ១៦ឆ្នាំរៀនថ្នាក់ទី១១ និងអាយុ១៧ឆ្នាំរៀនថ្នាក់ទី១២។

- កុមារអាយុ៩ឆ្នាំចំនួន៨,៦% កំពុងរៀននៅថ្នាក់ទី៤ដែលត្រូវនឹងវ័យរបស់ខ្លួន ក្រៅពីនេះ ៣៥,៨% កំពុងរៀននៅថ្នាក់ទី៣ និង៥៥,៦% កំពុងរៀននៅថ្នាក់ទី២និងទី១។
- កុមារអាយុ១០ឆ្នាំចំនួន៧,៤% កំពុងរៀននៅថ្នាក់ទី៥ដែលត្រូវនឹងវ័យរបស់ខ្លួន ក្រៅពីនេះ ១៨,៨% កំពុងរៀននៅថ្នាក់ទី៤ និងជាង៧០% កំពុងរៀននៅថ្នាក់ទី៣ ទី២ និងទី១។
- កុមារអាយុ១១ឆ្នាំចំនួន៥,៩% កំពុងរៀននៅថ្នាក់ទី៦ដែលត្រូវនឹងវ័យរបស់ខ្លួន ក្រៅពីនេះ ១២,៦% កំពុងរៀននៅថ្នាក់ទី៥ និងជាង៨០% កំពុងរៀននៅថ្នាក់ទី៤ចុះដល់ទី១។
- កុមារអាយុ១២ឆ្នាំចំនួន១,៤% កំពុងរៀននៅថ្នាក់ទី៧ដែលត្រូវនឹងវ័យរបស់ខ្លួន ក្រៅពីនេះ ៨,៤% កំពុងរៀននៅថ្នាក់ទី៦ និង៩០% កំពុងរៀននៅថ្នាក់ទី៥ចុះដល់ទី១។
- កុមារអាយុ១៣ឆ្នាំចំនួន១,៥% កំពុងរៀននៅថ្នាក់ទី៨ដែលត្រូវនឹងវ័យរបស់ខ្លួន ក្រៅពីនេះ ២,៣% កំពុងរៀននៅថ្នាក់ទី៧ និងជាង៩០% កំពុងរៀននៅថ្នាក់ទី៦ចុះដល់ទី១។

**ក្រាហ្វិកទី១៧. អាយុនិងកម្រិតសិក្សាកំពុងរៀន នៅឆ្នាំ២០១៣**



ក្រាហ្វិកទី១៨. របាយភាគរយជនជាតិដើមភាគតិចអាយុ៦-១៨ឆ្នាំ ដែលមិនបានចូលរៀន កំពុងរៀន និងឈប់រៀន តាមអំបូរធំៗឆ្នាំ២០១៣




## ៣.១.៥. ការទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ដំរឿនប្រជាសាស្ត្រនិងអង្កេតចន្លោះដំរឿន ប្រមូលទិន្នន័យអំពីចំនួនឆ្នាំឬកម្រិតថ្នាក់ខ្ពស់បំផុតដែលបានរៀនចប់ (Highest Year Completed and Highest Grade Completed) ក្នុងចំណោមប្រជាជនអាយុ៧ឆ្នាំឡើងៗ ទិន្នន័យខាងលើនេះ អាចប្រើដើម្បីបែងចែកការទទួលបានការអប់រំ ដូចខាងក្រោម៖

១. មិនបានរៀនសោះឬមិនបានរៀនចប់ថ្នាក់ណាមួយ
២. កម្រិតបឋមសិក្សា (ពីថ្នាក់ទី១ដល់ថ្នាក់ទី៦)
៣. កម្រិតមធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) (ពីថ្នាក់ទី៧ដល់ថ្នាក់ទី៩)
៤. ត្រឹមសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ (មានសញ្ញាប័ត្រឌីប្លូម)
៥. កម្រិតមធ្យមសិក្សាទុតិយភូមិ (ពីថ្នាក់ទី១០ដល់ថ្នាក់ទី១២)

៦. សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ (ប្រលងជាប់សញ្ញាប័ត្របាក់ឌុប)
៧. សញ្ញាប័ត្របណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស (មុនឬក្រោយមធ្យមសិក្សាទុតិយភូមិ)
៨. កម្រិតឧត្តមសិក្សា

ដោយហេតុថា ប្រជាជនក្នុងវ័យ៧-១៤ឆ្នាំ ភាគច្រើនកំពុងសិក្សាពីថ្នាក់ទី១ឬទី២ ដល់ថ្នាក់ទី៩ ដែលជាការអប់រំគ្រឹះ៩ឆ្នាំ (៩-year basic education) ការវិភាគការទទួលបានការអប់រំនៅក្នុងរបាយការណ៍នេះ ផ្តោតទៅលើក្រុមប្រជាជនអាយុ ១៥ឆ្នាំឡើង និង ក្រុមអាយុ២៥ឆ្នាំឡើង ជារួមនិងដោយបែងចែកតាមក្រុមអាយុ៥ឆ្នាំ។ ការគណនាការទទួលបានការអប់រំ ផ្អែកលើទិន្នន័យអំពីកម្រិតសិក្សាខ្ពស់បំផុតដែលបានបញ្ចប់ ជាពិសេសនៅក្នុងរបាយការណ៍នេះ មិនកំណត់នៅត្រឹមប្រជាជនធ្លាប់បានចូលសាលានោះទេ ពោលគឺសំដៅលើការទទួលបានការអប់រំក្នុងចំណោមប្រជាជនទាំងអស់ រាប់ទាំងប្រជាជនបានចូលសាលាទាំងប្រជាជនមិនបានចូលសាលានាពេលធ្វើអង្កេត ក្នុងន័យដើម្បីពិនិត្យមើលស្ថានភាពនៃការអប់រំនិងការទទួលបានការអប់រំរបស់ប្រជាជនទាំងអស់ នៅក្នុងវ័យដែលបានកំណត់។

ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ជិត៦៦%មិនបានរៀនឬបញ្ចប់កម្រិតសិក្សាអ្វីទាំងអស់ រីឯ២៤,១%ទៀតបានរៀនត្រឹមបឋមសិក្សាប៉ុណ្ណោះ។ ជាសរុប ៩០%បានរៀនតិចតួចឬមិនបានរៀនសោះ។ រីឯអ្នកបានរៀនយ៉ាងហោចណាស់ដល់កម្រិតមធ្យមសិក្សាបឋមភូមិមានចំនួនប្រហែល១០% ដែលក្នុងនោះអ្នករៀនបានកម្រិតមធ្យមសិក្សាទុតិយភូមិមានចំនួន៤% និងអ្នកបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួនក្រោម១%។ ទិន្នន័យឆ្នាំ២០១៣ មិនបានបង្ហាញថាមានជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងឬ២៥ឆ្នាំឡើង បានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈឬបច្ចេកទេសណាមួយនោះទេ[៦]។

បើប្រៀបធៀបជាមួយជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ជនជាតិដើមភាគតិចអាយុ២៥ឆ្នាំឡើងដែលមិនបានរៀនសោះឬបានរៀនត្រឹមកម្រិតសិក្សាបឋមភូមិមានចំនួនច្រើនជាង និងអ្នកដែលបានរៀនខ្ពស់ជាងកម្រិតសិក្សាបឋមភូមិមានចំនួនតិចជាង។ នេះបញ្ជាក់ថា ជនជាតិដើមភាគតិចវ័យក្មេង មានអត្រាទទួលបានការអប់រំល្អប្រសើរជាងជនជាតិដើមភាគតិចវ័យចាស់។

[៦] ទិន្នន័យជំរឿនឆ្នាំ២០០៨ បង្ហាញថាមានជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងប្រហែល៦០នាក់បានបញ្ចប់កម្រិតសិក្សាផ្សេងទៀត ដែលប្រហែលជាការបណ្តុះបណ្តាលវិជ្ជាជីវៈឬបច្ចេកទេសណាមួយ។

តារាងទី២៣.	កម្រិតសិក្សាអប់រំ និងវិជ្ជាជីវៈរបស់ប្រជាជនអាយុ១៥ឆ្នាំឡើងនិងអាយុ២៥ឆ្នាំឡើង ឆ្នាំ២០១៣

| | ជនជាតិដើមភាគតិច | | កម្ពុជាសរុប | |
|---|---|---|---|---|
| | អាយុ១៥ឆ្នាំឡើង | អាយុ២៥ឆ្នាំឡើង | អាយុ១៥ឆ្នាំឡើង | អាយុ២៥ឆ្នាំឡើង |
| ចំនួនសរុប | ១១៣.៣៣២ | ៧៦.០៨០ | ១០.៣៥៥.១៨៧ | ៧.១៨៣.២៤១ |
| ភាគរយ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| មិនបានរៀនសោះ | ៦៥,៨ | ៧៣,៥ | ២១,៣ | ២៦,៥ |
| បឋមសិក្សា (ថ្នាក់ទី១-៦) | ២៤,១ | ១៩,៣ | ៣៥,០ | ៣៦,៧ |
| មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) | ៦,០ | ៤,០ | ២៥,១ | ២១,៣ |
| សញ្ញាបត្រឌីប្លូម | ០,១ | ០,១ | ១,៥ | ១,៧ |
| មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) | ៣,២ | ២,៣ | ១១,៣ | ៨,៨ |
| សញ្ញាបត្របាក់ឌុប | ០,៨ | ០,៨ | ៣,២ | ២,២ |
| បណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស | ០,០ | ០,០ | ០,៦ | ០,៥ |
| ឧត្តមសិក្សា | ០,០ | ០,០ | ១,៨ | ២,២ |
| ផ្សេងទៀត | ០,០ | ០,០ | ០,១ | ០,១ |

### ៣.១.៦. ការទទួលបានការអប់រំ គិតតាមភេទ

យើងសង្កេតឃើញមានភាពខុសគ្នារវាងបុរសនិងស្ត្រីជនជាតិដើមភាគតិច អំពីការទទួលបានការអប់រំ ដែលជាទូទៅស្ត្រីទទួលបានការអប់រំទាបជាងបុរស ទាំងក្រុមអាយុ១៥ឆ្នាំឡើង ទាំងក្រុមអាយុ២៥ឆ្នាំឡើង។ បុរសអាយុ១៥ឆ្នាំឡើង ដែលមិនបានរៀនសោះឬរៀនមិនចប់ថ្នាក់ណាមួយមានចំនួន៥៦,៦% រីឯស្ត្រីមានដល់ទៅ៧៤,២%។ ក៏ប៉ុន្តែ បុរសអាយុ១៥ឆ្នាំឡើង ដែលបានរៀនត្រឹមបឋមសិក្សាមានដល់ទៅ ៣០,៨% ឯស្ត្រីមានតែ១៨,១%។ ជាសរុប ៨៧,៤%នៃបុរសមិនបានរៀនឬបានរៀនត្រឹមកម្រិតបឋមសិក្សា និង ៩២,៣%នៃស្ត្រីមិនបានរៀនឬបានរៀនត្រឹមកម្រិតបឋមសិក្សា។ ដូចនេះ អ្នកដែលបានរៀនលើសកម្រិតបឋមសិក្សាមានចំនួន១២,៦% ក្នុងចំណោមបុរស និង ៧,៧%ក្នុងចំណោមស្ត្រីអាយុ១៥ឆ្នាំ

ឡើង។ បើគិតក្នុងចំណោមប្រជាជនអាយុ២៥ឆ្នាំឡើង តួលេខនេះ មានចំនួន១០,៧%ក្នុងចំណោមបុរស និង ៤,១%ក្នុងចំណោមស្ត្រី។

**តារាងទី២៤. កម្រិតអប់រំខ្ពស់បំផុតដែលបានបញ្ចប់គិតតាមភេទ ឆ្នាំ២០១៣**

| កម្រិតអប់រំខ្ពស់បំផុតដែលបានបញ្ចប់ (%) | អាយុ១៥ឆ្នាំឡើង | | អាយុ២៥ឆ្នាំឡើង | |
|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី |
| មិនបានរៀនសោះ | ៥៦,៦ | ៧៤,២ | ៦២,២ | ៨៣,៤ |
| កម្រិតបឋមសិក្សា (ថ្នាក់ទី១-៦) | ៣០,៨ | ១៨,១ | ២៧,១ | ១២,៥ |
| កម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) | ៧,១ | ៥,០ | ៥,៥ | ២,៦ |
| សញ្ញាប័ត្រឌីប្លូម | ០,២ | ០,០ | ០,២ | ០,០ |
| កម្រិតមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) | ៤,៤ | ២,២ | ៤,២ | ០,៧ |
| សញ្ញាប័ត្របាក់ឌុបឡើងទៅ | ១,០ | ០,៦ | ០,៨ | ០,៨ |
| **សរុបភាគរយ** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |

## ៣.២. ការងារនិងស្ថានភាពសេដ្ឋកិច្ច

ដើម្បីស្វែងយល់ពីការងារនិងស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន របាយការណ៍នានារបស់ក្រសួងផែនការ បានបែងចែកប្រជាជនជាពីរប្រភេទ គឺប្រជាជនសកម្មសេដ្ឋកិច្ចនិងប្រជាជនអសកម្មសេដ្ឋកិច្ច។ យោងតាមរបាយការណ៍ទី៨ អំពីសកម្មភាពសេដ្ឋកិច្ចនិងការងារ របស់អង្កេតចន្លោះជំរឿនឆ្នាំ២០១៣[៧] ការបែងចែកមានដូចខាងក្រោម៖

### ក. ប្រជាជនសកម្មសេដ្ឋកិច្ច សំដៅដល់ប្រជាជនទាំងអស់៖

១. ដែលមានការងារធ្វើឬបានធ្វើការងារយ៉ាងតិច ៦ខែ (១៨៣ថ្ងៃ) ក្នុងរយៈពេល១ឆ្នាំមុនពេលប្រមូលទិន្នន័យ

២. ដែលធ្លាប់ធ្វើការពីមុន តែគ្មានការងារធ្វើនិងបានស្វែងរកការងារធ្វើ ឬដែលអាចធ្វើការបានយ៉ាងតិច ៦ខែ (១៨៣ថ្ងៃ) ក្នុងរយៈពេល១ឆ្នាំមុនពេលប្រមូលទិន្នន័យ

៣. មិនដែលធ្វើការសោះពីមុនមក តែអាចធ្វើការងារបាន

### ខ. ប្រជាជនអសកម្មសេដ្ឋកិច្ច សំដៅដល់ប្រជាជនទាំងអស់ ដែលជា៖

[៧] CIPS Report ៨: Economic Activity and Employment, ២០១៤, Pages ៦-៧

១. មេផ្ទះ

២. សិស្សនិស្សិត

៣. អ្នកក្នុងបន្ទុក

៤. អ្នកទទួលបានចំណូលតាមរយៈការជួលផ្សេងៗ ប្រាក់សោធននិវត្តន៍ ឬប្រាក់ចំណូលផ្សេងទៀត ជាទូទៅ

៥. អ្នកមិនសកម្មសេដ្ឋកិច្ចផ្សេងទៀត ដែលមិននៅក្នុងចំណាត់ថ្នាក់ណាមួយក្នុងចំណោមចំណាត់ថ្នាក់ទាំង៤ខាងលើ

### ***៣.២.១. ប្រជាជនសកម្មសេដ្ឋកិច្ចនិងអសកម្មសេដ្ឋកិច្ច***

តារាងខាងក្រោមបង្ហាញពីចំនួននិងភាគរយប្រជាជនសកម្មសេដ្ឋកិច្ចនិងអសកម្មសេដ្ឋកិច្ចនៅឆ្នាំ២០១៣ នៃប្រជាជនកម្ពុជានិងប្រជាជនជនជាតិដើមភាគតិចអាយុ៥ឆ្នាំឡើង និងអាយុ១៥ឆ្នាំឡើង។

ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចអាយុ៥ឆ្នាំឡើង ៦៣,២%ជាប្រជាជនសកម្មសេដ្ឋកិច្ច ដែលក្នុងនោះ ៦២,៨%ជាអ្នកមានការងារធ្វើ ០,៤%ជាអ្នកគ្មានការងារធ្វើ និង ៣៦,៨%ជាប្រជាជនអសកម្មសេដ្ឋកិច្ច។ ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ៨៧,១%ជាប្រជាជនសកម្មសេដ្ឋកិច្ច ដែលក្នុងនោះ ៨៦,៦%ជាអ្នកមានការងារធ្វើ ០,៥%ជាអ្នកគ្មានការងារធ្វើ និង១២,៩%ជាប្រជាជនអសកម្មសេដ្ឋកិច្ច។

**តារាងទី២៥. ប្រជាជនសកម្មនិងអសកម្មសេដ្ឋកិច្ចអាយុ៥ឆ្នាំឡើង និងអាយុ១៥ឆ្នាំឡើង ឆ្នាំ ២០១៣**

| | អាយុ៥ឆ្នាំឡើង | | អាយុ១៥ឆ្នាំឡើង | |
|---|---|---|---|---|
| | កម្ពុជាសរុប | ជនជាតិដើមភាគតិច | កម្ពុជាសរុប | ជនជាតិដើមភាគតិច |
| ភាគរយកម្លាំងពលកម្ម (ប្រជាជនសកម្មសេដ្ឋកិច្ច) | ៦២,២ | ៦៣,២ | ៧៩,៧ | ៨៧,១ |
| *ភាគរយមានការងារធ្វើ* | *៦០,៨* | *៦២,៨* | *៧៧,៨* | *៨៦,៦* |
| *ភាគរយគ្មានការងារធ្វើ* | *១,៤* | *០,៤* | *១,៨* | *០,៥* |
| ភាគរយមិនមែនកម្លាំងពលកម្ម (ប្រជាជនមិនសកម្មសេដ្ឋកិច្ច) | ៣៧,៨ | ៣៦,៨ | ២០,៣ | ១២,៩ |
| **ចំនួនប្រជាជនសរុប** | **១៣.៣៧៣.០០៣** | **១៦២.២១៣** | **១០.៣៥៥.១៩២** | **១១៣.៣៣៣** |

ធៀបនឹងប្រជាជនកម្ពុជាសរុប ភាគរយនៃប្រជាជនជនជាតិដើមភាគតិចដែលសកម្មសេដ្ឋកិច្ច និងដែលមានការងារធ្វើ មានចំនួនច្រើនជាងភាគរយនៃប្រជាជនកម្ពុជាសរុប ពិសេសក្នុងចំណោមប្រជាជនអាយុ១៥ឆ្នាំឡើង (អ្នកមានការងារធ្វើ ៨៦,៦%ទល់នឹង៧៧,៨%)។ ជាលទ្ធផល ប្រជាជនគ្មានការងារធ្វើឬអសកម្មសេដ្ឋកិច្ច ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិច មានចំនួនតិចជាងប្រជាជនកម្ពុជាសរុប (អ្នកគ្មានការងារធ្វើ ០,៥%ទល់នឹង១,៨% និង អ្នកអសកម្មសេដ្ឋកិច្ច ១២,៩%ទល់នឹង២០,៣%)។

### ៣.២.២. កម្លាំងពលកម្មតាមភេទ

ការចូលរួមក្នុងកម្លាំងពលកម្មរបស់ប្រជាជនជនជាតិដើមភាគតិច ខុសគ្នាតិចតួចរវាងបុរសនិងស្ត្រីអាយុ១៥ឆ្នាំឡើង (៨៨,៣%ក្នុងចំណោមបុរស និង ៨៦,១%ក្នុងចំណោមស្ត្រី)។ដូចគ្នាដែរ ចំពោះអត្រាមានការងារធ្វើ (៨៧,៧%ក្នុងចំណោមបុរស និង ៨៥,៥%ក្នុងចំណោមស្ត្រី) និង អត្រាគ្មានការងារធ្វើ (០,៦%ក្នុងចំណោមបុរស និង ០,៥%ក្នុងចំណោមស្ត្រី)។

**តារាងទី២៦. ប្រជាជនសកម្មសេដ្ឋកិច្ចតាមភេទ ឆ្នាំ២០១៣**

| | កម្ពុជាសរុប | | ជនជាតិដើមភាគតិច | |
|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី |
| កម្លាំងពលកម្ម | ៨៣,០ | ៧៦,៦ | ៨៨,៣ | ៨៦,១ |
| មានការងារធ្វើ | ៨១,៤ | ៧៤,៧ | ៨៧,៧ | ៨៥,៥ |
| គ្មានការងារធ្វើ | ១,៧ | ២,០ | ០,៦ | ០,៥ |
| មិនមែនកម្លាំងពលកម្ម | ១៧,០ | ២៣,៤ | ១១,៧ | ១៤,០ |

### ៣.២.៣. កម្លាំងពលកម្មតាមក្រុមអាយុនិងតាមភេទ

ការចូលរួមក្នុងកម្លាំងពលកម្មរបស់ប្រជាជនជនជាតិដើមភាគតិច មានទំហំគួរឱ្យកត់សម្គាល់ ទាំងក្រុមអាយុវ័យក្មេង ទាំងក្រុមអាយុពេញវ័យ និងក្រុមមនុស្សវ័យចាស់ (ក្រាហ្វិកខាងក្រោម)។ ក្នុងចំណោមប្រជាជនវ័យក្មេង (អាយុ១៥-២៤ឆ្នាំ) ស្ត្រីចូលរួមក្នុងកម្លាំងពលកម្មច្រើនជាងបុរស (ភាគរយប្រជាជនសកម្មសេដ្ឋកិច្ច មានចំនួន៨២,២%ក្នុងចំណោមស្ត្រី និង ៧៥,៤%ក្នុងចំណោមបុរស)។ ចាប់ពីអាយុ២៥ឆ្នាំដល់៥៤ឆ្នាំ ភាគរយនៃស្ត្រីចូលរួមក្នុងកម្លាំងពលកម្មមានចំនួនប្រហាក់ប្រហែលនឹងបុរស តែចាប់ពីអាយុ៥៥ឆ្នាំឡើងទៅ ភាគរយនៃស្ត្រីចូលរួមក្នុងកម្លាំងពលកម្មមានចំនួនតិចជាងបុរស។

ជាក់ស្តែងនៅឆ្នាំ២០១៣ បុរសជនជាតិដើមភាគតិចដែលមានអាយុ២៥-៥៤ឆ្នាំ មានចំនួនពី៩៦%ទៅ១០០%ជាបុរសសកម្មសេដ្ឋកិច្ច ដែលភាគរយនេះមានចំនួនពី៩៥%ដល់៩៩%ក្នុងចំណោម

ស្ត្រីជនជាតិដើមភាគតិច។ ចំពោះក្រុមអាយុ៥៥-៦៤ឆ្នាំ បុរសជនជាតិដើមភាគតិចដែលសកម្មសេដ្ឋកិច្ចមានចំនួន៩៣,៧% ឯស្ត្រីមានចំនួនត្រឹម៧៨,៦%ប៉ុណ្ណោះ។ ចំពោះក្រុមប្រជាជនវ័យចាស់អាយុ៦៥ឆ្នាំឡើង ជនជាតិដើមភាគតិចដែលសកម្មសេដ្ឋកិច្ចមានចំនួន៦៧,៣%ក្នុងចំណោមបុរស និង ៤៦,៨%ក្នុងចំណោមស្ត្រី។

**ក្រាហ្វិកទី១៩. កម្លាំងពលកម្មតាមភេទនិងក្រុមអាយុ ឆ្នាំ២០១៣**




### ៣.២.៤. ប្រជាជនសកម្មសេដ្ឋកិច្ចតាមអំបូរជនជាតិដើមភាគតិច

ក្រាហ្វិកខាងក្រោម បង្ហាញពីអត្រាចូលរួមកម្លាំងពលកម្ម (គឺប្រជាជនសកម្មសេដ្ឋកិច្ច) របស់ជនជាតិដើមភាគតិចនៅឆ្នាំ២០១៣ តាមអំបូរជនជាតិដើមភាគតិចនីមួយៗ ដោយរៀបតាមលំដាប់នៃចំនួនប្រជាជន ពីជនជាតិដែលមានប្រជាជនអាយុ១៥ឆ្នាំឡើងច្រើនជាងគេបង្អស់ (គឺជនជាតិទំពួន ដែលមានចំនួន២៩,៥១២នាក់) ទៅដល់ជនជាតិដែលមានប្រជាជនអាយុ១៥ឆ្នាំឡើងតិចជាងគេបង្អស់ (គឺជនជាតិព័រ ដែលមានប្រជាជនអាយុ១៥ឆ្នាំឡើងចំនួនត្រឹម២១៥នាក់ប៉ុណ្ណោះ)។ តាមក្រាហ្វិកនេះ យើង

ឃើញថា អត្រាប្រជាជនសកម្មសេដ្ឋកិច្ចតាមអំបូរជនជាតិនីមួយៗ ប្រែប្រួលទៅតាមប្រភេទអំបូរនិងទំហំប្រជាជន។

**ក្រាហ្វិកទី២០. ប្រជាជនសកម្មសេដ្ឋកិច្ចតាមអំបូរជនជាតិដើមភាគតិច ឆ្នាំ២០១៣**



ក្រាហ្វិកខាងលើបង្ហាញថា៖

- អំបូរដែលមានប្រជាជនច្រើន មានអត្រាចូលរួមកម្លាំងពលកម្មច្រើន ដែលជាទូទៅច្រើនជាងអត្រាចូលរួមកម្លាំងពលកម្មនៃប្រជាជនកម្ពុជាសរុប ដែលមានជិត៨០% (ក្រាហ្វិកទី២០ ខាងលើ)។ អំបូរជនជាតិទាំងនោះ មានទំពួន ព្នង គ្រឹង ព្រៅ កួយ ក្រោល និងការ៉ែត។
- អំបូរដែលមានប្រជាជនមធ្យម មានអត្រាចូលរួមកម្លាំងពលកម្មបង្គួរ (លើកលែងជនជាតិ កាជ្រូក) និងទាបជាងអត្រាចូលរួមកម្លាំងពលកម្មនៃប្រជាជនកម្ពុជាសរុប។ អំបូរជនជាតិទាំងនោះ មាន មិល ស្មៀង រដែ ស្អូច និងល្ងួន។
- អំបូរដែលមានប្រជាជនតិច (ក្រោម៥០០នាក់) មានអត្រាចូលរួមកម្លាំងពលកម្ម១០០%។ អំបូរជនជាតិទាំងនោះ មានលុន កាចក់ ចាអុង ខោញ និងព័រ។ ជនជាតិលុន មានអត្រាចូលរួមកម្លាំងពលកម្មទាបជាងគេបង្អស់ គឺត្រឹមតែ ៤៣,៦%ប៉ុណ្ណោះ។

### ៣.២.៥. អត្រាគ្មានការងារធ្វើតាមភេទនិងក្រុមអាយុ

អត្រាគ្មានការងារធ្វើ គឺជាចំនួនអ្នកគ្មានការងារធ្វើ (តាមនិយមន័យខាងលើ) ក្នុងចំណោមប្រជាជនសកម្មសេដ្ឋកិច្ច១០០នាក់។ អត្រាគ្មានការងារធ្វើរបស់ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងនៅឆ្នាំ ២០១៣ មានចំនួនតិចតួចណាស់ គឺត្រឹមតែ០,៦%ប៉ុណ្ណោះ។ ស្ត្រីជនជាតិដើមភាគតិច ជាទូទៅមានអត្រាគ្មានការងារធ្វើទាបជាងបុរសជនជាតិដើមភាគតិច លើកលែងតែក្នុងក្រុមអាយុ ២៥-៣៤ឆ្នាំ ដែលអត្រានេះមានចំនួន១%ក្នុងចំណោមស្ត្រី និង ០,៤%ក្នុងចំណោមបុរស។

**ក្រាហ្វិកទី២១. អត្រាគ្មានការងារធ្វើតាមអាយុនិងភេទ ឆ្នាំ២០១៣**



ភាពខុសគ្នាដែលគួរឱ្យកត់សម្គាល់មួយទៀតនៃអត្រាគ្មានការងារធ្វើរវាងបុរសនិងស្ត្រី គឺស្ថិតក្នុងចំណោមប្រជាជនអាយុ១៥-២៤ឆ្នាំ ដែលបុរសមានចំនួន១,១% និង ស្ត្រីមានចំនួនត្រឹម០,៤%។ ក្នុងចំណោមប្រជាជនអាយុ៣៥-៥៤ឆ្នាំ អត្រាគ្មានការងារធ្វើក្នុងចំណោមបុរសមានត្រឹមតែ០,២%ប៉ុណ្ណោះ ឯក្នុងចំណោមស្ត្រីមានចំនួយ០,៤%។

### ៣.២.៦. អត្រាគ្មានការងារធ្វើតាមអំបូរជនជាតិដើមភាគតិច

គិតតាមអំបូរជនជាតិ ជនជាតិដើមភាគតិចជាច្រើនអំបូរ មានអត្រាគ្មានការងារធ្វើស្មើនឹង 0% ក្នុងចំណោមប្រជាជនអាយុ១៥ឆ្នាំឡើង នៅឆ្នាំ២០១៣។ ជនជាតិដែលមានអត្រាគ្មានការងារធ្វើច្រើនជាងគេ គឺស្មៀង (៥,១%) ព្រៅ (២,៨%) និង ចារាយ (១%)។

**ក្រាហ្វិកទី២២. អត្រាគ្មានការងារធ្វើតាមអំបូរជនជាតិ**



### ៣.២.៧. ស្ថានភាពការងាររបស់ជនជាតិដើមភាគតិច

ស្ថានភាពការងាររបស់ប្រជាជន ចែកជា៤ប្រភេទ៖ ១) ការងារជានិយោជក ២) ការងារមានប្រាក់ខែប្រាក់កម្រៃ ៣) ការងាររកស៊ីដោយខ្លួនឯង និង ៤) ការងារគ្មានប្រាក់ខែប្រាក់កម្រៃ។ យោងតាមទិន្នន័យឆ្នាំ២០១៣ (ក្រាហ្វិកទី២៣ខាងក្រោម) ជនជាតិដើមភាគតិចដែលប្រកបការងារជានិយោជកមាន ០,១% ធ្វើការងារមានប្រាក់ខែប្រាក់កម្រៃមាន៤,៦% ធ្វើការងារនិងប្រកបរបររកស៊ីដោយខ្លួនឯងមាន ៣៨% និង ធ្វើការងារដោយគ្មានប្រាក់ខែប្រាក់កម្រៃមាន៥៧,៣%។ ភាពខុសគ្នានៃយេនឌ័រអំពីស្ថានភាពការងារ មានគួរឱ្យកត់សម្គាល់ចំពោះការងាររកស៊ីដោយខ្លួនឯង និងការងារគ្មានប្រាក់ខែប្រាក់កម្រៃ។ បុរសភាគច្រើនធ្វើការងាររកស៊ីដោយខ្លួនឯង (៥៨,៩%) ឯស្ត្រីភាគច្រើនធ្វើការងារដោយគ្មានប្រាក់ខែប្រាក់កម្រៃ (៧៨,៤%)។

**ក្រាហ្វិកទី២៣. ស្ថានភាពការងារជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងមានការងារធ្វើឆ្នាំ២០១៣**



### ៣.២.៨. ការងារតាមវិស័យសេដ្ឋកិច្ច

គិតតាមវិស័យសេដ្ឋកិច្ច នៅឆ្នាំ២០១៣ ភាគច្រើនលើសលប់នៃជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើ ប្រកបរបរពាក់ព័ន្ធនឹងវិស័យកសិកម្ម (សរុប៩៣,៣% បុរស៩០,៦% និងស្ត្រី ៩៥,៩%)។ ជនជាតិដើមភាគតិចចំនួន១,៦%ប៉ុណ្ណោះ (បុរស១,៨% និងស្ត្រី១,៤%) ធ្វើការងារក្នុងវិស័យឧស្សាហកម្ម និង ៥,១%ធ្វើការងារក្នុងវិស័យសេវាកម្ម (បុរស៧,៦% និងស្ត្រី២,៨%) ។

**ក្រាហ្វិកទី២៤. ការងារតាមវិស័យសេដ្ឋកិច្ចនៃជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើង ឆ្នាំ២០១៣**




### ៣.២.៩. ការងារតាមផ្នែក

តាមទិន្នន័យជំរឿនឆ្នាំ២០០៨និងអង្កេតចន្លោះជំរឿនឆ្នាំ២០១៣ ការងាររបស់ប្រជាជនមានការងារធ្វើ ត្រូវបានបែងចែក ជា៨ផ្នែក៖ ១. រដ្ឋាភិបាល ២. អង្គភាពស្វយ័ត(សហគ្រាសរដ្ឋ) ៣. សហគ្រាសឯកជនក្នុងស្រុក ៤. សហគ្រាសបរទេស ៥. ស្ថាប័នមិនយកប្រាក់ចំណេញ ៦. ស្ថាប័នអន្តរជាតិនិងស្ថានទូត ៧. គ្រួសារ និង ៨. ផ្សេងទៀត។ ការវិភាគអំពីការងារតាមផ្នែករបស់ជនជាតិដើមភាគតិចឆ្នាំ២០១៣បង្ហាញថា ភាគច្រើនលើសលប់នៃជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើមានការងារធ្វើនៅសហគ្រាសឯកជនក្នុងស្រុក (៩៥,១%ក្នុងចំណោមបុរស និង ៩៨,០%ក្នុងចំណោមស្ត្រី)។ គ្មានជនជាតិដើមភាគតិចធ្វើការនៅស្ថាប័នមិនយកប្រាក់ចំណេញទេ និងមានតិចតួចធ្វើការងារនៅតាមផ្នែកនៃការងារផ្សេងទៀត។

**តារាងទី២៧. ផ្នែកនៃការងាររបស់ជនជាតិដើមភាគតិចដែលមានការងារធ្វើ ឆ្នាំ២០១៣**

| | ប្រុស | ស្រី | សរុប |
|---|---|---|---|
| សហគ្រាសឯកជនក្នុងស្រុក | ៩៥,១ | ៩៨,០ | ៩៦,៦ |
| រដ្ឋាភិបាល | ៣,៧ | ០,៦ | ២,១ |
| សហគ្រាសបរទេស | ០,៩ | ០,៩ | ០,៩ |
| ផ្នែកគ្រួសារ | ០,៣ | ០,៤ | ០,៤ |
| អង្គភាពស្វយ័ត | ០,០ | ០,១ | ០,០ |
| ស្ថាប័នមិនយកប្រាក់ចំណេញ | ០,០ | ០,០ | ០,០ |
| ស្ថានទូត/ស្ថាប័នអន្តរជាតិ | ០,០ | ០,០ | ០,០ |

### ៣.២.១០. *កម្រិតវប្បធម៌របស់ជនជាតិភាគតិចដែលមានការងារធ្វើ*

ក្នុងចំណោមជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើ ភាគច្រើនមិនបានរៀនសោះឬបានរៀនត្រឹមកម្រិតបឋមសិក្សា (៨៩,២%ក្នុងចំណោមបុរស ៩៥,៦%ក្នុងចំណោមស្ត្រី និង ៩២,៥% ក្នុងចំណោមប្រជាជនទាំងពីរភេទ)។ ជនជាតិដើមភាគតិច ដែលបានរៀនដល់កម្រិតអនុវិទ្យាល័យឬវិទ្យាល័យមានប្រហែល៧,៥% ដែលក្នុងនោះមាន១០,៧%ក្នុងចំណោមបុរស និង ៤,៣%ក្នុងចំណោមស្ត្រី។

**ក្រាហ្វិកទី២៥. កម្រិតវប្បធម៌របស់ជនជាតិដើមភាគតិចអាយុ១៥ឆ្នាំឡើងដែលមានការងារធ្វើ**



### *៣.២.១១. ប្រាក់ចំណូល*

គ្មានទិន្នន័យអំពីប្រាក់ចំណូលរបស់ជនជាតិដើមភាគតិចទេ ។

## ៣.៣. សុខភាពនិងអនាម័យ

នៅកម្ពុជា ពុំទាន់មានទិន្នន័យអំពីបញ្ហាសុខភាពរបស់ជនជាតិដើមភាគតិចទេ។ ជំរឿន និងអង្កេតចន្លោះជំរឿនរបស់ក្រសួងផែនការ ប្រមូលទិន្នន័យតែអំពីពិការភាព ដែលអាចយកមកសិក្សាពីពិការភាពរបស់ជនជាតិដើមភាគតិចបាន។ អង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជា ប្រមូលទិន្នន័យសំបូរបែបជាងគេអំពីសុខភាព គឺមានទិន្នន័យអំពីពិការភាព សុខភាពមាតា ការស្វែងរកសេវាសុខភាពនិងចំណាយ និងការថែទាំកុមារ។ ក៏ប៉ុន្តែ អង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជាមិនបានប្រមូលទិន្នន័យលម្អិតអំពីអំបូរជនជាតិដើមភាគតិចទេ ក្រៅពីសំណួរអំពីជនជាតិ ដែលសំដៅលើក្រុមជនជាតិភាគតិចដទៃទៀតក្នុងស្រុក ដែលមិនមែនជនជាតិឥស្លាម និងក្រុមពូជសាសន៍ភាគតិចដទៃទៀត (ដូចជាវៀតណាម ចិន ថៃ ជាដើម)។

ដោយសារកង្វះទិន្នន័យអំពីសុខភាពនៅក្នុងជំរឿន និងអង្កេតចន្លោះជំរឿនដូចបានរៀបរាប់ខាងលើ ព័ត៌មានមួយចំនួនអំពីសុខភាពរបស់ជនជាតិដើមភាគតិចសម្រាប់របាយការណ៍នេះ ត្រូវបានសាកល្បងទាញចេញពីទិន្នន័យអង្កេតសង្គម-សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៥ ដោយប្រើប្រាស់និយមន័យជនជាតិដើមភាគតិចជាក្រុមជនជាតិភាគតិចដទៃទៀតក្នុងស្រុក។ តាមនិយមន័យនេះ ជនជាតិភាគតិចក្នុងស្រុកមានចំនួន ២៤៣.៣៥៧នាក់ ស្មើនឹង ១,៦%នៃប្រជាជនកម្ពុជាសរុប នៅឆ្នាំ២០១៥។

### *៣.៣.១. ការមានជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ*

ក្នុងចំណោមជនជាតិភាគតិចក្នុងស្រុកទាំងអស់ ៣៤.១៤៣នាក់ធ្លាប់ឈឺក្នុងរយៈពេល៣០ថ្ងៃមុនពេលអង្កេតឆ្នាំ២០១៥ (ស្មើនឹង ១៤% នៃប្រជាជនជនជាតិភាគតិចក្នុងស្រុក)។ ជាសរុបនិងគិតតាមក្រុមអាយុ[៩] ភាគរយអ្នកធ្លាប់ឈឺមានចំនួនច្រើនក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ (មាន២២,៤%) ហើយថយចុះក្នុងចំណោមក្រុមអាយុ៥-១៤ឆ្នាំ (មាន១៩,១%) និង ក្រុមអាយុ១៥-៥៤ឆ្នាំ (មាន ៩,៦%) តែកើនឡើងខ្ពស់ក្នុងចំណោមក្រុមអាយុ៥៥ឆ្នាំឡើង (មាន២២,៥%)។ លទ្ធផលនេះបញ្ជាក់ថាកុមារនិងមនុស្សចាស់ឈឺច្រើនជាងគេ ឯមនុស្សក្នុងវ័យកម្លាំងពលកម្មឈឺតិចជាងគេ។

ក្រាហ្វិកខាងក្រោម ក៏បានបង្ហាញពីភាពខុសគ្នាគួរឱ្យកត់សម្គាល់មួយរវាងបុរសនិងស្ត្រីជនជាតិដើមភាគតិច អំពីការមានជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ។ កុមារានិងបុរសវ័យចាស់ ជាទូទៅឈឺច្រើនជាងកុមារីនិងស្ត្រីវ័យចាស់ប្រហែល២ដង៖ នៅវ័យ០-៤ឆ្នាំ (៣០,៦% ទល់នឹង ១៧,៤%) នៅវ័យ៥-១៤ឆ្នាំ

[៩] ការកំណត់យកក្រុមអាយុនេះ ផ្អែកលើ ភាពងាយឬមិនងាយឈឺនៃវ័យនីមួយៗ។

(២៤,០% ទល់នឹង ១០,២%)និង ៥៥ឆ្នាំឡើង (៣១,៥% ទល់នឹង ១៤,៨%)។ តែបុរសក្នុងវ័យកម្លាំងពលកម្មឈឺតិចជាងស្ត្រី (៥,១% ទល់នឹង ១៣,៨%)។ កុមារដែលឈឺច្រើនជាងកុមារី អាចបណ្តាលមកពីកុមារច្រើនតាមឪពុកម្តាយចេញទៅធ្វើការងារកសិកម្មឬការងារប្រមូលអនុផលព្រៃឈើផ្សេងៗ[៩]។

**ក្រាហ្វិកទី២៦. ភាគរយមានជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ តាមភេទនិងក្រុមអាយុ ឆ្នាំ២០១៥**




### ៣.៣.២. ជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ

អ្នកដែលធ្លាប់ឈឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ ត្រូវបានសួរបន្តអំពីជំងឺដែលឈឺ ដែលក្នុងនោះមានជំងឺចំនួន១៧ ត្រូវបានរាយការណ៍នៅក្នុងទិន្នន័យឆ្នាំ២០១៥។ ការប្រៀបធៀបពីជំងឺរវាងប្រជាជនជនជាតិភាគតិចក្នុងស្រុកនិងប្រជាជនកម្ពុជាសរុប បង្ហាញនូវភាពខុសគ្នាគួរឱ្យកត់សម្គាល់មួយចំនួន (ក្រាហ្វិកទី២៧)។

- ទីមួយ ជនជាតិដើមភាគតិចដែលឈឺចំនួន៧៦% រាយការណ៍ថាឈឺជំងឺចំនួន៨ប៉ុណ្ណោះ (ធៀបនឹងប្រជាជនកម្ពុជា ដែលមានចំនួន៤២,៩%ប៉ុណ្ណោះ ដែលឈឺជំងឺ៨មុខនេះ)។
- ទីពីរ ធៀបនឹងប្រជាជនកម្ពុជាសរុបដែលឈឺ ជនជាតិដើមក្នុងស្រុកដែលឈឺជំងឺគ្រុនចាញ់ មានចំនួនជិត៣០% ធៀបនឹងប្រជាជនកម្ពុជាដែលមានចំនួនត្រឹម២,៥% (ច្រើនជាងប្រជាជនកម្ពុជាសរុប ១២ដង) និងដែលឈឺជំងឺរបេង មានចំនួន៧,៤% ធៀបនឹងប្រជាជនកម្ពុជាដែលមានចំនួនត្រឹម១,៣% (ច្រើនជាងប្រជាជនកម្ពុជាសរុប ជិត៦ដង)។

[៩] នេះជាការលើកឡើងដោយក្រុមជនជាតិដើមភាគតិចនៅក្នុងសិក្ខាសាលាផ្ទះបញ្ចាំងលទ្ធផលនៃរបាយការណ៍នេះ។

- ទីបី ភាគច្រើននៃជនជាតិដើមក្នុងស្រុកដែលឈឺ ច្រើនឈឺជំងឺគ្រុនចាញ់ ជំងឺផ្លូវដង្ហើម និងជំងឺគ្រុនសន្និ ដែលជាសរុបមានអ្នកឈឺជំងឺទាំង៣នេះ ចំនួន៥៧,១%នៃអ្នកឈឺ (ធៀបនឹងប្រជាជនកម្ពុជាសរុបដែលមានត្រឹម២៦%ប៉ុណ្ណោះ។

**ក្រាហ្វិកទី២៧. ជំងឺក្នុងរយៈ៣០ថ្ងៃចុងក្រោយ ឆ្នាំ២០១៥**




### ***៣.៣.៣. ការរកសេវាពិគ្រោះព្យាបាលជំងឺ***

កាលណាវ័យកាន់តែចាស់ ភាគរយនៃអ្នកមានជំងឺយូរលើសមួយឆ្នាំ មានកាន់តែច្រើន (៨២%ក្នុងចំណោមមនុស្សអាយុ៥៥ឆ្នាំឡើង ៤៥,៨%ក្នុងចំណោមមនុស្សអាយុ១៥-៥៤ឆ្នាំ និង ២១,៦%ក្នុងចំណោមមនុស្សអាយុ៥-១៤ឆ្នាំ) យោងតាមទិន្នន័យឆ្នាំ២០១៥។ ក៏ប៉ុន្តែ ជនជាតិដើមភាគតិចវ័យចាស់ដែលបានទៅរកសេវាព្យាបាល មានចំនួនតិចជាងជនជាតិដើមភាគតិចវ័យក្មេង។

ជាក់ស្តែង ក្នុងចំណោមជនជាតិដើមក្នុងស្រុកទាំងអស់ កុមារអាយុក្រោម៥ឆ្នាំដែលឈឺ សុទ្ធតែបាននាំទៅរកសេវាពិគ្រោះព្យាបាលទាំងអស់ (១០០%)។ តួលេខនេះ មានចំនួន៩៥,%ក្នុងចំណោមប្រជាជនអាយុ៥-១៤ឆ្នាំ ៩៤%ក្នុងចំណោមប្រជាជនអាយុ១៥-៥៤ឆ្នាំ និង៩០,៥%ក្នុងចំណោមប្រជាជនវ័យ៥៥ឆ្នាំឡើង។ ការទៅរកសេវាព្យាបាលតិចក្នុងចំណោមមនុស្សចាស់ អាចបណ្តាលមកពីការមានជំងឺរ៉ាំរ៉ៃច្រើនក្នុងចំណោមមនុស្សវ័យចាស់។

សេវាសុខភាពដែលបានទៅរកមុនគេ គឺឱសថស្ថាន (មាន២៧,៨%) មន្ទីរពេទ្យរដ្ឋ (មន្ទីរពេទ្យខេត្តមាន១៩,៣% និងមន្ទីរពេទ្យបង្អែកស្រុកមាន១៥,៥%) និងគ្លីនិកឯកជន (មាន១៧,៦%)។ ការកត់សម្គាល់មួយគឺ ជនជាតិដើមភាគតិចមិនសូវបានទៅរកសេវាពិគ្រោះនិងព្យាបាលជំងឺនៅមណ្ឌលសុខភាព

ឡើយ (គឺមានត្រឹម ៣% នៃអ្នកធ្លាប់ឈឺក្នុងរយៈ៣០ថ្ងៃមុនពេលធ្វើអង្កេតឆ្នាំ២០១៥ ប៉ុណ្ណោះ) (ក្រាហ្វិកទី២៩)។

ក្រាហ្វិកទី២៨. ការរកសេវាពិគ្រោះព្យាបាលនិងរយៈពេលមានជំងឺ ឆ្នាំ២០១៥




ក្រាហ្វិកទី២៩. *សេវាសុខភាពដែលបានទៅរកមុនគេពេលឈឺ (២០១៥)*



### ៣.៣.៤. ការទទួលបានសេវាសុខភាពមាតា

អង្កេតសង្គមកិច្ចសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៥ មានទិន្នន័យខ្លះៗអំពីការទទួលបានសេវាសុខភាពរបស់មាតា (អ្នកផ្តល់សេវាថែទាំគភ៌ ទីកន្លែងសម្រាលកូន និងវត្តមានបុគ្គលិកសុខាភិបាលពេលសម្រាល) និងទិន្នន័យអំពីសុខភាពកុមារអាយុក្រោម២ឆ្នាំ (ការបំបៅដោះកូន ការចិញ្ចឹមកូន និងការចាក់ថ្នាំបង្ការ)។ ទិន្នន័យទាំងនេះ ត្រូវបានប្រមូលពីស្ត្រីដែលមានកូនអាយុក្រោម៥ឆ្នាំ នាពេលធ្វើអង្កេតឆ្នាំ២០១៥។

**ក្រាហ្វិកទី៣០. សេវាថែទាំគភ៌ចុងក្រោយ ឆ្នាំ២០១៥**




ក្រាហ្វិកខាងលើបង្ហាញពីការទទួលបានសេវាថែទាំគភ៌ចុងក្រោយ របស់ស្ត្រីដែលមានកូនអាយុក្រោម៥ឆ្នាំ នាពេលធ្វើអង្កេតនៅឆ្នាំ២០១៥។ ភាគច្រើននៃស្ត្រីជនជាតិភាគតិច ទទួលសេវាថែទាំគភ៌ពីឆ្មប (៥៨,៨%) ឆ្មបបុរាណ (២០,៦%) និងពីគិលានុបដ្ឋាយិកា (១២,៩%)។ ជាការប្រៀបធៀប ស្ត្រីជនជាតិភាគតិចច្រើនទទួលសេវាថែទាំគភ៌ពីឆ្មបបុរាណច្រើនជាងស្ត្រីកម្ពុជាសរុប (២០,៦% ទល់នឹង ២%) និងទទួលសេវាថែទាំគភ៌ពីវេជ្ជបណ្ឌិតតិចជាងស្ត្រីកម្ពុជាសរុប (៦% ទល់នឹង ២៧%)។

ផ្អែកលើព័ត៌មានអំពីការសម្រាលកូនចុងក្រោយ ជនជាតិភាគតិចច្រើនសម្រាលកូននៅតាមផ្ទះ (៥៣%) និងសម្រាលកូននៅមន្ទីរពេទ្យ (៣៨%)។ ការសម្រាលកូននៅមណ្ឌលសុខភាព មានចំនួនត្រឹម ៦%ប៉ុណ្ណោះ ដែលភាគរយដ៏តិចនេះ អាចបណ្តាលមកពីជនជាតិដើមភាគតិចរស់នៅតំបន់ជនបទឬដាច់ស្រយ៉ាល ដែលមានត្រឹមតែប៉ុស្តិ៍សុខភាព ដែលគ្មានលទ្ធភាពផ្តល់សេវាសម្រាលបាន។

ក្រាហ្វិកទី៣១.  ទីកន្លែងសម្រាលចុងក្រោយ




### ***៣.៣.៥. ការបំបៅដោះនិងការចិញ្ចឹមកូន***

ចំពោះកំណើតកូនចុងក្រោយ (កូនដែលមានអាយុក្រោម២ឆ្នាំនាពេលធ្វើអង្កេតឆ្នាំ២០១៥) ស្ត្រីជាម្តាយសុទ្ធតែបានបំបៅកូនដោយទឹកដោះម្តាយទាំងអស់ (គឺ១០០% ក្នុងចំណោមម្តាយចំនួន ៨.៩៦៩ នាក់ ដែលបានសម្ភាសន៍)។ ស្ត្រីជាម្តាយដែលបានចាប់ផ្តើមបំបៅដោះកូនបន្ទាប់ពីកើតភ្លាម មានចំនួន ៣២,២% នៃម្តាយ (គឺបានចាប់ផ្តើមបំបៅដោះកូនក្នុងរយៈពេលតិចជាង១ម៉ោងក្រោយកើត) មានចំនួន ៥៦,៤%នៅក្នុងអំឡុង២ម៉ោងក្រោយកើត និងមានចំនួន១១,៤%ក្នុងអំឡុង៥-៦ម៉ោងក្រោយកើត។ ជាពិសេសទៅទៀត ម្តាយដែលមានកូនអាយុក្រោម២ឆ្នាំទាំងអស់ នៅបន្តបំបៅដោះកូននៅឡើយ នាពេលធ្វើអង្កេត (១០០%)[១០]។

ស្ត្រីជនជាតិភាគតិច ចិញ្ចឹមកូនតូចដោយពឹងផ្អែកលើទឹកដោះម្តាយទាំងស្រុង។ នៅពេលសួរថា តើម្តាយបានឱ្យអាហារអ្វីខ្លះទៅកូននាថ្ងៃម្សិលមិញ (១ថ្ងៃមុនថ្ងៃធ្វើអង្កេត) ស្ត្រីជាម្តាយឆ្លើយដូចខាងក្រោម៖

- មិនបានឱ្យកូនបៅទឹកដោះគោម្សៅ (១០០%នៃម្តាយ)

[១០] ទិន្នន័យអង្កេតសង្គមកិច្ចសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៥

- មិនបានឱ្យកូនបៅទឹកដោះគោខាប់ (១០០%នៃម្តាយ)
- មិនបានឱ្យកូនហូបផ្លែឈើជាអាហារ (១០០%នៃម្តាយ)
- មិនបានឱ្យកូនផឹកទឹក (៧៧%នៃម្តាយ)

### ៣.៣.៦. ពិការភាព

យោងតាមទិន្នន័យជំរឿនឆ្នាំ២០០៨ និងអង្កេតចន្លោះជំរឿនឆ្នាំ២០១៣ ជនជាតិដើមភាគតិចដែលពិការពីកំណើតឬក្រោយកំណើត មានចំនួន១.៦៧៣នាក់នៅឆ្នាំ២០០៨ (ស្មើនឹង១,៣៥%នៃប្រជាជនជនជាតិដើមភាគតិចសរុប) និង ចំនួន ២.៨២៧នាក់នៅឆ្នាំ២០១៣ (ស្មើនឹង១,៥៤%នៃប្រជាជនជនជាតិដើមភាគតិចសរុប)។ ក្នុងនោះ អ្នកពិការក្រោយកំណើតមានចំនួនជិត៧០%នៃអ្នកពិការទាំងអស់ (ទិន្នន័យឆ្នាំ២០០៨)។ ភាគរយជនជាតិដើមភាគតិចដែលពិការពីកំណើតឬក្រោយកំណើត គឺតិចជាងភាគរយអ្នកពិការក្នុងចំណោមប្រជាជនកម្ពុជាសរុប ដែលមានចំនួន ១,៤%នៅឆ្នាំ២០០៨ និង១,៩%នៅឆ្នាំ២០១៣។ ក្នុងចំណោមជនជាតិដើមភាគតិចដែលពិការនៅឆ្នាំ២០១៣ មានអ្នកពិការភ្នែក (៣៤,៤៥%) ពិការអវៈយវៈ (២៧,៣១%) ថ្លង់ (១៤,៨២%) គរ (១០,៥៨%) សតិមិនប្រក្រតី (៦,១៩%) និងពិការផ្សេងទៀត (៦,៦១%)។

**តារាងទី២៨. ពិការភាពនៃជនជាតិដើមភាគតិចពីកំណើត និងក្រោយកំណើត**

| | ២០០៨ | | | | ២០១៣ | |
|---|---|---|---|---|---|---|
| | ពីកំណើត | ក្រោយកំណើត | សរុប | | ពីកំណើតនិងក្រោយកំណើត | |
| | ចំនួន | ចំនួន | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ពិការភ្នែក | ៣១០ | ៤០១ | ៧១១ | ២៩,៥ | ៩៧៤ | ៣៤,៥ |
| គរ | ១៣៦ | ៦៨ | ២០៤ | ៨,៥ | ២៩៩ | ១០,៦ |
| ថ្លង់ | ៩៨ | ២៦៩ | ៣៦៧ | ១៥,២ | ៤១៩ | ១៤,៨ |
| ពិការអវៈយវៈ | ១២១ | ៧៣១ | ៨៥២ | ៣៥,៣ | ៧៧២ | ២៧,៣ |
| សតិមិនប្រក្រតី | ៧៦ | ២០៤ | ២៨០ | ១១,៦ | ១៧៥ | ៦,២ |
| ពិការផ្សេងទៀត | - | - | - | - | ១៨៧ | ០,១ |
| **សរុបអ្នកពិការ** | **៧៤១** | **១.៦៧៣** | **២.៤១៤** | **១០០,០** | **២.៨២៧** | **១០០,០** |
| **ចំនួនប្រជាជន** | **១៧៩.១៩៣** | | | | **១៨៣.៨៣០** | |
| **ភាគរយអ្នកពិការ** | **១,៣៥** | | | | **១,៥៤** | |

បើគិតតាមភេទ បុរសច្រើនពិការអវៈយវៈច្រើនជាងស្ត្រី (៣៨,៦% ទល់នឹង ១៩,២%) ឯស្ត្រីច្រើនមានបញ្ហាគរថ្លង់ច្រើនជាងបុរស (៣៩,២% ទល់នឹង ១៣,០%)។ បើគិតតាមក្រុមអាយុ ជនជាតិ

ដើមភាគតិច ហាក់ដូចជាមានបញ្ហាភ្នែកនៅគ្រប់វ័យទាំងអស់ (៣៣,៧%ក្នុងចំណោមអាយុក្រោម១៨ឆ្នាំ ៣៩,៦%ក្នុងចំណោមអាយុ១៥-៥៩ឆ្នាំ និង២៩,១%ក្នុងចំណោមអាយុ៦០ឆ្នាំឡើង)។ ដូចគ្នាដែរចំពោះបញ្ហាពិការអវៈយវៈ (២២,៣%ក្នុងចំណោមអាយុក្រោម១៨ឆ្នាំ ២៥,៧%ក្នុងចំណោមអាយុ១៥-៥៩ឆ្នាំ និង៣២,៦%ក្នុងចំណោមអាយុ៦០ឆ្នាំឡើង)។

**តារាងទី២៩. ពិការភាព តាមភេទនិងក្រុមអាយុ ឆ្នាំ២០១៣**

| ភាគរយនៃពិការភាព | ភេទ | | ក្រុមអាយុ | | |
|---|---|---|---|---|---|
| | ប្រុស | ស្រី | ក្រោម១៨ឆ្នាំ | ១៨-៥៩ឆ្នាំ | ៦០ឆ្នាំឡើង |
| ពិការភ្នែក | ៣៣,៩ | ៣៤,៨ | ៣៣,៧ | ៣៩,៦ | ២៩,១ |
| គរ | ៤,១ | ១៥,២ | ១៧,៥ | ១៤,៥ | ១,៥ |
| ថ្លង់ | ៨,៩ | ១៩,១ | ១០,២ | ១១,៤ | ២១,៨ |
| ពិការអវៈយវៈ | ៣៨,៦ | ១៩,២ | ២២,៣ | ២៥,៧ | ៣២,៦ |
| សតិមិនប្រក្រតី | ៨,៥ | ៤,៥ | ១៦,៣ | ៤,៧ | ១,១ |
| ពិការផ្សេងទៀត | ៥,៩ | ៧,១ | ០,០ | ៤,១ | ១៣,៩ |
| ចំនួនសរុប | ១.១៨៥ | ១.៦៤២ | ៦៦៨ | ១.១៤៨ | ១.០០៩ |

### ***៣.៣.៧. អនាម័យ***

ការមានបង្គន់អនាម័យប្រើប្រាស់និងការមានទឹកស្អាតបរិភោគជាសូចនាករ២ អំពីអនាម័យ ដែលមាននៅក្នុងទិន្នន័យគ្រួសាររបស់ជំរឿនឆ្នាំ២០០៨ និង អង្កេតចន្លោះជំរឿនឆ្នាំ២០១៣។

នៅឆ្នាំ២០០៨ ៩០,៩%នៃគ្រួសារជនជាតិដើមភាគតិចគ្មានបង្គន់ប្រើប្រាស់ ៤,៤%មានបង្គន់ចាក់ទឹក និង ៣,១%ប្រើប្រាស់បង្គន់រណ្តៅ។ នៅឆ្នាំ២០១៣ ចំនួនគ្រួសារដែលគ្មានបង្គន់ប្រើប្រាស់បានថយចុះបន្តិច មកនៅ៨៤,៤% និងគ្រួសារដែលប្រើបង្គន់ចាក់ទឹកកើនឡើងបាន១០,៩%។ ទោះជាយ៉ាងនេះក្តី ភាគច្រើនលើសលប់នៃគ្រួសារជនជាតិដើមភាគតិច នៅមិនទាន់មានបង្គន់អនាម័យប្រើប្រាស់ទេ។

ចំពោះប្រភពទឹកស្អាតបរិភោគ ៣២,៣%នៃគ្រួសារជនជាតិដើមភាគតិចនៅឆ្នាំ២០០៨ ប្រើប្រាស់ទឹកម៉ាស៊ីនបណ្តាញ ទឹកអណ្តូងស្នប់ និងទឹកអណ្តូងមានគម្រប។ តួលេខនេះ កើនដល់៣៨,៤%នៅឆ្នាំ២០១៣។ ភាគច្រើននៃគ្រួសារជនជាតិដើមភាគតិច ប្រើប្រាស់ទឹកទន្លេ បឹង ស្ទឹង ព្រែក ជាប្រភពទឹកសម្រាប់បរិភោគ។

**តារាងទី៣០.   គ្រួសារជនជាតិមានបង្គន់អនាម័យនិងទឹកស្អាតបរិភោគ**

| | | ឆ្នាំ២០០៨ | ឆ្នាំ២០១៣ |
|---|---|---|---|
| | ចំនួនគ្រួសារសរុប | ៣៣.៧៥៨ | ៣៧.២០១ |
| ប្រភេទបង្គន់ដែល គ្រួសារប្រើប្រាស់ | គ្មានបង្គន់ប្រើប្រាស់ | ៩០,៩ | ៨៤,៤ |
| | បង្គន់ចាក់ទឹកភ្ជាប់ទៅលូ | ២,៣ | ៤,៦ |
| | បង្គន់ចាក់ទឹកមានអាងស្តុក | ២,១ | ៦,៣ |
| | បង្គន់រណ្តៅ | ៣,១ | ៣,៧ |
| | បង្គន់ផ្សេងទៀត | ១,៦ | ១,០ |
| ប្រភពទឹកទទួលទាន | ទឹកម៉ាស៊ីនបណ្តាញ | ២,១ | ១,៥ |
| | អណ្តូងស្នប់ | ២២,៩ | ២៣,១ |
| | អណ្តូងមានគម្រប | ៧,៣ | ១៣,៨ |
| | អណ្តូងគ្មានគម្រប | ២០,៥ | ១៨,១ |
| | ទឹកភ្លៀង | ០,៦ | ០,២ |
| | ទឹកចេញក្រោមដី ទឹកទន្លេ | ៤៤,៦ | ៤១,១ |
| | ទឹកទិញ | ១,០ | ១,០ |

## ៣.៤. សាសនានិងជំនឿ

ជនជាតិដើមភាគតិចកាន់សាសនាច្រើនសាសនា។ នៅឆ្នាំ២០១៣ អ្នកកាន់ពុទ្ធសាសនាមាន ៥៤,១% អ៊ីស្លាមសាសនាមាន០,៧% គ្រីស្តសាសនាមាន៣,៤% និងសាសនាផ្សេងទៀតមាន៤១,៨%។ នេះបញ្ជាក់ថា ជនជាតិដើមភាគតិចកាន់សាសនាផ្សេងៗទៀតជាច្រើន ដែលប្រហែលជាជំនឿរបស់ខ្លួនដែលមានយូរលង់មកហើយ និងដែលពុំមានទិន្នន័យជាក់លាក់នៅក្នុងជំរឿននិងអង្កេតនានាឡើយ។

**តារាងទី៣១.   សាសនារបស់ជនជាតិដើមភាគតិច**

| សាសនារបស់ជនជាតិដើមភាគតិច | ២០០៨ | | ២០១៣ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ព្រះពុទ្ធសាសនា | ៨២.២២៤ | ៤៥,៩ | ៩៩.៤៩៤ | ៥៤,១ |
| អ៊ីស្លាមសាសនា | ៤៣០ | ០,២ | ១.២៧៤ | ០,៧ |
| គ្រីស្តសាសនា | ៥.៥១៣ | ៣,១ | ៦.២៤២ | ៣,៤ |
| សាសនាផ្សេងទៀត | ៩១.០២៦ | ៥០,៨ | ៧៦.៨២២ | ៤១,៨ |
| **សរុប** | **១៧៩.១៩៣** | **១០០,០** | **១៨៣.៨៣១** | **១០០,០** |

# ៤. លំនៅឋាន ដីធ្លី និងកម្មសិទ្ធិ

## ៤.១. លំនៅឋាន

ព័ត៌មានអំពីលំនៅឋាន ត្រូវបានដកស្រង់ចេញពីទិន្នន័យគ្រួសារនៃជំរឿនឆ្នាំ២០០៨ និងអង្កេតចន្លោះជំរឿនឆ្នាំ២០១៣។ យោងតាមទិន្នន័យនេះ ភាគច្រើនលើសលប់នៃគ្រួសារជនជាតិដើមភាគតិចមានលំនៅឋានខ្លួនឯង គឺមានចំនួន ៩៦,៣%នៅឆ្នាំ២០០៨ និង ចំនួន ៩៥,៥%នៅឆ្នាំ២០១៣។ រីឯគ្រួសារជនជាតិដើមភាគតិចដែលស្នាក់នៅផ្ទះគេ មានចំនួន ២,៦%នៅឆ្នាំ២០០៨ និង ចំនួន ៣,៩%នៅឆ្នាំ២០១៣។ គ្រួសារជនជាតិដើមភាគតិចដែលជួលផ្ទះគេនៅមានចំនួនតិចជាង១%។

**តារាងទី៣២. លំនៅឋានជនជាតិដើមភាគតិច**

| | ចំនួនគ្រួសារ | | ភាគរយ | |
|---|---|---|---|---|
| | ២០០៨ | ២០១៣ | ២០០៨ | ២០១៣ |
| ផ្ទះខ្លួនឯង | ៣២.៥៧១ | ៣៥.៥៣៦ | ៩៦,៣ | ៩៥,៥ |
| ផ្ទះជួលគេ | ១៩៨ | ៦០ | ០,៦ | ០,២ |
| ផ្ទះគេឱ្យស្នាក់នៅ | ៨៨៨ | ១.៤៦៨ | ២,៦ | ៣,៩ |
| ផ្សេងទៀត | ១០១ | ១៣៧ | ០,៣ | ០,៤ |
| មិនច្បាស់ | ៦២ | ០ | ០,២ | ០,០ |
| **សរុប** | **៣.៣៨២** | **៣៧.២០១** | **១០០,០** | **១០០,០** |

គ្រួសារជនជាតិដើមភាគតិចប្រើប្រាស់ប្រភពភ្លើងបំភ្លឺផ្សេងៗជាច្រើន។ ភាគច្រើននៃគ្រួសារជនជាតិដើមភាគតិច ប្រើប្រាស់ចង្កៀងប្រេងកាត (៦៦,២%នៅឆ្នាំ២០០៨ និងថយចុះនៅត្រឹម៣៣,៧%នៅឆ្នាំ២០១៣) និងប្រើប្រាស់អាគុយ (១១,៦%នៅឆ្នាំ២០០៨ និងកើនដល់៤១,៦%នៅឆ្នាំ២០១៣) ជាប្រភពភ្លើងបំភ្លឺ។ រីឯគ្រួសារដែលប្រើប្រាស់ភ្លើងអគ្គិសនី បានកើនពី៤,៩%នៅឆ្នាំ២០០៨ ដល់១១,៥%នៅឆ្នាំ២០១៣។ ចំណែកឯគ្រួសារដែលមានម៉ាស៊ីនភ្លើងផ្ទាល់ខ្លួនជាប្រភពបំភ្លឺ មានចំនួន២,៣%នៅឆ្នាំ២០០៨ និងកើនដល់៩,១%នៅឆ្នាំ២០១៣។

**តារាងទី៣៣.	ប្រភពភ្លើងបំភ្លឺរបស់គ្រួសារជនជាតិដើមភាគតិច**

| | ចំនួនគ្រួសារ | | ភាគរយ | |
|---|---|---|---|---|
| | ២០០៨ | ២០១៣ | ២០០៨ | ២០១៣ |
| ភ្លើងអគ្គិសនីរដ្ឋ | ១.៦៦៣ | ៤២៧ | ៤,៩ | ១១,៥ |
| ម៉ាស៊ីនភ្លើង | ៧៧៩ | ៣៤ | ២,៣ | ៩,១ |
| ភ្លើងអគ្គិសនីរដ្ឋនិងម៉ាស៊ីនភ្លើង | ២៣០ | ១៥៦ | ០,៧ | ០,៤ |
| ចង្កៀងប្រេងកាត | ២២.៣៧៧ | ១២.៥៣៤ | ៦៦,២ | ៣៣,៧ |
| ទៀន | ៥១៩ | ៧៣១ | ១,៥ | ២,០ |
| អាគុយ | ៣.៩១៤ | ១៥.៤៦៥ | ១១,៦ | ៤១,៦ |
| ផ្សេងទៀត | ៤.៣៣៨ | ៦៤៥ | ១២,៨ | ១,៧ |
| **សរុប** | **៣.៣៨២** | **៣៧.២០១** | **១០០,០** | **១០០,០** |

ចំពោះប្រភពថាមពលចម្អិន ភាគច្រើនលើសលប់នៃគ្រួសារជនជាតិដើមភាគតិច ប្រើប្រាស់ឧសជាប្រភពថាមពលចម្អិនអាហារ (៩៧%នៅឆ្នាំ២០១៨ និង ៩៥%នៅឆ្នាំ២០១៣)។ រីឯគ្រួសារដែលប្រើប្រាស់ធ្យូងឬប្រេងកាតជាប្រភពថាមពលចម្អិនអាហារមានចំនួនតិចជាង២% និងគ្រួសារដែលប្រើប្រាស់ដែលប្រើប្រាស់ហ្គាសឬអគ្គិសនីជាប្រភពថាមពលចម្អិនអាហារមានចំនួនតិចជាង១%។

**តារាងទី៣៤.	ប្រភពថាមពលចម្អិនរបស់គ្រួសារជនជាតិដើមភាគតិច**

| | ចំនួនគ្រួសារ | | ភាគរយ | |
|---|---|---|---|---|
| | ២០០៨ | ២០១៣ | ២០០៨ | ២០១៣ |
| ឧស | ៣២.៧៨៧ | ៣៥.៣១៨ | ៩៦,៩ | ៩៤,៩ |
| ធ្យូង | ៣៤៤ | ៥៨១ | ១,០ | ១,៦ |
| ប្រេងកាត | ១២២ | ៤២៧ | ០,៤ | ១,១ |
| ហ្គាស | ៤២១ | ៦១១ | ១,២ | ១,៦ |
| អគ្គិសនី | ២៥ | ២២៨ | ០,១ | ០,៦ |
| គ្មាន | ៣៣ | ៣៦ | ០,១ | ០,១ |
| ផ្សេងទៀត | ៨៨ | ០ | ០,៣ | ០,០ |
| **សរុប** | **៣.៣៨២** | **៣៧.២០១** | **១០០,០** | **១០០,០** |

ចំពោះសម្ភារៈគ្រួសារសម្រាប់ព័ត៌មាននិងការប្រស្រ័យទាក់ទង គ្រួសារជនជាតិដើមភាគតិច ជិត ១ភាគ៣មានទូរទស្សន៍ប្រើ (ជាសរុបមានចំនួន ៣០%នៅឆ្នាំ២០១៣ កើនពី ១៩,២%នៅឆ្នាំ២០០៨)។ ការមានទូរស័ព្ទដៃប្រើក្នុងចំណោមគ្រួសារជនជាតិដើមភាគតិច បានកើនយ៉ាងខ្លាំង ពីជិត២០%នៅឆ្នាំ ២០០៨ មក១១០%នៅឆ្នាំ២០១៣ (មានន័យថា នៅឆ្នាំ២០១៣ មានគ្រួសារដែលមានទូរស័ព្ទដៃលើស ពីមួយក្នុងមួយគ្រួសារ)។ នៅឆ្នាំ២០១៣ ចំនួន១០%នៃគ្រួសារជនជាតិដើមភាគតិចមានទូរស័ព្ទលើតុ ប្រើ។ ការប្រើប្រាស់អ៊ីនធឺណែតមានចំនួនតិចតួចណាស់ក្នុងចំណោមគ្រួសារជនជាតិដើមភាគតិច (គឺតិច ជាង១% នៅឆ្នាំ២០០៨និង២០១៣)។

ចំពោះសម្ភារៈគ្រួសារសម្រាប់ការធ្វើដំណើរ នៅឆ្នាំ២០១៣ គ្រួសារជនជាតិដើមភាគតិចចំនួន ៧៦,១% មានម៉ូតូ ២,២%មានរថយន្ត ៩,១%មានគោយន្ត ៧,៨%មានទូក និង៣៧,៤%មានកង់។

**តារាងទី៣៥. សម្ភារៈប្រើប្រាស់នៅក្នុងផ្ទះរបស់គ្រួសារជនជាតិដើមភាគតិច**

| | ចំនួនគ្រួសារ | | ភាគរយនៃគ្រួសារសរុប | |
|---|---|---|---|---|
| | ២០០៨ | ២០១៣ | ២០០៨ | ២០១៣ |
| វិទ្យុ | ១.៣១៤ | ៨.៨៣៥ | ៣៨,៩ | ២៣,៧ |
| ទូរទស្សន៍ | ៦.៤៨៨ | ១១.១៤៤ | ១៩,២ | ៣០,០ |
| ទូរស័ព្ទលើតុ | ២១៤ | ៣.៧៧៨ | ០,៦ | ១០,២ |
| ទូរស័ព្ទដៃ | ៥.៣៧២ | ៤០.៩៤៩ | ១៥,៩ | ១១០,១ |
| កុំព្យូទ័រ | ៤៤០ | ៨៨៣ | ១,៣ | ២,៤ |
| កង់ | ១.៦៥៣ | ១៣.៩១២ | ៤៨,៩ | ៣៧,៤ |
| ម៉ូតូ | ១៥.៨៧៤ | ២៨.៣២៣ | ៤៦,៩ | ៧៦,១ |
| រថយន្ត | ៦៥៣ | ៨០៦ | ១,៩ | ២,២ |
| ទូក | ១.២៩៦ | ២.៩០៨ | ៣,៨ | ៧,៨ |
| ត្រាក់ទ័រ | ១២២ | ៣០ | ០,៤ | ០,១ |
| គោយន្ត | ១.៣៦៩ | ៣.៣៨៧ | ៤,០ | ៩,១ |
| អ៊ីនធឺណែត នៅផ្ទះ | ១១០ | ២៤ | ០,៣ | ០,១ |
| អ៊ីនធឺណែត ក្រៅផ្ទះ | ៨៩ | ១៤៩ | ០,៣ | ០,៤ |
| អ៊ីនធឺណែតនៅផ្ទះនិងក្រៅផ្ទះ | ០ | ៤២ | ០,០ | ០,១ |
| **ចំនួនគ្រួសារសរុប** | **៣.៣៨២** | **៣៧.២០១** | **១០០,០** | **១០០,០** |

## ៤.២. ដីធ្លីនិងកម្មសិទ្ធិ

### *៤.២.១. ដីធ្លីនិងកម្មសិទ្ធិឯកជន*

គ្មានទិន្នន័យអំពីដីធ្លីនិងកម្មសិទ្ធិឯកជនរបស់ជនជាតិដើមភាគតិចទេ។

### *៤.២.២. ដីធ្លីនិងកម្មសិទ្ធិជាលក្ខណៈសមូហភាពសហគមន៍ជនជាតិដើមភាគតិច*

ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិច សរុបចំនួន១៥៥ សហគមន៍ និង១៤អំបូរជនជាតិ ទូទាំងប្រទេសកម្ពុជាគិតត្រឹមខែមិថុនា ឆ្នាំ២០២១(ឧបសម្ព័ន្ធ៤)។ សហគមន៍ទាំងនេះស្ថិតនៅក្នុងខេត្តចំនួន១០ មានខេត្តរតនៈគិរី (ចំនួន៧៥ភូមិ) ខេត្តមណ្ឌលគិរី (ចំនួន ២៨ភូមិ) ខេត្តក្រចេះ (ចំនួន១៣ភូមិ) ខេត្តស្ទឹងត្រែង (ចំនួន១៤ភូមិ) ខេត្តព្រះវិហារ (ចំនួន៩ភូមិ) ខេត្ត កំពង់ធំ (ចំនួន៥ភូមិ) ខេត្តពោធិ៍សាត់ (ចំនួន២ភូមិ) ខេត្តបាត់ដំបង (ចំនួន១ភូមិ) ខេត្តកោះកុង (ចំនួន ៣ភូមិ) និងខេត្តកំពង់ស្ពឺ (ចំនួន៥ភូមិ)។ ក្រសួងមហាផ្ទៃ បានទទួលស្គាល់សហគមន៍ជនជាតិដើមភាគ តិចជាសហគមន៍នីតិបុគ្គល សរុបចំនួន១៥២សហគមន៍នៅទូទាំងប្រទេសកម្ពុជា គិតត្រឹមខែមិថុនា ឆ្នាំ ២០២១នេះ។ សហគមន៍ទាំងនេះស្ថិតនៅក្នុងខេត្តចំនួន៨ មានខេត្តរតនៈគិរី (ចំនួន៨៥ភូមិ) ខេត្ត មណ្ឌលគិរី (ចំនួន៣៥ភូមិ) ខេត្តបាត់ដំបង (ចំនួន១ភូមិ) ខេត្តកំពង់ស្ពឺ (ចំនួន៤ភូមិ) ខេត្តព្រះវិហារ (ចំនួន៦ភូមិ) ខេត្តក្រចេះ (ចំនួន១១ភូមិ) ខេត្តស្ទឹងត្រែង (ចំនួន៨ភូមិ) និងខេត្តកំពង់ធំ (ចំនួន២ភូមិ) (តារាងទី៣៦និងឧបសម្ព័ន្ធទី៦)។

**តារាងទី៣៦. ចំនួនសហគមន៍ជនជាតិដើមភាគតិច ដែលចុះបញ្ជីនៅក្រសួងមហាផ្ទៃ គិតត្រឹមខែមិថុនា ឆ្នាំ២០២១**

| | ខេត្ត | ចំនួនសហគមន៍ |
|---|---|---|
| ១ | រតនគិរី | ៨៥ |
| ២ | មណ្ឌលគិរី | ៣៥ |
| ៣ | ក្រចេះ | ១១ |
| ៤ | ស្ទឹងត្រែង | ៨ |
| ៥ | ព្រះវិហារ | ៦ |
| ៦ | កំពង់ស្ពឺ | ៤ |
| ៧ | កំពង់ធំ | ២ |
| ៨ | បាត់ដំបង | ១ |
| | សរុប | ១៥២ |

ដោយឡែកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាសមូហភាព នៅទូទាំងប្រទេសសរុប ៣៣សហគមន៍ ស្មើនឹង ៨៥៦ប័ណ្ណ លើផ្ទៃដីទំហំ ៣៣,៨៩៨ហិកតា ស្មើនឹង ៣,២៣៥គ្រួសារ គិតត្រឹមខែធ្នូ ឆ្នាំ២០២០។ សហគមន៍ទាំងនេះស្ថិតនៅក្នុងខេត្តចំនួន៤ មានខេត្តរតនៈគិរី (ចំនួន២០ភូមិ) ខេត្តមណ្ឌលគិរី (ចំនួន៧ភូមិ) ខេត្តក្រចេះ (ចំនួន៤ភូមិ) និងខេត្តស្ទឹងត្រែង (ចំនួន២ភូមិ) (តារាងទី៣៧និងឧបសម្ព័ន្ធទី៧) ។

**តារាងទី៣៧. ដីសហគមន៍ជនជាតិដើមភាគតិច ដែលបានចុះបញ្ជីនិងដែលបានចែកប័ណ្ណ ពីឆ្នាំ ២០១១ ដល់ ២០២០**

| ខេត្ត | | ចំនួនភូមិ | ចំនួនប័ណ្ណសរុប | ទំហំដីជាហិកតា | ចំនួនគ្រួសារ |
|---|---|---|---|---|---|
| ១ | រតនគិរី | ២០ | ៣៩៧ | ២០៩៦៦,៥៨ | ២០០៨ |
| ២ | មណ្ឌលគិរី | ៧ | ២៧៨ | ៦១៥៥,៦៦ | ៤៧៣ |
| ៣ | ក្រចេះ | ៤ | ១៣៤ | ៤៧៨៤,៩៩ | ៦២៩ |
| ៤ | ស្ទឹងត្រែង | ២ | ៤៧ | ១៩៩១,៥១ | ១២៥ |
| សរុប | | ៣៣ | ៨៥៦ | ៣៣៨៩៨,៧៥ | ៣២៣៥ |

# ៥. សេចក្តីសន្និដ្ឋាន

យោងតាមស្មារតីនៃសិក្ខាសាលាថ្នាក់ជាតិឆ្នាំ២០១៧ ស្តីពីការឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្ត គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច របាយការណ៍ជាតិស្តីពី*ស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា* គឺជារបាយការណ៍ប្រវត្តិសាស្ត្រលើកដំបូងបង្អស់ ដែលត្រូវបានបង្កើតឡើង ប្រកបដោយសារសំខាន់បំផុតសម្រាប់ការងារអភិវឌ្ឍន៍ជនជាតិដើមនៅកម្ពុជា ដែលជាការឆ្លើយតបមួយ ទៅនឹងការយកចិត្តទុកដាក់ជាពិសេសលើការអភិវឌ្ឍជនជាតិដើមភាគតិចនៅកម្ពុជា របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះ ជារបាយការណ៍ផ្លូវការដែលចងក្រងទិន្នន័យមូលដ្ឋានគ្រឹះ អំពីស្ថានភាពប្រជាសាស្ត្រ ការអប់រំ ការងារនិងសេដ្ឋកិច្ច សុខភាពនិងអនាម័យ និងលំនៅឋាននិងកម្មសិទ្ធសម្ភារៈរបស់ជនជាតិដើមភាគតិច ដោយបានផ្តោតជាក់លាក់លើជនជាតិដើមភាគតិចទាំងអស់នៅកម្ពុជា ដើម្បីផ្តល់ភាពងាយស្រួលដល់ភាគីពាក់ព័ន្ធទាំងអស់ ដូចជា ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល អង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងម្ចាស់ជំនួយនានា រួមទាំងជនជាតិដើមភាគតិចខ្លួនឯង ក្នុងដំណើរការរៀបចំផែនការនិងសកម្មភាពអន្តរាគមន៍នានា ជុំវិញការអភិវឌ្ឍន៍និងការអភិរក្សជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ជនជាតិដើមភាគតិច ក៏ដូចជាការរួមចំណែកដល់ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច រួមទាំងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជានិងអន្តរជាតិឆ្នាំ២០៣០ ឱ្យកាន់តែមានប្រសិទ្ធិភាព និងប្រសិទ្ធិផល តាមគោលការណ៍ មិនទុកចោលនរណាម្នាក់ឡើយ។

ម្យ៉ាងវិញទៀត របាយការណ៍នេះ ក៏ជាមូលដ្ឋាននិងគោលដៅបន្តសម្រាប់បច្ចុប្បន្នភាពនៃរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច ទៅពេលអនាគត ដើម្បីឆ្លើយតបទៅនឹងបញ្ហាកង្វះព័ត៌មានអំពីជនជាតិដើមភាគតិចនៅកម្ពុជាសម្រាប់ការងារអភិវឌ្ឍន៍ និងដើម្បីបន្តជួយឱ្យមានកាន់តែច្រើន ទូលំទូលាយ លម្អិត គ្រប់ជ្រុងជ្រោយ និងមានសង្គតិភាព នូវប្រព័ន្ធទិន្នន័យដែលផ្តោតជាក់លាក់លើជនជាតិដើមភាគតិចនៅកម្ពុជា។

ជាទិដ្ឋភាពរួម ជនជាតិដើមភាគតិចនៅកម្ពុជា ត្រូវបានចាត់ទុកថាជាប្រជាជនងាយរងគ្រោះនៅក្នុងបរិការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព។ ជនជាតិដើមភាគតិចនៅកម្ពុជា កំពុងមានស្ថានភាពប្រជាសាស្ត្រប្រែប្រួលឆ្ពោះទៅរកស្ថានភាពប្រជាសាស្ត្ររបស់ប្រជាជនកម្ពុជាទូទៅ ដូចជា ការថយចុះនៃអត្រាកំណើតនិងអត្រាមរណភាព ការកើនឡើងនៃអាយុរៀបការដំបូង ការកើនឡើងនៃកម្លាំងពលកម្ម និង

និន្នាការនៃទេសន្តរប្រវេសន៍ទៅកាន់ទីប្រជុំជន។ ក៏ប៉ុន្តែ ការប្រែប្រួលទាំងនេះ នៅមានទំហំតូចនៅឡើយ បើធៀបទៅនឹងការប្រែប្រួលនៃស្ថានភាពប្រជាសាស្ត្រនៃប្រជាជាកម្ពុជាសរុប។ លើសពីនេះទៀត ស្ថានភាពសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច នៅមានកម្រិតទាបនៅឡើយ ពិសេសគឺការទទួលបានការអប់រំនិងជំនាញវិជ្ជាជីវៈ ពិសេសគឺការទទួលបានការអប់រំរបស់កុមារនិងយុវវ័យ។ ថ្វីបើចំនួនប្រជាជនក្នុងវ័យធ្វើការងារមានចំនួនកើនឡើង ស្ថានភាពការងារនិងសេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច នៅមានកម្រិតទាប ដោយភាគច្រើនផ្តុំលើការងារជុំវិញវិស័យកសិកម្ម និងការងារគ្មានប្រាក់កម្រៃ ពិសេសចំពោះស្ត្រីជនជាតិដើមភាគតិច។ ជនជាតិដើមភាគតិច ក៏នៅជួបប្រទះបញ្ហាទឹកស្អាត សុខភាពនិងអនាម័យ ដែលគួរត្រូវបានការយកចិត្តទុកដាក់បន្ថែមទៀតពីគ្រប់ភាគីពាក់ព័ន្ធ ដូចជាបញ្ហាជំងឺឆ្លង ការរកនិងការទទួលបានសេវាសុខភាពបឋម និងអនាម័យ។

ដើម្បីកំណើនកម្លាំងពលកម្មមានផលិតភាព តំហយ(ការថយឬថយចុះ)ផលធៀបប្រជាជនក្នុងបន្ទុក និងការអភិវឌ្ឍធនធានមនុស្សមានប្រសិទ្ធិភាព ដែលនឹងបង្កើនកាលានុវត្តភាពនៃការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារនិងសង្គមរបស់ជនជាតិដើមភាគតិច សកម្មភាពអន្តរាគមន៍ជាប្រព័ន្ធពីសំណាក់ស្ថាប័នពាក់ព័ន្ធគឺជាកិច្ចការចាំបាច់មិនអាចខ្វះបាន និងគួរយកចិត្តទុកដាក់បន្តទៀតលើកត្តាប្រជាសាស្ត្រ (មានអត្រាកំណើតនិងអត្រាមរណភាព) និងការលើកកម្ពស់និងការជំរុញការទទួលបានការអប់រំ សេវាសុខភាព ប្រព័ន្ធទឹកស្អាតការចូលរួម សិទ្ធិនានាក្នុងការរស់នៅ បញ្ហាយេនឌ័រ បញ្ហាបាត់បង់ធនធានដីធ្លីនិងធម្មជាតិ និងការទទួលបានផលនៃការអភិវឌ្ឍ។ ការស្រាវជ្រាវជាក់លាក់អំពីស្ថានភាពការងារ សេដ្ឋកិច្ច និងការរស់នៅរបស់ជនជាតិដើមភាគតិច គួរត្រូវបានជំរុញនិងលើកទឹកចិត្ត ដើម្បីទទួលបានព័ត៌មានលម្អិតនិងគ្រប់ជ្រុងជ្រោយជាបន្ថែមទៀត អំពីការប្រឈមនិងដំណោះស្រាយ។

# ឧបសម្ព័ន្ធទី១. ប្រវត្តិសកម្មភាពនិងលទ្ធផលការងារនៃការរៀបចំរបាយការណ៍

**ការរៀបចំរបាយការណ៍នេះ បានឆ្លងកាត់កិច្ចប្រជុំជាច្រើនលើក[១១] ដែលរួមមាន៖**

**លើកទី១**- នៅថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ នៅសណ្ឋាគារអេប្សរាអង្គរ ខេត្តសៀមរាប ក្នុងអង្គសិក្ខាសាលាឆ្លុះបញ្ចាំងថ្នាក់ជាតិ ស្តីពីការអនុវត្តគោលនយោបាយជាតិស្តីពីកាអភិវឌ្ឍជនជាតិដើមភាគតិច ដែលបានបង្ហាញអំពីតម្រូវការក៏ដូចជាការឯកភាពឲ្យមានរបាយការណ៍ជាតិស្តីពីទិន្នន័យជនជាតិដើមភាគតិចមួយជាក់លាក់។




សិក្ខាសាលាឆ្លុះបញ្ចាំងថ្នាក់ជាតិ ស្តីពីការអនុវត្តគោលនយោបាយជាតិស្តីពីកាអភិវឌ្ឍជនជាតិដើមភាគតិច
ថ្ងៃទី១១-១៣ ខែមករា ឆ្នាំ២០១៧ នៅខេត្តសៀមរាប

**លើកទី២**- នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ ម៉ោង៩ព្រឹក នៅការិយាល័យឯកឧត្តមបណ្ឌិតប៉ូច ប៊ុណ្ណាក់ មានកិច្ចប្រជុំស្តីពីការពិភាក្សាលើដំណើរការរៀបចំផែនការសកម្មភាពសម្រាប់បង្កើតរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គមសេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា ដែលមានសមាសភាពចូលរួមពីតំណាងអង្គការជនជាតិដើមភាគតិចកម្ពុជា តំណាងអង្គការUNFPA ក្រោមអធិបតីភាពដ៏

[១១] របាយការណ៍នៃកិច្ចប្រជុំទាំងអស់ ត្រូវបានធ្វើឡើងដោយអង្គការជនជាតិដើមភាគតិចកម្ពុជា។

ខ្ពង់ខ្ពស់**ឯកឧត្តមបណ្ឌិតប៉ូច ប៊ុណ្ណាក់** ដែលជាអនុរដ្ឋលេខាធិការនៃក្រសួងផែនការ និង**ឯកឧត្តមយឹម ជុង** ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ។



**កិច្ចប្រជុំពិភាក្សាលើដំណើរការរៀបចំផែនការសកម្មភាពសម្រាប់បង្កើតរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នៅក្រសួងផែនការ**

**លើកទី៣**- នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ ម៉ោង៩ព្រឹកដល់ម៉ោង១២ថ្ងៃត្រង់ នៅភោជនីយដ្ឋានទន្លេបាសាក់ មានកិច្ចប្រជុំពិភាក្សាបន្តលើដំណើរការនៃការរៀបចំឲ្យមានរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច រវាងក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៍ជនបទ និងមានការចូលរួមពីសមាជិកសម្ព័ន្ធជនជាតិដើមភាគតិច រួមមានអង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) និងអង្គការសមាគមខ្មែរលើ (HA) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**លោកជំទាវម៉ាត់ ម៉ារ៉ា** រដ្ឋលេខាធិកានៃក្រសួងអភិវឌ្ឍន៍ជនបទ និង**ឯកឧត្តមទួន ថាវរៈ** រដ្ឋលេខាធិការក្រសួងផែនការ ដោយមានការសម្របសម្រួលអង្គពិភាក្សាដោយ**ឯកឧត្តមបណ្ឌិតប៉ូច ប៊ុណ្ណាក់** អនុរដ្ឋលេខាធិការនៃក្រសួងផែនការ។ ជាលទ្ធផលនៃកិច្ចពិភាក្សា គឺអង្គប្រជុំបានសម្រេចរៀបចំបង្កើតក្រុមការងារបច្ចេកទេស ដើម្បីរៀបចំបង្កើតរបាយការណ៍ជាតិនេះឡើងតាមចំណារគូសបញ្ជាក់អំពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ ដែលមានសមាសភាពសរុបចំនួន១១រូប ដោយ**ឯកឧត្តមទួន ថាវរៈ** រដ្ឋលេខាធិការនៃក្រសួងផែនការជាប្រធាន និងលោក**ជំទាវម៉ាត់ ម៉ារ៉ារដ្ឋ** លេខាធិការក្រសួងអភិវឌ្ឍន៍ជនបទជាអនុប្រធាន និងមានសមាជិកសំខាន់ៗទាំងពីរក្រសួង រួមទាំងតំណាងស្ថាប័នជនជាតិដើមភាគតិចមានអង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) អង្គ

ការសមាគមខ្មែរលើ (HA) លេខាធិការដ្ឋានសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា (CIPA) និងមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA)។

**លើកទី៤**- នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង៩ដល់ម៉ោង១២ថ្ងៃត្រង់ នៅភោជនីយដ្ឋានខេអេស ទីក្រុងភ្នំពេញ មានកិច្ចប្រជុំជាថ្មីម្តងទៀតរវាងក្រុមការងារស្តីពីផែនការបង្កើតរបាយការណ៍ជាតិ ដើម្បីពិនិត្យមើលបច្ចុប្បន្នភាពអំពីដំណើរការរៀបចំការងារសរសេរសេចក្តីព្រាងរបាយការណ៍ជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមទួន ថាវរៈ** រដ្ឋលេខាធិការ ក្រសួងផែនការ និង**លោកជំទាវម៉ាត់ ម៉ារ៉ា** រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានវត្តមានដ៏ខ្ពង់ខ្ពស់ពី**ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់** អនុរដ្ឋលេខាធិការ ក្រសួងផែនការ និង**ឯកឧត្តមយឹម ផុង** ប្រធាននាយកដ្ឋានជនជាតិភាគតិច ក្រសួងអភិវឌ្ឍន៍ជនបទ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និងអង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO)។ ជាលទ្ធផល អង្គប្រជុំគឺបានឯកភាពសម្រេចដាក់ចេញនូវសំណើរសុំការឯកភាពពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងទាំងពីរស្តីពីការបង្កើតក្រុមការងារ រួមទាំងទម្រង់ មាតិកា និងតម្រូវការព័ត៌មាននៃការផលិតរបាយការណ៍ រួមទាំងផែនការដែលត្រូវអនុវត្តសម្រាប់បញ្ចប់របាយការណ៍ជាតិលើកទី១ ក៏ដូចជាផែនការធ្វើរបាយការណ៍បច្ចុប្បន្នភាពជាសេរីជាបន្តបន្ទាប់។



កិច្ចប្រជុំពិគ្រោះយោបល់ពិនិត្យលើសេចក្តីព្រាងរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ សង្គម-សេដ្ឋកិច្ចជនជាតិដើមភាគតិចនៅកម្ពុជា នៅភោជនីយដ្ឋានទន្លេបាសាក់ ទីក្រុងភ្នំពេញ នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១

**លើកទី៥**- នៅថ្ងៃទី២ ខែមេសា ២០១៨ នៅភោជនីយដ្ឋានទន្លេបាសាក់ផ្លូវម៉ៅសេទុង ក្រុងភ្នំពេញបានរៀបចំកិច្ចប្រជុំស្តីពីកិច្ចពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច ជូនទៅដល់ក្រុមការងារ ដែលមានសមាសភាពចូលរួមសរុប ១៣នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**លោកជំទាវម៉ាត់ ម៉ារ៉ា** រដ្ឋលេខានៃក្រសួងអភិវឌ្ឍន៍ជនបទ និង **ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់** អនុរដ្ឋលេខានៃក្រសួងផែនការ ។ ជាលទ្ធផល គឺអង្គប្រជុំបានឆ្លងសេចក្តីព្រាងរបាយការណ៍ជាតិលើកទី១ប្រកបដោយភាពជោគជ័យ និងមានការផ្តល់មតិយោបល់ដើម្បីកែលម្អលើចំណុចខ្វះខាតនៃរបាយការណ៍នេះគឺត្រូវសរសេរកែរតម្រូវឈ្មោះក្រុមជនជាតិដើមភាគតិចឱ្យដូចគ្នា ក៏ប៉ុន្តែ អង្គប្រជុំនៅមិនទាន់សម្រេចថាយកតាមឯកសារណាមួយនៅឡើយ។ **លោកជំទាវម៉ាត់ ម៉ារ៉ា** បានស្នើសុំឱ្យដាក់បញ្ចូលរាល់សមិទ្ធផលរួមគ្រប់ក្រសួងពាក់ព័ន្ធក្នុងរបាយការណ៍នេះដែរ ព្រោះជារបាយការណ៍ជាតិតំណាងឱ្យរាជរដ្ឋាភិបាលទាំងមូល ។ ចុងក្រោយក្រុមការងារក៏បានព្រមព្រៀងលើផែនការបន្ត ដើម្បីស្នើសុំពិគ្រោះយោបល់ជាមួយមន្ត្រីថ្នាក់បច្ចេកទេសតាមបណ្តាក្រសួងពាក់ព័ន្ធនានាដែលធ្វើកិច្ចការលើជនជាតិដើមភាគតិច និងបន្តឆ្លងជាមួយមន្ត្រីកំរិតថ្នាក់នយោបាយ មុនដាក់ប្រកាសឱ្យប្រើប្រាស់ជាផ្លូវការបាន។



កិច្ចប្រជុំឆ្លងរបាយការណ៍ជាតិលើកទី១ជាមួយក្រុមការងារ លើសេចក្តីព្រាងរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ សង្គម-សេដ្ឋកិច្ចជនជាតិដើមភាគតិចនៅកម្ពុជា នៅភោជនីយដ្ឋានខេអេសទីក្រុងភ្នំពេញនៅថ្ងៃទី២ ខែមេសា ២០១៨

**លើកទី៦**- នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ម៉ោង៨កន្លះដល់ម៉ោង១២ថ្ងៃត្រង់ នៅអាហារដ្ឋានផ្ទះបាយជនជាតិដើមភាគតិច មានកិច្ចប្រជុំក្រុមការងារបច្ចេកទេសរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការជនជាតិដើមភាគតិចកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមឃឹម ផុង** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច ក្នុងគោលបំណងបន្តបច្ចុប្បន្នភាពលើដំណើរការរៀបចំរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច។



កិច្ចប្រជុំពិគ្រោះយោបល់បន្តបច្ចុប្បន្នភាពសេចក្តីព្រាងរបាយការណ៍ជាតិ ស្តីពីស្ថានភាពប្រជាសាស្ត្រ និង សង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា នៅអាហារដ្ឋាន ផ្ទះបាយជនជាតិដើមភាគតិច ភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨

**លើកទី៧**- នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០១៨ នៅអាហារដ្ឋានផ្ទះបាយជនជាតិដើមភាគតិច ក្រុងភ្នំពេញ មានកិច្ចប្រជុំក្រុមការងារបច្ចេកទេសរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងផែនការ ដោយមានការចូលរួមពីអង្គការជនជាតិដើមភាគតិចកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់** និង **លោកឈុន ស៊ីវ៉ាថា** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច វេលាម៉ោង៩-១២ថ្ងៃត្រង់ដើម្បីបន្តបច្ចុប្បន្នភាពរបាយការណ៍ជាតិ ក្រោយពីសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសលើកទី១ និងរៀបចំផែនការសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួងជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ យោងផែនការសកម្មភាពបន្ទាប់ពីសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសលើកទី១ នៅភោជនីយដ្ឋានទន្លេបាសាក់ I ។



ប្រជុំពិគ្រោះយោបល់អំពីបច្ចុប្បន្នភាពសេចក្តីព្រាងរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា និងលើកផែនការសិក្ខាសាលាពិគ្រោះយោបល់លើកទី២ជាមួយអន្តរក្រសួង នៅអាហារដ្ឋានផ្ទះបាយជនជាតិដើមភាគតិច ភ្នំពេញ ថ្ងៃទី៨ ខែឧសភា ២០១៨

**លើកទី៨**- នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨ នៅបន្ទប់ប្រជុំ**លោកជំទាវម៉ាត់ ម៉ារ៉ា** ក្រសួងអភិវឌ្ឍន៍ជនបទ មានកិច្ចប្រជុំស្តីពីការរៀបចំសិក្ខាសាលាឆ្លងរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច ក្រោមអធិបតីភាព**លោកជំទាវម៉ាត់ ម៉ារ៉ា** និង**ឯកឧត្តមយឹម ជុង** ចូលរួមដោយសមាជិកនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច អង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) និងលេខាធិការដ្ឋានសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា(CIPA)។ លោកជំទាវស្នើឱ្យក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច ធ្វើការងារនេះដោយផ្ទាល់ជាមួយស្ថាប័នអង្គការជនជាតិដើមភាគតិច និងក្រសួងផែនការពិសេសជាមួយ **ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់** អំពីពេលវេលានិងទំហំកិច្ចការងារ។



ប្រជុំពិគ្រោះយោបល់អំពីដំណើរការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ឆ្លងសេចក្តីព្រាងរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា លើកទី២ នៅក្រសួងអភិវឌ្ឍន៍ជនបទ រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨

**លើកទី៩**- នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ នៅសណ្ឋាគារសាន់វេ ក្នុងទីក្រុងភ្នំពេញ មានការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ឆ្លងរបាយការណ៍ជាតិព្រាងលើកទី២ ដឹកនាំរៀបចំសម្របសម្រួលដោយក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ។ សិក្ខាសាលានេះបានចូលរួមសហការលើដំណើរការរៀបចំពីសមាជិកសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជារួមមាន CIPO, CIYA, CIPL, OPKC, HA និង IRAM, ដែលមានសមាសភាពចូលរួមសរុបចំនួន ៦៤រូប មកពីក្រសួងស្ថាប័នពាក់ព័ន្ធចំនួន១៦ និងតំណាងអង្គការជាតិ និងអន្តរជាតិដែលធ្វើការពាក់ព័ន្ធនឹងជនជាតិដើមភាគតិចរួមទាំងតំណាងសហគមន៍ជនជាតិដើមភាគតិចផងដែរ ក្រោមគណៈធិបតីភាពដ៏ខ្ពង់ខ្ពស់តំណាងឱ្យ**ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ពី**លោកជំទាវម៉ាត់ ម៉ារ៉ា** រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ និង**ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់** អនុរដ្ឋលេខាធិការនៃក្រសួងផែនការ។ ជាលទ្ធផលនៃអង្គសិក្ខាសាលា ក្រុមការងារបច្ចេកទេសបានព្រមព្រៀងលើការសរសេរឈ្មោះជនជាតិដើមភាគតិចឱ្យបានត្រឹមត្រូវដោយផ្អែកតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ដែលរាជរដ្ឋាភិបាល បានអនុម័ត។ ចំពោះឈ្មោះជនជាតិដើមដែលនៅមិនទាន់បានកំណត់ គឺស្នើឱ្យសម្រេចតាមបងប្អូនជនជាតិដើមឬម្ចាស់ជនជាតិផ្ទាល់។ ជាពិសេសអង្គសិក្ខាសាលាក៏បាន ស្នើឱ្យដាក់បញ្ចូលនូវឯកសារបច្ចុប្បន្នភាពដែលសហគមន៍បានស្វ័យអត្តសញ្ញាណសហគមន៍ដែលបានចុះបញ្ជីជានីតិបុគ្គល និងសហគមន៍ដែលបានចុះបញ្ជីដីជាលក្ខណៈសមូហភាព។ កិច្ចការងារទាំងអស់នេះជាសមិទ្ធផលរួមមួយបង្ហាញពីការខិតខំ និងយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលដល់បងប្អូនសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាផងដែរ។



**សិក្ខាសាលាពិគ្រោះយោបល់ឆ្លងសេចក្តីព្រាងរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចនៅកម្ពុជា លើកទី២ជាមួយអន្តរក្រសួង នៅសណ្ឋាគារសាន់វេភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ២០១៨**

**លើកទី១០**- នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ នៅភោជនីយដ្ឋាន ស៊ីនហៅស៍ ក្នុងទីក្រុងភ្នំពេញ មានកិច្ចប្រជុំរវាងក្រុមការងារបច្ចេកទេសពីអង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) អង្គការសមាគមខ្មែរលើ (HA) មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និងក្រសួងផែនការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**លោកជំទាវហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងជាអគ្គនាយកជំរឿនទូរទៅទូទាំងប្រទេស។ ជាលទ្ធផលនៃ កិច្ចប្រជុំគឺមានការឯកភាពទៅលើដំណើរការនៃការចូលរួមរបស់តំណាងជនជាតិដើមភាគតិចក្នុង ដំណើរការធ្វើជំរឿនស្ថិតិជាតិ២០១៩ ជាមន្ត្រីជំរឿន។ បន្ទាប់ពីកិច្ចប្រជុំរួច ជាលទ្ធផលឆ្លើយតប មានការចូលរួមយ៉ាងសកម្មពីសមាជិកសម្ព័ន្ធជនជាតិដើមភាគតិចកម្ពុជា គឺបានសហការជាមួយក្រសួងផែនការក្នុងការជួយសម្របសម្រួលផ្សព្វផ្សាយជ្រើសក្រុមការងារជនជាតិដើមភាគតិចដើម្បីដាក់ពាក្យជាមន្ត្រីជំរឿនឆ្នាំ២០១៩នេះ។ ចុងក្រោយមានជនជាតិដើមភាគតិចចូលរួមធ្វើជាមន្ត្រីសម្ភាសន៍ និងត្រួតពិនិត្យសរុបចំនួន៨៦ នាក់ មកពីខេត្តរតនគិរីចំនួន២៧ នាក់ ខេត្តមណ្ឌលគិរីចំនួន១៤ នាក់ ខេត្តក្រចេះចំនួន១៣ នាក់ ខេត្តស្ទឹងត្រែងចំនួន០៧នាក់ ខេត្តកំពង់ស្ពឺចំនួន០៨នាក់ ខេត្តកំពង់ធំ ចំនួន០១នាក់ និងខេត្តឧត្តរមានជ័យចំនួន០២នាក់ រួមទាំងមានក្រុមយុវជនចំនួន៤ នាក់ បានចូលរួមកែតម្រូវលទ្ធផលក្រោយជំរឿនឆ្នាំ២០១៩។



ប្រជុំពិភាក្សាពីដំណើរការដាក់បញ្ចូលជនជាតិដើមភាគតិចក្នុងក្រុមការងារជំរឿនឆ្នាំ២០១៩
នៅភោជនីយដ្ឋានស៊ីនហៅស៍ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨

**លើកទី១១**- នាថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង៩និង៣០នាទី នៅការិយាល័យលោកសុត សឿង នៃក្រសួងអភិវឌ្ឍន៍ជនបទ គឺមានកិច្ចប្រជុំស្តីពីបច្ចុប្បន្នភាពដំណើរការនៃការរៀបចំរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច រវាងសមាជិកសម្ពន្ធ័ជនជាតិដើមភាគតិចកម្ពុជា រួមមានអង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) អង្គការសមាគមខ្មែរលើ (HA) សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA) សមាជិកសកម្មការពារសិទ្ធិជនជាតិដើមភាគតិច (IRA) សមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា (CIWA) និងក្រុមការងារនាយកដ្ឋាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកសុត សឿង** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ និងមានអ្នកចូលរួមសរុបចំនួន៩ នាក់។



**ប្រជុំពង្រឹងកិច្ចសហការណ៍ល្អជាមួយប្រធាននាយកដ្ឋានជនជាតិភាគតិច និងបច្ចុប្បន្នភាពរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចជនជាតិដើមភាគតិចនៅកម្ពុជា នៅការិយាល័យនាយកដ្ឋានជនជាតិដើមភាគតិច ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៩**

**លើកទី១២**- នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ នៅសាលប្រជុំទីស្តីការក្រសួងផែនការ មានកិច្ចប្រជុំបន្តដើម្បីពិនិត្យអំពីបច្ចុប្បន្នភាពលើដំណើរការនៃការរៀបចំរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច រវាងក្រុមការងារបច្ចេកទេស មកពីអង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) និងក្រសួងផែនការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់** និង**ឯកឧត្តមជា ចាន់ទុំ** ដែលជាអ្នកដឹកនាំរៀបចំផ្ទាល់លើការបង្កើតរបាយការណ៍ជាតិនេះ។



**ប្រជុំពង្រឹងកិច្ចសហការណ៍ល្អដំណើរការបន្តបច្ចុប្បន្នភាពរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចជនជាតិដើមភាគតិចនៅកម្ពុជា នៅក្រសួងផែនការ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០**

**លើកទី១៣**- នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង៩:៣០-១១ព្រឹក មានកិច្ចប្រជុំមួយក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី**លោកសុត សឿង** ប្រធាននាយកដ្ឋានអភិវឌ្ឍជនជាតិភាគតិច និងក្រុមការងារ បច្ចេកទេស។ ជាលទ្ធផល លោកបានប្តេជ្ញាចិត្តនឹងគាំទ្រចូលរួមជំរុញសកម្មភាពផលិតរបាយការណ៍រហូតដល់ដាក់សម្ពោធជាផ្លូវការ។ លោកបានផ្តល់សិទ្ធិដល់មន្ត្រី២រូបឱ្យចូលរួមពាក់ព័ន្ធការងារនេះគឺ**លោកស្រី សំ សុម៉ាលី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍជនជាតិភាគតិច និង**លោកស្រី សេង កុសុមា** ប្រធានការិយាល័យ នៃក្រសួងអភិវឌ្ឍន៍ជនបទ។ ផែនការបន្ទាប់លោកស្រីទាំងពីរនឹងទៅចូលរួមប្រជុំនាថ្ងៃទី២៥ ជាមួយក្រសួងផែនការ ដើម្បីពិភាក្សាបន្តលើដំណើរការសកម្មភាពដាក់សម្ពោធរបាយការណ៍ជាតិនេះ។

**លើកទី១៤**- នាថ្ងៃទី២៥ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង៣រសៀល នៅសាលប្រជុំទីស្តីការក្រសួងផែនការ មានកិច្ចប្រជុំរវាងក្រុមការងារបច្ចេកទេសស្តីពីបច្ចុប្បន្នភាពលើលទ្ធផលនៃការបង្កើតរបាយការណ៍ជាតិស្តីពីស្ថានភាពប្រជាសាស្ត្រនិងសង្គម-សេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច ក្នុងគោលបំណងដើម្បីពិភាក្សាអំពីដំណើរការនៃការសហការរវាងក្រសួងផែនការនិងក្រសួងអភិវឌ្ឍន៍ជនបទក្នុងការដឹកនាំរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងជាមួយថ្នាក់ដឹកនាំកម្រិតនយោបាយ និងកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់របាយការណ៍ជាតិនេះជាផ្លូវការ ដែលមានសមាសភាពចូលរួមសរុបចំនួន១០រូប មកពីក្រសួងអភិវឌ្ឍន៍ជនបទចំនួន៣រូបដឹកនាំដោយ**លោកស្រីសំ សុម៉ាលី** ក្រសួងផែនការមានចំនួន៣រូប អង្គការជនជាតិដើមភាគតិចកម្ពុជាចំនួន៤រូប និងអង្គការទិន្នន័យអំពីការអភិវឌ្ឍ ODC ចំនួន១រូប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់** និង**ឯកឧត្តមជា ចាន់ទុំ**។



**ប្រជុំពង្រឹងកិច្ចសហការណ៍ល្អរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងផែនការ បន្តបច្ចុប្បន្នភាពរបាយការណ៍ជាតិ ស្តីពីស្ថានភាពប្រជាសាស្ត្រ និងសង្គម-សេដ្ឋកិច្ចជនជាតិដើមភាគតិចនៅកម្ពុជា នៅក្រសួងផែនការ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០**

លទ្ធផលនៃកិច្ចប្រជុំ គឺ**ឯកឧត្តមបណ្ឌិត ប៉ូច ប៊ុណ្ណាក់** បានធ្វើបច្ចុប្បន្នភាពនៃការងារបង្កើតរបាយការណ៍ជាតិដែលនឹងត្រូវបញ្ចប់ក្នុងកំឡុងខែមិថុនា ដោយមានកិច្ចការសេសសល់មួយចំនួនដូចជា៖ ការទាញយកទិន្នន័យ បុព្វកថា សារតា ជាភាសាខ្មែរនិងបកប្រែជាអង់គ្លេស ស្របតាមពាក្យគន្លឹះមួយចំនួនដូចក្នុងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចឆ្នាំ២០០៩ និងអាចតាមការសរសេរឡើងដោយឯកឧត្តមដើម្បីឆ្លងក្រុមសម្រេចបន្ត ជាពិសេសឆ្លងជាមួយក្រុមដឹកនាំកម្រិតនយោបាយ ពីបណ្ដាក្រសួងពាក់ព័ន្ធសំខាន់ៗ។ ចំណែកឯកិច្ចសហការរវាងក្រសួង គឺ**លោកស្រីសំ សុម៉ាលី** ជំនួសឱ្យលោកសុត សឿន ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច បានស្នើសុំឱ្យក្រសួងផែនការដើរតួជាអ្នកដឹកនាំសម្របសម្រួលរៀបចំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំកម្រិតនយោបាយ និងការដាក់សម្ពោធឱ្យប្រើប្រាស់របាយការណ៍ជាតិជាផ្លូវការ ពីព្រោះក្រសួងផែនការជាអ្នកបច្ចេកទេសសរសេររបាយការណ៍នេះដោយផ្ទាល់ និងមានបទពិសោធន៍ក៏ដូចជាមានការយល់ដឹងច្បាស់លាស់លើដំណើរការរៀបចំនេះ ដោយឡែកក្រសួងអភិវឌ្ឍន៍ជនបទស្នើសុំត្រឹមតែជាអ្នកចូលរួម។ ជាលទ្ធផលគឺ**ឯកឧត្តមប៉ូច ប៊ុណ្ណាក់** និង**ឯកឧត្តមជា ចាន់ទុំ** ក៏បានឯកភាពតាមការស្នើសុំរបស់**លោកស្រីសំ សុម៉ាលី** ហើយឯកឧត្តម ក៏បានមានប្រសាសន៍ថាក្រុមការងារក្រសួងផែនការ នឹងបន្តសហការរៀបចំជាមួយអង្គការជនជាតិដើមភាគតិចកម្ពុជា លើផ្នែកភស្តុភារ។

# ឧបសម្ព័ន្ធទី២. ភូមិដែលមានជនជាតិដើមភាគតិច ១០នាក់ឡើង

| No. | Province | District | Commune | Village | Urban | Number of IP |
|---|---|---|---|---|---|---|
| 1 | Banteay Meanchey | Preah Netr Preah | Chob Vari | Chroab Thmei | Rural | 34 |
| 2 | Banteay Meanchey | Krong Serei Saophoan | Kampong Svay | Kampong Svay | Urban | 23 |
| 3 | Banteay Meanchey | Malai | Boeng Beng | Khla Ngoab | Rural | 15 |
| 4 | Banteay Meanchey | Krong Paoy Paet | Sangkat Paoy Paet | 1100202 | Urban | 12 |
| 5 | Banteay Meanchey | Krong Paoy Paet | Sangkat Paoy Paet | 1100201 | Urban | 30 |
| 6 | Battambang | Banan | Kantueu Pir | Kampang Lech | Rural | 19 |
| 7 | Battambang | Krong Battambang | Svay Pao | Preaek Moha Tep | Urban | 13 |
| 8 | Battambang | Samlout | Samlout | 2090506 | Rural | 13 |
| 9 | Battambang | Sampov Lun | Chrey Seima | 2100606 | Rural | 17 |
| 10 | Battambang | Phnom Proek | Pech Chenda | Phnum Touch | Rural | 23 |
| 11 | Battambang | Kamrieng | Boeung Reang | Doung | Rural | 10 |
| 12 | Kampong Cham | Chamkar Leu | Cheyyou | Trapeang Ruessei | Rural | 14 |
| 13 | Kampong Cham | Chamkar Leu | Cheyyou | Spueu | Rural | 15 |
| 14 | Kampong Cham | Chamkar Leu | Ta Ong | Phum Sammuoy | Rural | 16 |
| 15 | Kampong Cham | Cheung Prey | Soutip | Skon | Urban | 19 |
| 16 | Kampong Cham | Krong Kampong Cham | Boeng Kok | Boeng Kok Pir | Urban | 19 |
| 17 | Kampong Cham | Kang Meas | Peam Chi Kang | Kaoh Touch | Rural | 11 |
| 18 | Kampong Cham | Srei Santhor | Khnar Sa | Ampil | Rural | 14 |
| 19 | Kampong Chhnang | Kampong Tralach | Chhuk Sa | Tuol | Rural | 10 |
| 20 | Kampong Chhnang | Kampong Tralach | Kampong Tralach | Kampong Tralach Kraom | Rural | 10 |
| 21 | Kampong Chhnang | Kampong Tralach | Ou Ruessei | Srae Prei | Rural | 14 |
| 22 | Kampong Chhnang | Sameakki Mean Chey | Svay | Svay Ph-aem | Rural | 18 |
| 23 | Kampong Speu | Aoral | Trapeang Chour | 5040319 | Rural | 68 |
| 24 | Kampong Speu | Aoral | Trapeang Chour | 5040318 | Rural | 169 |
| 25 | Kampong Speu | Aoral | Trapeang Chour | 5040321 | Rural | 174 |
| 26 | Kampong Speu | Aoral | Trapeang Chour | 5040316 | Rural | 205 |

| No. | Province | District | Commune | Village | Urban | Number of IP |
|---|---|---|---|---|---|---|
| 27 | Kampong Speu | Aoral | Trapeang Chour | 5040317 | Rural | 215 |
| 28 | Kampong Speu | Samraong Tong | Tang Krouch | Tuek L-ak | Rural | 25 |
| 29 | Kampong Thom | Baray | Kokir Thum | Kokir Thum | Rural | 23 |
| 30 | Kampong Thom | Baray | Krava | Kampong Sdach | Rural | 10 |
| 31 | Kampong Thom | Baray | Krava | Rung | Rural | 14 |
| 32 | Kampong Thom | Baray | Svay Phleung | Krouch | Rural | 10 |
| 33 | Kampong Thom | Kampong Svay | Chey | Koun Tnaot | Rural | 287 |
| 34 | Kampong Thom | Kampong Svay | Damrei Slab | Kab Thlok | Rural | 11 |
| 35 | Kampong Thom | Kampong Svay | Trapeang Ruessei | Prey Preal Kha | Rural | 10 |
| 36 | Kampong Thom | Kampong Svay | Trapeang Ruessei | 6020919 | Rural | 91 |
| 37 | Kampong Thom | Krong Stueng Saen | Damrei Choan Khla | Balang Khang Lech | Urban | 10 |
| 38 | Kampong Thom | Krong Stueng Saen | Achar Leak | Prey Banlich | Urban | 14 |
| 39 | Kampong Thom | Prasat Ballangk | Phan Nheum | Smaonh | Rural | 148 |
| 40 | Kampong Thom | Prasat Ballangk | Sala Visai | Ou Krouch | Rural | 87 |
| 41 | Kampong Thom | Prasat Ballangk | Sala Visai | Sala Visai | Rural | 110 |
| 42 | Kampong Thom | Prasat Ballangk | Sala Visai | Kokir | Rural | 289 |
| 43 | Kampong Thom | Prasat Ballangk | Sala Visai | Andas | Rural | 369 |
| 44 | Kampong Thom | Prasat Ballangk | Sala Visai | Tralaek | Rural | 439 |
| 45 | Kampong Thom | Prasat Ballangk | Sala Visai | 6040521 | Rural | 466 |
| 46 | Kampong Thom | Prasat Ballangk | Sala Visai | Kvan Tieng | Rural | 600 |
| 47 | Kampong Thom | Prasat Ballangk | Sala Visai | Srae | Rural | 683 |
| 48 | Kampong Thom | Prasat Sambour | Chhuk | Veal Veaeng | Rural | 476 |
| 49 | Kampot | Angkor Chey | Ankor Chey | Prey Chheu Teal | Rural | 11 |
| 50 | Kampot | Angkor Chey | Mroum | Chheu Teal | Rural | 10 |
| 51 | Kampot | Chum Kiri | Srae Chaeng | Khpob Run | Rural | 28 |
| 52 | Kampot | Chum Kiri | Trapeang Reang | Ta Reach | Rural | 10 |
| 53 | Kampot | Tuek Chhou | Boeng Tuk | Roluos | Rural | 10 |
| 54 | Kampot | Tuek Chhou | Prey Thnang | Chakkrei Ting | Rural | 12 |
| 55 | Kandal | Kandal Stueng | Barku | Tboung Kdei | Rural | 10 |

| No. | Province | District | Commune | Village | Urban | Number of IP |
|---|---|---|---|---|---|---|
| 56 | Kandal | Kien Svay | Kbal Kaoh | Yok Bat | Urban | 11 |
| 57 | Kandal | Khsach Kandal | Puk Ruessei | Anhcheaeng Leu | Rural | 10 |
| 58 | Kandal | Kaoh Thum | Preaek Chrey | Pak Nam | Rural | 16 |
| 59 | Kandal | Kaoh Thum | Preaek Sdei | Chong Preaek | Rural | 10 |
| 60 | Kandal | Kaoh Thum | Preaek Sdei | Preaek Ta Mem | Rural | 10 |
| 61 | Kandal | Kaoh Thum | Preaek Sdei | Preaek Louk | Rural | 11 |
| 62 | Kandal | Kaoh Thum | Preaek Sdei | Pouthi Reamea | Rural | 19 |
| 63 | Kandal | Mukh Kampul | Bak Kaeng | Kdei Chas | Rural | 13 |
| 64 | Kandal | Mukh Kampul | Bak Kaeng | Chambak Meas | Rural | 25 |
| 65 | Kandal | Mukh Kampul | Kaoh Dach | Lvea | Rural | 13 |
| 66 | Kandal | Mukh Kampul | Kaoh Dach | Chong Kaoh | Rural | 14 |
| 67 | Kandal | Mukh Kampul | Preaek Anhchanh | Preaek Ta Baen | Rural | 10 |
| 68 | Kandal | Saang | Traeuy Sla | Preaek | Rural | 11 |
| 69 | Koh Kong | Botum Sakor | Ta Noun | Preaek Khyang | Rural | 11 |
| 70 | Koh Kong | Krong Khemarak Phoumin | Dang Tong | Phum Ti Buon | Urban | 10 |
| 71 | Kratie | Krong Kracheh | Ou Ruessei | Kapou | Urban | 26 |
| 72 | Kratie | Krong Kracheh | Roka Kandal | Rokaa Kandaal Muoy | Urban | 16 |
| 73 | Kratie | Sambour | Boeng Char | Damrae | Rural | 146 |
| 74 | Kratie | Sambour | Boeng Char | Kaoh Dambang | Rural | 376 |
| 75 | Kratie | Sambour | Boeng Char | Kampong Roteh | Rural | 536 |
| 76 | Kratie | Sambour | Kbal Damrei | Changhab | Rural | 108 |
| 77 | Kratie | Sambour | Kbal Damrei | Ou Pou | Rural | 151 |
| 78 | Kratie | Sambour | Kbal Damrei | Srae Traeng | Rural | 703 |
| 79 | Kratie | Sambour | Kaoh Khnhaer | Kampong Pnov | Rural | 26 |
| 80 | Kratie | Sambour | Ou Krieng | Kaoh Khnhaer | Rural | 19 |
| 81 | Kratie | Sambour | Ou Krieng | Ou Krieng | Rural | 40 |
| 82 | Kratie | Sambour | Ou Krieng | Srae Sangkae | Rural | 107 |
| 83 | Kratie | Sambour | Ou Krieng | Ou Preah | Rural | 174 |
| 84 | Kratie | Sambour | Ou Krieng | Pon Ta Chea | Rural | 435 |

| No. | Province | District | Commune | Village | Urban | Number of IP |
|---|---|---|---|---|---|---|
| 85 | Kratie | Sambour | Roluos Mean Chey | Srae Chhuk | Rural | 325 |
| 86 | Kratie | Sambour | Roluos Mean Chey | Srae Roluos | Rural | 577 |
| 87 | Kratie | Sambour | Roluos Mean Chey | Pakleae | Rural | 830 |
| 88 | Kratie | Sambour | Roluos Mean Chey | Toung | Rural | 968 |
| 89 | Kratie | Sambour | Sandan | Sangkom | Rural | 504 |
| 90 | Kratie | Sambour | Srae Chis | Phnum Pir | Rural | 258 |
| 91 | Kratie | Sambour | Srae Chis | Koun Va | Rural | 360 |
| 92 | Kratie | Sambour | Srae Chis | Srae Tnaot | Rural | 643 |
| 93 | Kratie | Sambour | Srae Chis | Rovieng | Rural | 781 |
| 94 | Kratie | Sambour | Srae Chis | Ampok | Rural | 968 |
| 95 | Kratie | Sambour | Srae Chis | Srae Chis | Rural | 1084 |
| 96 | Kratie | Snuol | Khsuem | Srae Thmei | Rural | 132 |
| 97 | Kratie | Snuol | Khsuem | Samrang | Rural | 158 |
| 98 | Kratie | Snuol | Khsuem | Mil | Rural | 173 |
| 99 | Kratie | Snuol | Khsuem | Choeng | Rural | 392 |
| 100 | Kratie | Snuol | Pir Thnu | 10050209 | Rural | 14 |
| 101 | Kratie | Snuol | Pir Thnu | Cheung Khlu | Rural | 226 |
| 102 | Kratie | Snuol | Pir Thnu | Trapeang Srae | Rural | 325 |
| 103 | Kratie | Snuol | Pir Thnu | Thma Hal Veal | Rural | 366 |
| 104 | Kratie | Snuol | Pir Thnu | Cheung Khle | Rural | 457 |
| 105 | Kratie | Snuol | Pir Thnu | Thma Hal Dei Kraham | Rural | 540 |
| 106 | Kratie | Snuol | Pir Thnu | Pravanh | Rural | 734 |
| 107 | Kratie | Snuol | Snuol | 10050312 | Rural | 20 |
| 108 | Kratie | Snuol | Snuol | Thpong | Rural | 31 |
| 109 | Kratie | Snuol | Snuol | Preaek Kdei | Rural | 185 |
| 110 | Kratie | Snuol | Snuol | Trapeang Leak | Rural | 223 |
| 111 | Kratie | Snuol | Snuol | Kbal Snuol | Rural | 281 |
| 112 | Kratie | Snuol | Snuol | Krong | Rural | 592 |
| 113 | Kratie | Snuol | Srae Char | Treak | Rural | 25 |
| 114 | Kratie | Snuol | Srae Char | Mak Kandal | Rural | 26 |

| No. | Province | District | Commune | Village | Urban | Number of IP |
|---|---|---|---|---|---|---|
| 115 | Kratie | Snuol | Srae Char | Mean Chey | Rural | 56 |
| 116 | Kratie | Snuol | Srae Char | Kbal Trach | Rural | 204 |
| 117 | Kratie | Chitr Borie | Changkrang | 10060202 | Rural | 410 |
| 118 | Kratie | Chitr Borie | Kantuot | 10060401 | Rural | 501 |
| 119 | Kratie | Chitr Borie | Kantuot | 10060405 | Rural | 555 |
| 120 | Kratie | Chitr Borie | Kou Loab | 10060502 | Rural | 21 |
| 121 | Kratie | Chitr Borie | Sambok | 10060701 | Rural | 73 |
